# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ សៅ ពត ភេទប្រុស អាយុ៧១ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ គណៈឃុំកំពង់ស្វាយ
## មុខងារបច្ចុប្បន្នៈ ក្រុមប្រឹក្សាឃុំជាងទង
## សព្វថ្ងៃរស់នៅភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ
## ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា
## ០២:២៥:៣២
## ៦៣ទំព័រ

ដានី : បាទ! ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះ លោកតាៗឈ្មោះពេញឈ្មោះអីដែរ?

ពត : ឈ្មោះនោះឈ្មោះគេស្គាល់ម៉ាប្រទេសជាតិ(សើច) ម៉ាពិភពលោកហើយ គឺខ្ញុំឈ្មោះពតៗ

ដានី : ឈ្មោះ ពត ប៉ុន្តែឈ្មោះក្នុងបញ្ជីជាតិលោកតា?

ពត : បញ្ជីជាតិខ្ញុំឈ្មោះ សៅ វនៗ ប៉ុនជំនាន់នឹងខ្ញុំធ្វើការនឹង ខ្ញុំឈ្មោះ ពត ក្នុងបញ្ជីជាតិពី សង្គមចាស់នឹង ខ្ញុំរៀនឪពុកខ្ញុំដាក់ពតៗ

ដារ៉ា : ពត ទទេរចឹងម៊ង ឬក៏មាន?

ពត : បាទ! សៅ ពតៗ

ដារ៉ា : សៅ ពត?

ពត : បាទ! សៅ ពតៗ

ដានី : សៅ ពត ប៉ុន្តែក្រោយមក?

ពត : បច្ចុប្បន្ននេះ សៅ វន រាល់ថ្ងៃនេះសៅ វនៗ

ដានី : ម៉េចបានលោកតាដាក់ដូរមកដាក់ សៅ វនវិញ?

ពត : ដូរមកដាក់ សៅ វននេះ សៅ ពតនេះឈ្មោះឪពុកខ្ញុំដាក់ៗ បាទ! ដល់ហើយមកខ្ញុំបោះឆ្នោតឈរតំណាងឈរក្រុមប្រឹក្សាឃុំខាងគណៈបក្សសមរង្ស៊ី ខ្ញុំដាក់អឺ!អាណត្តិទី១នឹង ខ្ញុំដាក់ សៅ វន ប៉ុន្តែកាលនឹងមិនទាន់ចុះបញ្ជីអត្រានុកូលដ្ឋានទេណាៗ ហើយនៅខាងកន្លែង គ.ជ.បនេះ គេថាមិនអាចផ្លាស់បានទេ ឈ្មោះពត ព្រោះចុះទៅហើយដាក់ឈ្មោះហួសទៅហើយៗ ចឹងដាក់ ពត ចឹងម៊ង ចឹងអាណត្តិទីមួយខ្ញុំឈ្មោះ ពតៗ ប៉ុនឥឡូវនេះដាក់

សៅ វន ហើយតាមបញ្ជីជាតិ ។ នៅក្នុងក្រុមប្រឹក្សាឃុំបច្ចុប្បន្ននេះ សៅ វន ខាងសមរង្ស៊ី ។

ដានី : លោកតាសព្វថ្ងៃអាយុប៉ុន្មានហើយ?

ពត : អាយុច្រើនហើយ ៧១ ។

ដានី : ៧១?

ពត : បាទ!

ដានី : លោកតាស្រុកកំណើតកើតជាលោកតានៅណាទៅ?

ពត : នៅនឹងម៉ង ភូមិស្រែខ្វាវ ឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានី : ឃុំដាងទង?

ពត : បាទ!

ដានី : ចុះសព្វថ្ងៃ?

ពត : សព្វថ្ងៃនៅ ។

ដានី : សព្វថ្ងៃរស់នៅភូមិឃុំដដែល?

ពត : ភូមិឃុំដដែល ។

ដានី : លោកយាយគាត់ឈ្មោះអីដែរ?

ពត : ញឹម អឿន ។

ដានី : គាត់អាយុប៉ុន្មានដែរឥឡូវ?

ពត : ៦៦ ។

ដានី : បាទ! លោកតាមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ពត : កូនចៅទាំងអស់ ខ្ញុំប្រពន្ធ២ ហើយឥឡូវបូកសរុបនៅ១០ ។

ប្រពន្ធ : ប្រពន្ធ២ មួយមុនស្លាប់ ទាំងសងខាង ខ្ញុំក៏មានដែរ ប៉ុនស្លាប់ ។

ពត : មុនស្លាប់បានកូន១ ហើយនេះប្រពន្ធផង គាត់មានគ្រួសារប៉ុនបានកូន២ ហើយដល់ឥឡូវស្លាប់មួយ ។ ដូច្នេះនៅ១ ។ទាំងសងខាង ដល់ខ្ញុំយកគាត់មកនេះបាន៨ទៀត ក្រោយ ។

ដានី : បាន៨ទៀត?

ពត : បាទ! ចឹង១០ ។

ដានី : ១០នាក់?

ពត : នៅ១០ ។

ដានី ៖ អឺ! លោកតាសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

ពត ៖ ខ្ញុំអឺ! មុខរបរធ្វើស្រែ ក្អួយ ។

ដានី ៖ មុខរបរធ្វើស្រែ?

ពត ៖ បាទ!

ដានី ៖ ធ្វើអីទៀត?

ពត ៖ ធ្វើស្រែ អឺ!រាល់ថ្ងៃនេះ អ្នកស្រុកពឹងពរឲ្យធ្វើអាចារ្យកាន់ពាលាអី ។

ដានី ៖ អាចារ្យកាន់ពាលា ។ បាទ! ហើយលោកតាឥឡូវនឹងមានតួនាទីជាក្រុមប្រឹក្សាឃុំដែរ?

ពត ៖ បាទ! ក្រុមប្រឹក្សាឃុំ ។

ដានី ៖ ខាងគណៈអឺ! សមរង្ស៊ី?

ពត ៖ បាទ!

ដានី ៖ ចាប់ពីអាណត្តិណាមក?

ពត ៖ ពីអាណត្តិទី១មកឈ្មោះ ពត ប៉ុនដល់អាណត្តិក្រោយនេះដាក់វិន ។

ដារ៉ា ៖ ចុះពីគិតពីឆ្នាំណាមក?

ពត ៖ ២០០២ ពេលបោះឆ្នោត ។

ដារ៉ា ៖ អូ! ២០០២ដែលពេលបោះឆ្នោតអាណត្តិក្រុមប្រឹក្សាឃុំលើកទី១?

ពត ៖ បាទ! លើកទី១បាទ ។

ដារ៉ា ៖ ចឹងកាលពេលអាណត្តិទី១អ៊ំជាប់?

ពត ៖ ជិទប់ទី២ ។

ដារ៉ា ៖ ចុះបច្ចុប្បន្ននេះ?

ពត ៖ បច្ចុប្បន្នក្រុមប្រឹក្សាសមរង្ស៊ី មាន២កៅអី ។

ដារ៉ា ៖ ជាក្រុមប្រឹក្សា?

ពត ៖ បាទ!

ដារ៉ា ៖ ជាសមាជិកក្រុមប្រឹក្សា ឬក៏ជាប្រធានក្រុមប្រឹក្សា?

ពត ៖ បាន២កៅអី ចេះបាន២ចឹងទៅ ប្អូនមួយនោះវាក្មេងអាយុ៣០ជាងឲ្យទៅជាជិទប់ទី២ ខ្ញុំជាក្រុមប្រឹក្សាវិញចឹង ។

ដារ៉ា ៖ ចឹងអ៊ំជាក្រុមប្រឹក្សាឃុំជាងទង?

ពត ៖ បាទ!

ដារ៉ា ៖ តែមកពីគណបក្សសមរង្សី?

ពត ៖ បាទៗ ។

ដានី ៖ ចឹងអ៊ី! ខ្ញុំចង់ដឹងពីជីវិតរបស់តា តាំងពីក្មេងមក ដូចថាលោក ដូចថាកាលពីក្មេងៗមក លោកតាដូចថាធ្លាប់បានរៀនសូត្រអី ពីត្រឹមណាដល់ត្រឹមណាដែរ?

ពត ៖ ដែលចេះបួន ពីក្មេងមក ខ្ញុំរៀនឪពុកបានឲ្យទៅរៀនឪពុកបានឲ្យទៅរៀននឹងបានជាប់ Certificateថ្នាក់ទី៧ គេពីដើមគេហៅ Certificateណា៎ ។ ហើយបងខ្ញុំគាត់ឲ្យខ្ញុំ កុងគួកធ្លាក់ចូលអនុវិទ្យាល័យដទៃតាកែវ ។ គាត់ឲ្យរៀនសាលាឯកជនPrivateពីដើមបាន២ឆ្នាំ ដល់ថ្នាក់ទី៥ ។ ចឹងអ៊ី!បានជាប់សញ្ញាប័ត្រគេហៅបឋមភូមិបំពេញវិជ្ជាបារាំង-ខ្មែរ អានឹងហៅ Certificate មានសញ្ញាប័ត្រនឹងមួយ ។ ចេះដាក់ថ្នាក់ទី៧ពីដើមក៏បាន ទី៧ចាស់ ។

ដានី ៖ លោកតាចូលរៀនតាំងពីឆ្នាំណាមក?

ពត ៖ យី! តាំងពីអាណានិគមន៍បារាំង តាំង៥៣ ៥៤អីមក ។

ដានី ៖ រៀននៅណា?

ពត ៖ សាលាបឋមអង្គការនេះ ហើយជាប់Certificateនឹង៥៧ ឆ្នាំ៥៧ ។

ដានី ៖ នៅសាលាអង្គការដដែល?

ពត ៖ បាទ! អង្គការដដែល ។

ដានី ៖ ចឹងដល់ពេលឆ្នាំ៥៧នឹង អ៊ី!ឈប់រៀន?

ពត ៖ បាទ! ឈប់រៀនព្រោះកម្រិតជីវភាពវាក្រ ។

ដានី ៖ ចុះលោកតាមានប្រសាសន៍មិញថាទៅរៀនសាលា?

ពត ៖ ទៅរៀនថ្នាក់ទី៦Private ថ្នាក់ទី៥ Privateឯកជននោះ បងស្រីខ្ញុំគាត់ប្ដីគ្រូបង្រៀនគាត់ឲ្យថវិកាទៅរៀន បន្តបាន២ឆ្នាំ ។

ដានី ៖ រៀននៅណា?

ពត ៖ ហ្នឹងវេជ្ជសាស្ត្រតាកែវ សាលាអនុវិទ្យាល័យវេជ្ជសាស្ត្រតាកែវ Privateណា៎ កាលនឹង ។

ដារ៉ា ៖ នឹងនៅទីរួមខេត្តតាកែវ?

ពត ៖ បាទ! ទីរួមខេត្តតាកែវ ។

ដានី ៖ បាទ! រៀនបាន២ឆ្នាំ?

ពត ៖ ២ឆ្នាំពីថ្នាក់ទី៦ ពីដើមថ្នាក់ទី៦ ទី៥ ទី៤ ហើយបានទី៣ប្រឡងឌីប្លូម ។

ដានី ៖ បាទ! ចឹងបានរៀនខេត្តតាកែវបានតែ២ឆ្នាំទេ?

ពត ៖ បាទ! បានតែ២ឆ្នាំទេ ដល់ថ្នាក់ទី៥ ។

ដារ៉ា ៖ ចឹងនៅក្នុងជំនាន់នឹងអ៊ីដូចថាជីវភាពរស់នៅរបស់អ្នកស្រុក អ្នកភូមិនៅក្នុងភូមិអ៊ីមានលក្ខណៈយ៉ាងម៉េចដែរអ៊ី?

ពត ៖ កាលនោះបើនិយាយពីក្រជាងគេ គឺឪពុកម្តាយខ្ញុំនឹងហើយ និយាយស្មោះត្រង់ ។

ដារ៉ា ៖ ចង់និយាយពីជីវភាពទូទៅក្នុងភូមិ?

ពត ៖ ជីវភាពទូទៅក្នុងភូមិ គេពីដើមនេះប្អូនវាមាន បើនិយាយទៅតាមការវិភាគកម្រិតជីវភាពដែលមានកសិកម្ម អានឹងខ្ញុំប្រើភាសាតាមសម័យប៉ុលពតគេបង្រៀនទេណា ហើយវាត្រឹមត្រូវមែន មានកសិករក្រ កសិករកណ្តាលថ្នាក់ក្រោម កសិករកណ្តាលទូទៅ មានតែប៉ុននឹងទេ ។ គ្រាន់ថាឲ្យមានដាច់គេអត់ទេ កម្រិតជីវភាព គឺអ្នកម៉ាឆ្នាំខ្វះ៣ខែ ម៉ាឆ្នាំអ្នកខ្វះខាត៦ខែអីចឹងទៅ គ្រួសារខ្លះម៉ាឆ្នាំគេសល់ផលបានហូបលើសពីចំនួនរបស់គេលក់ដូរ ។

ដារ៉ា ៖ បានតិច?

ពត ៖ បាទ!តិចតួច ហើយមានតែប៉ុន្មានគ្រួសារទេ ។

ដារ៉ា ៖ ហើយរបររកស៊ី ក្រៅពីធ្វើស្រែតែម៉ាមុខនឹង?

ពត ៖ ធ្វើតែស្រែ បាទ! ហើយនឹងដូរដូរ កាលជំនាន់នឹងគេទិញមាន់ជួញមាន់នឹងទិញពីនឹងយកទៅលក់ ទៅអង្គតាសោម រែកទៅ បើមានកង់ជីកទៅជំនាន់នឹង ។

ដារ៉ា ៖ ជំនាន់អ៊ីរៀនថ្នាក់Certificateនឹងជំនាន់នឹង?

ពត ៖ បាទ! ជំនាន់នឹង ។ ហើយខ្ញុំដែលមានខបនិស្ស័យបានរៀន ចង់និយាយថាមានភ័ព្វសំណាងបានរៀន ដោយសារជិតផ្ទះនឹងទេ វត្តអង្គរកានឹង ។ ប្អូនឯងមិនឃើញទេ ។

ដារ៉ា ៖ បាទ! មកតាមផ្លូវឃើញវត្តអង្គរកា ។

ពត ៖ បាទ! ហើយវត្តនឹងយើងមិនសូវទៅប្រហែលម៉ាគីឡូទៅមក ។

ដារ៉ា ៖ ទោះបីជាជីវភាពក្រីក្រ ប៉ុន្តែដោយសារសាលានៅជិតចឹងទៅ បានទៅរៀនទៅ?

ពត ៖ បាទ! សាលា ចេះប្រឹងទៅបានទៅរៀនទៅ ។

ដានី ៖ ចុះលោកទៅរៀននៅតាកែវបានតែ២ឆ្នាំ ម៉េចបានតែ២ឆ្នាំហើយឈប់?

ពត ៖ បាទ! ឈប់វាថវិកា ប្អូនកាលនឹងបង់ឲ្យគេសាលាឈ្នួលម៉ាខែ១៥០រៀល អឺ!១៥០ៗចឹង ជំនាន់នឹងម៉ាជី២០០០០ អឺ! ២០០ដាង អាទឹក៩ ទឹក៨អីម៉ាជី២០០ៗ ហើយកម្រិតបង ខ្ញុំគាត់មិនសូវនេះដែរ ។

ដានី ៖ នឹងឆ្នាំណា ដែលឈប់ពីតាកែវមក?

ពត : ឈប់ពីតាកែវឆ្នាំ មើលខ្ញុំ៥៧ជាប់Certificate ៥៧ ៥៨រៀន ៥៨ ៥៩ ឆ្នាំ៥៩នឹងឈប់ហើយ ។

ដានី : បាទ! ឈប់ហើយមកណាទៀតទៅ?

ពត : មកនឹងដើរអត់លាក់ទេ ដើររស់នៅការរស់ជំនាន់នឹងប្រឡោតខាងការងាររាជការ ដែលទៅប្រឡងនេះប្រឡងនោះអត់ជាប់ ធ្វើកម្មករទីណាត់ទីណែងអី ។

ដារ៉ា : នៅក្នុងភូមិនឹងដែរ?

ពត : អត់ទៅភ្នំពេញ រស់នៅភ្នំពេញទៅមកៗ ។ ប៉ុន្តែមុខរបរអីគ្មានទាំងអស់ ហើយគេកាន់ទៅ ។

ដារ៉ា : ដែលថាឥឡូវគេច្រើនដាក់ថាមុខរបរមិនច្បាស់លាស់?

ពត : បាទ! មិនច្បាស់លាស់ នឹងហើយ(សើច) កម្មករសេរី ធ្វើកូលីផ្ទះថ្មអីចឹងប្អូនណា តាមកម្រិតនេះ សំចតរស់នៅក្នុងវត្ត ។ ទៅនៅភ្នំពេញរស់នៅក្នុងវត្តៗសំពៅមាស ។

ដារ៉ា : វត្តសំពៅមាស?

ពត : បាទ!

ដានី : ពូរស់នៅភ្នំពេញរយៈពេលប៉ុន្មានឆ្នាំទៅ?

ពត : ទេ! រកកំណត់ ៣ឆ្នាំចឹងទៅ ខ្ញុំគិតថា៤ឆ្នាំ ដល់អាយុខ្ញុំអាយុ២៧ ២៨បានមកនៅស្រុកនឹង ។

ដារ៉ា : មកនៅស្រុកវិញ?

ពត : បាទ! អាយុ ។

ដារ៉ា : ចឹងចូលនៅក្នុងខ្ទង់៦០ប៉ុន្មាន អ៊ី៦០?

ពត : ៦០ នឹងខ្ទង់៦២ ៦៣អស់ ចាំមើលពីព្រោះ៦៨ ៦៩ ឆ្នាំ៧០រដ្ឋប្រហារ ។ ខ្ញុំឆ្នាំ៧០រដ្ឋប្រហារ ៦៤ ៦៥ខ្ញុំរស់នៅជាមួយឪពុកម្តាយវិញ ។

ដារ៉ា : មកភូមិនឹងម៉ង?

ពត : បាទ!

ដានី : ៦៤ ៦៥ មកនៅស្រុកជាមួយឪពុកម្តាយវិញ?

ពត : បាទ!

ដានី : ធ្វើអីទៅមកនៅជាមួយឪពុកម្តាយ?

ពត : ឪពុកម្តាយធ្វើកសិករ នៅធ្វើស្រែជាមួយគាត់ ។

ដានី ៖ តែអ៊ំធ្វើអី?

ពត ៖ ខ្ញុំ?

ដានី ៖ បាទ!

ពត ៖ ធ្វើស្រែនឹង ។

ដានី ៖ ធ្វើស្រែ?

ពត ៖ បាទ!

ដានី ៖ ធ្វើស្រែ ចុះអ៊ំរៀបការឆ្នាំណាទៅ?

ពត ៖ ឆ្នាំអី! មើលឆ្នាំ៦៨ ១៩៦៨ ។

ដានី ៖ ១៩៦៨ អ៊ំរៀបការ?

ពត ៖ បាទ! រៀបការ ។

ដានី ៖ កាលនឹងប្រពន្ធអ៊ំឲ្យរៀបការជាមួយប្រពន្ធអ៊ំមុន?

ពត ៖ អ៊ំមុន ។

ដានី ៖ បាទ! គាត់ឈ្មោះអីដែរ?

ពត ៖ ឈ្មោះមាស សុន ។

ដានី ៖ មាស សុន?

ពត ៖ បាទ!

ដានី ៖ គាត់អ្នកនៅណាដែរ?

ពត ៖ អ្នកស្វាយរៀង ប៉ុន្ដែខ្ញុំមិនទាន់ដែលបានទៅស្រុកគាត់ផងទេ ។

ដានី ៖ បាទ! គាត់ម៉េចបានអ៊ំដូចថា គាត់អ្នកស្វាយរៀង អ៊ំអ្នកនៅនេះ?

ពត ៖ ជួបគ្នានៅភ្នំពេញ កាលនឹងខ្ញុំទៅនៅភ្នំពេញជួបគ្នានៅ ។

ដានី ៖ ជួបគ្នាហើយមក?

ពត ៖ មកនេះមក ។

ដានី ៖ មកដល់ឆ្នាំ៦៨បានរៀបការ ចឹង៣-៤ឆ្នាំ?

ពត ៖ អត់ទេ ដល់ស្លាប់គាត់ស្លាប់ ទៅបានខ្ញុំរៀបការនេះ ។ ហើយបើនេះប្រពន្ធនឹងជម្រាបត្រង់គ្រាន់បានសែនព្រេងអី អានេះ ។

ដានី ៖ បាទ! ចឹងអ៊ំជួបជាមួយប្រពន្ធមុននៅទីក្រុងភ្នំពេញទេ?

ពត ៖ បាទ! ភ្នំពេញ ។

ដានី ៖ ពីឆ្នាំណា ជួបគាំងពីឆ្នាំណា?

ពត ៖ ខ្ទង់៦៥ ៦៦ ៦៧ ព្រោះការបានជាងម៉ាឆ្នាំ អឺ!រស់នៅបានជាងម៉ាឆ្នាំចូល២ឆ្នាំ គាត់ស្លាប់ កូនបាន៧ខែ គាត់ក៏ស្លាប់ទៅ ។

ដានី ៖ ដល់ពេលគាត់ស្លាប់បានគាត់ឲ្យអ៊ំអញ្ជើញមកនេះ?

ពត ៖ អត់ទេ មកនៅនេះ គាត់មកជាមួយនៅរស់នៅជាមួយខ្ញុំ មកនៅនឹងផ្ទះម៉ែឪនេះ ឪពុកខ្ញុំទៅយកមក ។

ដានី ៖ គាត់ស្លាប់ឆ្នាំណា?

ពត ៖ ណាំ មើលខ្ទង់៦៥ ៦៦ហើយ ១៩៦៥ ១៩៦៦ ។

ដានី ៖ ម៉ាឆ្នាំ ចឹងឆ្នាំ៦៨អ៊ំរៀបការជាមួយនឹងអឺ!លោកយាយ?

ប្រពន្ធ ៖ ចាំ!

ដានី ៖ បាទ! លោកយាយអ្នកស្រុកណាដែរ?

ពត ៖ ស្រុកអឺ! នៅឃុំជាងទងនឹងដែរ ប៉ុនបច្ចុប្បន្នគេហៅឃុំត្រពាំងធំខាងជើង នៅភូមិត្រពាំងទឹក ។

ដានី ៖ នៅភូមិពាងទឹក?

ពត ៖ ភូមិត្រពាំងទឹក ។

ដានី ៖ ត្រពាំងទឹក?

ពត ៖ បាទ! ពីដើម ។

ដានី ៖ ចឹងដល់ពេលឆ្នាំ៦៨ លោកតារៀបការជាមួយលោកយាយ ហើយធ្វើការអីដល់ពេលយើងដូចថាធ្វើការ?

ពត ៖ កាលនឹងធ្វើ អត់មានធ្វើអី ប្អូននៅជនបទធ្វើតែស្រែនឹង ។

ដានី ៖ បាទ!

ពត ៖ បាទ!៦៨ ហើយដល់៦៩យើងធ្វើៗដល់ឆ្នាំ៧០រដ្ឋប្រហារ ១ នឹងអានឹងក៏ ។

ដានី ៖ យ៉ាងម៉េចទៅដល់ពេលរដ្ឋប្រហារ?

ពត ៖ រដ្ឋប្រហារហើយ កាលនឹងជម្រាបត្រង់អាជិនាន់នឹងពេល អឺ!នៅភូមិនឹងបើកាលណាយើងចលនាបក្ស ចលនាវាកើតមាន បដិវត្តមកចូលមកមានឈ្មោះថាអង្គការរណសិរ្សរួបរួមជាតិកម្ពុជាណាំ ។ ដូច្នេះក៏ ខ្ញុំនៅភូមិនេះ ក៏ខាងអង្គការ ពាក្យនឹងប្រើពាក្យអង្គការហើយ

អន្តការរណសិរ្សរួបរួមជាតិកម្ពុជានឹងបែកតាមរយៈភូមិ ។ យុំនឹងក៏ចាត់តាំងឲ្យខ្ញុំធ្វើមេភូមិ ធ្វើជាមេភូមិ ។

ដារ៉ា : ពីឆ្នាំណាមក អ៊ំធ្វើមេភូមិ?

ពត : ពីឆ្នាំ៧០ រដ្ឋប្រហារថ្ងៃ១៨ ខែ៣ ឆ្នាំ១៩៧០រដ្ឋប្រហារបាន ខែជេស្ឋ ខែ៣ ខែ៤ ខែ៥ ខ្ញុំធ្វើមេភូមិៗត្រពាំងទឹកនេះ ភូមិត្រពាំងទឹក ។

ដានី : ចឹងលោកតាដែលថាចូលជាមួយចលនាបដិវត្តនឹង ចូលពីៗថ្ងៃណាមក ពីថ្ងៃណា ខែណា?

ពត : អាថ្ងៃនឹងអត់ចាំទេ បើសរុប ខែចេត្រ ពិសាខ ជេស្ឋ ខ្ទង់ខែ៧ខែអីនឹងចូលនឹងណា ដល់ទៅឆ្នាំថ្ងៃ៣០នេះ ថ្ងៃ៣០ ថ្ងៃ១ ខែ១ ៧១ហ្នឹងគេធ្វើឲ្យខ្ញុំទៅធ្វើជាគណៈកៀរគរប្រមូលប្រជាជននៅឃុំពពេល ។

ដានី : ខែ១ ៧១ទៅធ្វើគណៈកៀរគរ?

ពត : ហ្នឹងហើយគេឲ្យឈ្មោះ គណៈកៀរគរប្រជាជន ពីតំបន់ប្រទុងប្រទាញក្បែរអន្តតាសោមជម្លៀសប្រជាជនពីនឹងមកក្រោយមក ។

ដារ៉ា : គណៈកៀរគរប្រជាជន?

ពត : បាទ!

ដារ៉ា : នៅភូមិអីគេ?

ពត : នៅឃុំពពេល ។

ដារ៉ា : ឃុំពពេល?

ពត : បាទ! ឃុំពពេល ស្រុកត្រាំកក់ ។

ដានី : ចុះគណៈកៀរគរនឹង លោកតាទៅក្រោយពេលធ្វើប្រធានភូមិត្រពាំងទឹក?

ពត : បាទៗ ដកពីខ្ញុំ ដកពីប្រធានភូមិនេះទៅ ។

ដានី : ចឹងតាំងពីចូលបដិវត្តភ្លាមមក អ៊ំត្រូវបានចាត់តាំងត្រូវធ្វើជាប្រធានភូមិ?

ពត : បាទ! កាលនឹងចូលបេះទេប្អូន ក្នុងករណីនឹងប៉ុនមិនចង់យល់អីទេ ប៉ុនគំនៀបពេលនឹងចលនានឹងវាមកហើយណា កាលណាយើងមិនចូលក៏គ្រោះថ្នាក់ដែរ ។ ហើយម្យ៉ាងចំពោះខ្ញុំដែលមានសមត្ថភាពតិចតួចប៉ុននឹងគេចាត់ទុកថាជាអនុធនសិស្ស ហើយបើឯងមិនចូលរួមគេថាប្រឆាំងនឹងបដិវត្ត ។ ដូច្នេះត្រូវតែ អានឹងវា ចឹងត្រូវសម្របខ្លួនទៅតាមអានឹង ។ ហើយដល់ថ្ងៃ៣០ខែ៩ ឆ្នាំ៧១ដដែល គឺដកពីពពេលនឹងមកវិញហើយ ។ ដកមកវិញ

ហើយ ដកមកវិញ ហ្នឹងថ្ងៃ៣០ខែ៩ខ្ញុំចាំច្បាស់នៅរដូវខែភ្ជុំ គឺថ្ងៃនឹងគឺខាងអង្គការស្រុកនេះហៅខ្ញុំមកឃុំពេលចាត់តាំងឲ្យខ្ញុំធ្វើប្រធានរណសិរ្សឃុំដាងទង ។

ដារ៉ា : ចុះកិច្ចការប្រធានរណសិរ្ស?

ពត : ឃុំដាងទង ។

ដានី : កិច្ចការនឹងធ្វើអីខ្លះទៅ?

ពត : បាទ! កិច្ចការនឹងធ្វើគ្រប់គ្រងលើមេភូមិ អឺ!លើប្រជាជនក្នុងឃុំទាំងមូល ។

ដារ៉ា : គឺមានន័យថា?

ពត : មេឃុំ ។

ដារ៉ា : យើងសម្រេចកិច្ចការគ្រប់យ៉ាងនៅក្នុងឃុំនឹងតែម្តង?

ពត : ក្នុងឃុំនឹងតែម្តង ប៉ុន្តែ ។

ដានី : ទាក់ទងនឹងបញ្ហានយោបាយ បញ្ហាសេដ្ឋកិច្ច បញ្ហាប្រជាជនលំនៅដ្ឋាន?

ពត : បាទ! ប្រជាជនលំនៅដ្ឋាននឹងយើងហើយ ។

ដានី : គឺនៅក្នុងប្រធានរណសិរ្សនឹងហើយ?

ពត : បាទ! រណសិរ្សនឹងហើយ ។ ប្រជាជនចុះមកពីក្រោម យើងមកប៉ុន្មានគ្រួសារ១០គ្រួសារ ២០គ្រួសារ យើងចាត់ចែងលោកមេភូមិនេះទៅទទួល៣គ្រួសារមករស់នៅជាមួយនេះៗ ចាត់ចែងជំនាន់នេះ គេសុទ្ធតែធ្វើចំការ ការងារ ។

ដានី : ចុះលោកតាពេលដែលយើងមានចលនាដំបូងកាលពីឆ្នាំ៧០ ដែលចាត់តាំងលោកតាធ្វើមេភូមិអីនឹង ដូចថាខាងណាដែលគេចុះមកចលនា?

ពត : ខាងចលនានឹងគឺនៅដំបូងគេនៅដាងទងនឹង គឺមិត្តមុំៗតាមរយៈនៅក្បាលអូរបងប្អូនអឿកបងប្អូនលោកអឿកនឹង គាត់ធ្វើមេឃុំ ។ ហើយដល់ហើយគាត់រួមការងាររបស់គាត់ការនឹងខាងលើការងាររបស់គាត់កាលនឹងខាងលើគេចុះមកដែររួមដើរចាត់តាំងមេភូមិ ។ក្រោយពីរដ្ឋប្រហារហើយ គេចាត់តាំងរដ្ឋអំណាចភូមិនឹងម៉ង ។

ដានី : ឈ្មោះដែលគាត់ធ្វើមេឃុំដាងទងកាលនឹង?

ពត : បាទៗ ទាហានរណសិរ្សឃុំ ។

ដានី : កាលនោះ ហើយអ្នកដែលមកពីខាងលើមកពីណាខ្លះ?

ពត ៖ គេខាងលើ ខ្ញុំមិនសូវស្គាល់គេប្អូន ប៉ុនឃើញដែលស្គាល់នឹងមានតាញ៉ែវ គាត់ស្លាប់ហើយ ហើយចេញពីព្រៃមកមានតាគៀវ ។ ប៉ុនតាគៀវនឹងគាត់ស្លាប់ដែរ ព្រោះវាថាគាត់ក្បត់ គាត់ស្លាប់ហើយ បើគាត់ស្លាប់ហើយតាគៀវ ដឹងប៉ុននឹងតាគៀវនឹង តាញ៉ែវ តាជឹម ។

ដានី ៖ គាត់អ្នកស្រុកភូមិយើងនឹងដែរ ឬមកពីណាវិញ?

ពត ៖ អត់ទេៗ ខ្ញុំអត់ស្គាល់ទេ តាគៀវនឹងដឹងនៅណាទេ បើតាជឹមស្រុកនៅត្រពាំងធំ គាត់គ្រូបង្រៀន ។

ដានី ៖ ចឹងកាលនឹងដូចថាពេលដែលពីឆ្នាំ៧០រដ្ឋប្រហារហើយ យើងកាលនឹងយើងមានរចនាសម្ព័ន្ធជាឃុំ ជាស្រុកអីហើយ ឬក៏មិនទាន់ទេ?

ពត ៖ មានហើយ ពេលនឹងគេចាត់តាំងមកចុះប៉ីបៗរាយនៅតំបន់ណាប្រទុងប្រទាញគេអត់ទាន់ចាត់តាំងបានទេ ប៉ុនចាត់តាំងបានពេលនោះ ខ្ញុំដឹងថាឃុំលាយបូ ឃុំពេលមានហើយណា ឃុំពពេល ដាងទង ហើយស្រែននោង អីនេះនឹង ។ ប៉ុនចាត់តាំងមានមួយៗជាបង្គោលនេះនឹង ។

ដានី ៖ គណៈស្រុកពេលនឹងពីណាគេ?

ពត ៖ គណៈស្រុកកាលនឹងអឺ!ខ្ញុំដឹង គេអត់ទាន់ទេនៅបិទនៅឡើយ ប៉ុនគ្រាន់ឃើញដើរៗធ្វើការនៅបិទ ។ អឺ! ឃើញកូនតាម៉ុកមួយ ស្រី ឈ្មោះយាយខុម ។

ដានី ៖ ឈ្មោះខុម?

ពត ៖ បាទ! ឈ្មោះខុម កូនតាម៉ុក ។

ដានី ៖ កាលនោះគេហៅស្រុកអីគេ?

ពត ៖ ស្រុកអឺ!ស្រុកត្រាំកក់នឹង គេហៅស្រុក១០៥ ។

ដានី ៖ ចឹងចាត់តាំងៗពីឆ្នាំ៧០មកដាក់១០៥?

ពត ៖ ដាក់ទៅឃើញថាដាក់១០៥ ស្រុក១០៥ ។

ដារ៉ា ៖ ឃើញចឹង?

ពត ៖ បាទ! ឃើញចឹង ។

ដារ៉ា ៖ យើងដឹងតាំងពីអឹ?

ពត ៖ ធ្វើការ បាទ! ។

ដារ៉ា ៖ ធ្វើការឆ្នាំ៧១?

ពត ៖ បាទ! ៧១ បាន ។

ដារ៉ា : ដីង១០៥?

ពត : យី! ចង់ភ្លេចហើយ ។

ដានី : ចុះអ្នកដែលចាត់តាំងអីឲ្យទៅជាគណៈកៀរគរប្រជាជនអីនៅឃុំពពេលអ៊ី អឺ!ខាងណាគេអ្នកចាត់តាំង?

ពត : ខាងនឹង អឺ!បងតាគៀវ ។

ដានី : តាគៀវ អ្នកចាត់តាំង?

ពត : បាទ! មកឲ្យខ្ញុំទៅប្រមូល និងមិត្តមួយប៉ុនគាត់ស្លាប់ដែរហើយ ឈ្មោះខឿននៅភូមិត្រពាំងធំនេះ ។

ដានី : តាគៀវ កាលនឹងគាត់តួនាទី គាត់ធ្វើអីទៅ?

ពត : សមាជិកស្រុក ។

ដានី : សមាជិកស្រុក?

ពត : បាទ!

ដានី : កាលអ៊ំទៅធ្វើគណៈកៀរគរប្រជាជននឹង ទៅប៉ុន្មាននាក់ដូចថាគេចាត់តាំងឲ្យទៅ?

ពត : ទៅពីនេះទៅ២ ។

ដានី : ២ អ៊ំមួយ?

ពត : ហើយនឹងពួកមិត្តខឿនមួយនៅត្រពាំងធំ ប៉ុនគាត់ស្លាប់ហើយណា ។ ទៅហើយដល់មានមនុស្សនៅនឹងកាលនឹង គេធ្វើរណសិរ្សស្រួលដែលប្អូន មិនមែនអ្នកធម្មតាដែរ ទៅយើងទៅពីទាយចឹងមិនមែននេះ គឺមានអ្នកស្រុកគេនៅនឹងមួយ មេឃុំជិនាន់សីហនុឈ្មោះតាខែងយើងគ្រាន់ទៅអែបជាមួយគេតែ២ កៀរគរប្រជាជន អានឹងគេហៅរណសិរ្សៗយកតាខែង ។ ដល់យូរទៅក៏តាខែងនឹងគេឲ្យឈប់ទៅ គេឲ្យខឿងនឹងទទួលខុសត្រូវរហូតមកហើយខ្ញុំមកជាងទងមក ។

ដារ៉ា : ចុះពេលរដ្ឋប្រហារសម្តេចព្រះនរោត្តសីហនុឆ្នាំ៧០ ខាងលន់ នល់ អត់មានមកគ្រប់គ្រងនៅនេះបានទេ?

ពត : អត់ទេ ។

ដារ៉ា : គឺថានៅតែក្នុងចលនា?

ពត : នៅតែក្នុង បាទ!ចលនានឹងម៉ាប្រឹបនឹង គ្រាន់រដ្ឋប្រហារហើយប្អូនដូចបាក់ទំនប់ម៉ង់ណាប្រឹបគឺតឹងតែងតិចនៅឃុំពពេលនឹង តំបន់ប៉ុន្មានភូមិដែលភូមិដែលប្រទង់ប្រទាញនៅក្បែរ

សាលាដើមចំបក់នឹង ។ ហើយបើក្រៅពីនឹងលិចៗនេះ គឺគេមកជម្លៀសមក អានឹងចឹង ។ ហើយឃុំតាភេម បានខាងលិចវត្តចំប៉ានឹងភូមិ ហើយយើងចេះដើរចាត់តាំងភូមិចឹង ។

ដារ៉ា : គ្រប់គ្រងដូចថាមានរដ្ឋអំណាច របៀបការចាត់តាំងអីមិនទាន់ច្បាស់លាស់នៅឡើង?

ពត : បាទ! មិនទាន់ច្បាស់នៅឡើយទេ ប៉ុនខបមាដូចខ្ញុំទៅជាគណៈកៀរគរទៅដល់ចាត់តាំងភូមិចឹងណា៎ បាទ! ។

ដានី : ចុះអ៊ឹដូចថារបៀបថា របៀបយើងជាគណៈកៀរគរ គោលនយោបាយពីខាងលើមកគេប្រាប់អ៊ឹមកថា យើងត្រូវធ្វើយ៉ាងម៉េចខ្លះដើម្បីកៀរគរប្រជាជន?

ពត : កៀរគរកាលនឹងរណសិរ្សរួបរួមជាតិកម្ពុជានឹង គឺអឺ!ប្រមូលរាល់ខោអាវ អឺ!អត់ទេប្រមូលនូវរាល់ស្មារតីស្នេហាជាតិទាំងអស់ ក្នុងនោះវាយរំលំរបបលន់ នល់, សេរីមតៈ, អ៊ិន តាំ, សួស គាន់, ឡុង បូរ៉េត និងចក្រពត្តិ ។ ហើយគេប្រមូលទាំងអស់នូវរាល់បណ្តាវណ្ណៈទាំងអស់ មានកសិករ កម្មករៗ អនុធន នាយទុនជាតិ ហើយនិងអ្នករដ្ឋការស៊ីវិល ឲ្យតែទាហានប៉ូលីស ឲ្យតែមានលក្ខណៈស្នេហាជាតិចូលរួមរណសិរ្សគឺទទួលទាំងអស់អានេះចឹង ។

ដានី : កាលនោះគេមកបង្រៀនអ៊ឹចឹង ឬក៏គេម៉េច?

ពត : គេហៅ មិននេះទេ ជួនណាគេចុះមកចឹង គោលនយោបាយហៅកម្មាភិបាលដូចខ្ញុំអ៊ីចឹងនៅក្នុង... គេហៅទៅរៀននៅព្រៃភ្នំ ។ ខបមាមិត្តខ្ញឿននៅពេលហៅមួយ ខ្ញុំជាធទងមួយមួយៗទៅបង្រៀនឯកសារនឹងមក ដល់មកយកមកអនុវត្ត ។ ប៉ុនហាមស្តីតាម៉ុកគាត់ប្រាប់ថាពេលនឹងដែលខ្ញុំរស់មកដល់ថ្ងៃនេះ ខ្ញុំនឹកឃើញសម្តីតាម៉ុក ។ គាត់ថា“ជីវិតមនុស្សមានតែអ្នកភូមិភាគទេ ដែលមានសិទ្ធិវិនិច្ឆ័យចំពោះជីវិតមនុស្ស ។ ឯចំពោះកម្មាភិបាលថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត បើកាលណាអ្នកឯងសម្លាប់មនុស្សម្នាក់ គឺជីករណ្តៅកប់ខ្លួនឯង ឲ្យហើយស្រេច ចាំធ្វើអី” ប្រកាសនៅពេលសន្និបាតឆ្នាំ៧២ ៧១ ៧២នឹងតាម៉ុក ។

ដារ៉ា : ចឹងមានតែភូមិភាគទេ?

ពត : បាទៗ ថ្នាក់ភូមិភាគ ហើយនឹងមជ្ឈិមទេ ដែលមានសិទ្ធិសម្រេចៗចំពោះជីវិតមនុស្ស ។

ដានី : ចឹងកាលអ៊ឹទៅរៀននឹង ទៅរៀនជាមួយតាម៉ុកៗអ្នកបង្រៀន?

ពត : ពេលមក តាម៉ុកអត់បានរៀបរាប់យូរទេ ជួនកាលទៅរៀន៣-៤សារជួបតាម៉ុកម៉ាពេលតិចៗ ហើយពេលជួបគឺនិយាយ ហើយគាត់ប្រាប់ថា “ប្រមូលឲ្យអស់ សាមគ្គីឲ្យបាន វ៉ៃឲ្យចំពីក្រោយសាមគ្គីឲ្យបាន ប្រមូលឲ្យអស់ វ៉ៃឲ្យចំពីក្រោយ” ។ ហើយគាត់លើទៀតគាត់ថា “បច្ចុប្បន្ននេះ អាមិត្តវាវាត់កន្ទុយយើងត្រូវកាត់ក្បាល ដាច់ខាតគាត់និយាយ” ។

ដារ៉ា ៖ អាមិត្តវាត់កន្ទុយ?

ពត ៖ មិត្តវាត់កន្ទុយ ។

ដារ៉ា ៖ មិត្តវាត់កន្ទុយ?

ពត ៖ យើងត្រូវកាត់ក្បាលវា ។

ដារ៉ា ៖ ចង់មានន័យថាម៉េច ចង់សំដៅលើ?

ពត ៖ មានន័យថាពេលនោះ យួនចង់ចាត់តាំងមេភូមិនៅតាមភូមិឃុំ ចឹងដល់កាត់ក្បាល គាត់និយាយបញ្ជាក់ទៀតថា "មិត្តទាំងអស់ មិត្តវាត់កន្ទុយហើយ វ៉ៃបែកនៅសមរភូមិណាមួយ វាឡងតែ....អាកាវាយកបានទាំងអស់ជាជយោភ័ណ្ឌ" គាត់ថា "ដូច្នេះ ដល់កាត់ក្បាល យ៉ាងម៉េចគាត់ប្រាប់ពន្យល់ ។ ចលនាប្រជាជនកុំលក់អង្ករឲ្យយួន" សម្ដីរបស់ពេលនឹងគាត់និយាយ ហើយក៏អនុវត្តនឹងទៅ ។

ដារ៉ា ៖ កាលនឹងចលនាអីនៅជាមួយ ដូចថាត្រូវជាមួយនឹងយួនអីដែរតើអ៊ំ?

ពត ៖ បាទ! អានឹងកងទ័ពចូលមក វាចង់ប្រជៀតចង់នេះនឹង វាមកតាមរយៈពួកមកពីហាណូយមួយចំនួន ។ ត្រង់កិច្ចការអីជ្រៅរាក់ទៀតមិនដឹងទេ ប៉ុនសម្ដីតាម៉ុកថាចឹង ហើយពេលនឹងអនុវត្តទៅ ។ ហើយចំពោះកម្មាភិបាលមកពីហាណូយមួយចំនួនវាចេះបាត់ខ្លួនតាមនឹងដែរ គ្រាន់៧០វដ្ដប្រហារហើយមានកម្លាំងមកពីហាណូយមក ។

ដានី ៖ ពេលដែលអ៊ំទៅប្រជុំនៅព្រៃភ្នំនៅម្ដុំណា ព្រៃភ្នំនឹង?

ពត ៖ អត់ទេ ប្អូនអត់ដឹងអត់យល់ត្រង់ណា ជួនកាលទៅចឹងនេះ ឆ្ងាយកណ្ដាលព្រៃមិនដឹងកន្លែងណាជាកន្លែងណា ប៉ុនពេលនឹងត្រូវតែរៀននៅក្នុងកណ្ដាលព្រៃភ្នំហើយ អត់មានរៀននៅនេះបានទេ ។

ដានី ៖ ភ្នំនឹងហៅភ្នំអីនឹង?

ពត ៖ ជួនកាលភ្នំ ដំរីរមៀល ជួនកាលហួសនឹងទៅណា ខ្ញុំវាមិនសូវដឹងដែរ ព្រោះឯងអត់ដែលស្គាល់ ។ គេអត់ឲ្យដឹង អត់ឲ្យស្គាល់ទៀត ។

ដានី ៖ ដូចតាម៉ុកគាត់មកបង្រៀនម្ដងម្កាល ។ ចុះអ្នកដែលមកបង្រៀនដូចជា?

ពត ៖ គណៈតំបន់ ។

ដានី ៖ គណៈតំបន់?

ពត ៖ តាម៉ុកអត់មានបានទៅឈរជើង តែនេះចូលមកបាន១ម៉ោង២ម៉ោងទៅទៀតហើយ ព្រោះកាលនឹងគាត់គណៈភូមិភាគកំពត ខេត្តកំពត ខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ។

ដារ៉ា ៖ ៤?

ពត ៖ ៤ បានម៉ាភាគនឹង ហើយគណៈភូមិភាគជំនាន់នឹងខ្ញុំដឹង ដូចតាម៉ុកលេខា បន្ទាប់មកជួ ជេតហៅតាស៊ី, ដឹង២នឹង ប៉ុន្មមួយទៀតមិនដឹងអ្នកណាទេ អត់ដឹង។ ហើយតាម៉ុក គាត់មកគាត់និយាយរឿង គាត់និយាយម៉ាត់។

ដានី ៖ អត់ស្គាល់តាកងចាប ហៅសែ?

ពត ៖ ដែលឮតែឈ្មោះ អត់ដែលបានឃើញមុខទេ។ បើតាជួ ជេតខ្ញុំឃើញ។

ដានី ៖ ចុះអ្នកដែលបង្រៀនអ៊ី?

ពត ៖ ខ្ញុំគឺតាសោម ចៅហ្វាយខេត្ត គណៈតំបន់គេហៅគណៈតំបន់ណា៎ ប្រើពាក្យគណៈទាំងអស់កាលនឹង។ តាសោម, តាមុត, មាស មុតនេះ។ មាស មុតនេះ គាត់ទើបចូលកងទ័ពដល់ចប់សង្គ្រាមហើយទេ កាលនឹងគាត់នៅជាលេខា១ខេត្តតាកែវ លេខាអ៊ី!នឹងមិនដឹងតាសោម តាមុត ហើយតាផែន។

ដារ៉ា ៖ ផែន កែវ ផែន?

ពត ៖ បាទ?

ដារ៉ា ៖ ផែន ឈ្មោះ កែវ ផែន?

ពត ៖ មិនដឹង កែវ ផែនអីទេ ខ្ញុំមិនដែលបាន។

ដារ៉ា ៖ ដឹងតែផែន?

ពត ៖ ដឹងតែផែន។

ដារ៉ា ៖ តែតាមុតនឹងគាត់គណៈតំបន់ ឬក៏អី?

ពត ៖ គណៈតំបន់៣នឹង។

ដារ៉ា៖ គេហៅតំបន់អី?

ពត ៖ តំបន់១៣។

ដារ៉ា ៖ តំបន់១៣?

ពត ៖ បាទ! តំបន់១៣។

ដានី ៖ តាប៉ៃ ផែន គាត់នៅជុំគីរីរាល់ថ្ងៃ?

ពត ៖ ហ្នឹងហើយ នៅជុំគីរី ប៉ុន្តែស្លាប់ហើយ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់?

ពត ៖ ហ៎! ស្តាប់យូរហើយ ស្តាប់គាំងពីជំនាន់ប៉ុលពត ជំនាន់វៀតណាមបុកមក ស្តាប់ហើយគាដែននឹងនោះ ។

ដានី ៖ ចឹងកាលនឹង អ៊ំដូចថាយើងទៅប្រជុំព្រៃភ្នំនឹង យើងមិនមែនទៅប្រជុំម្តងទេ ប្រជុំច្រើនដង?

ពត ៖ ម៉ាឆ្នាំទៅ២ដង ឬម៉ាឆ្នាំទៅម្តង គេហៅសន្និបាទបូកសរុបប្រចាំឆ្នាំ ហើយគេឆ្លងជីវទស្សន៍គណៈស្រុកមួយៗ គណៈឃោធាមួយៗអីចឹងទៅ ហើយយើងមេឃុំគ្រាន់ចូលរៀន ។ ប៉ុនករណីដែលចូលរៀនពេលខ្លះ ចាប់ពីថ្នាក់ស្រុកមក កងពលមក កងវរៈសេនាធំមក កងវរៈសេនាតូចអីមក កងរយមក មេឃុំមក ចៅហ្វាយស្រុកមកចូលរៀនជាមួយគ្នាចឹងទៅ ។

ដានី ៖ រយៈពេលប៉ុន្មានទៅម្តងៗ?

ពត ៖ ម្តងជួនកាលម៉ាអាទិត្យ ជួនកាលកន្លះខែដែរ ។

ដារ៉ា ៖ នៅក្នុងព្រៃនឹងម៉ង?

ពត ៖ បាទ! នៅក្នុងព្រៃនឹងម៉ង ។

ដារ៉ា ៖ កាលនឹងនៅក្នុងឆ្នាំ៧០ប៉ុន្មានដែរ?

ពត ៖ ខ្ទង់៧០ចាប់រៀន ៧២ ៧៣ ៧៤ អានឹង ។

ដារ៉ា ៖ ហើយកាលប្រជុំបំពាក់បំប៉ន គេហៅបំពាក់បំប៉នគោលនយោបាយនឹង?

ពត ៖ បាទ! គោលនយោបាយ ។

ដារ៉ា ៖ អានឹងមានយាយថែមអី តាទិតអីចូល?

ពត ៖ តាថែម តាទិតនឹងហើយសុទ្ធតែនឹងហើយ រៀនជាមួយគ្នា យាយថែមនឹងកំណើតគាត់នៅក្បាលអូរនេះដែរនឹង យាយថែម ហើយតាទិតនៅត្រពាំងធំនេះដែរ ប្អូនថ្លៃតាម៉ុកនឹង ។ ហើយចឹងរៀនជាមួយគ្នានឹង ហើយតាជីមចៅហ្វាយស្រុកនឹងអានឹងនៅនឹងដែរ រៀនជាមួយគ្នា ។

ដារ៉ា ៖ ចុះកាលនឹងដឹងថាយាយថែម តាទិតនឹងគាត់មានមុខនាទីអីដែរ?

ពត ៖ ដែលតាទិតនឹងគាត់សឹកពីបួសមក គាត់ធ្វើកូនប្រសារតានេះនឹង គាត់ជាបក្សជនធម្មតាសាមញ្ញនៅទេ មិនទាន់ឡើងតួនាទីជាស្រុកជាអីទេ នៅទេ ។ បើទៅស្រុកនឹងគ្រាន់តែទៅជាការងារគេទេអានឹងចឹង ។ ដូចតាសានអីប្អូនថ្លៃតាម៉ុក ពិតមែនមានងារជាស្រុកអត់បានទទួលជាលេខាគេ លេខាគេពីលើ ។ ដូច្នេះគ្រាន់អនុវត្តព្រោះមាគ៌ាសាមគ្គីភាព ឯកភាពផ្ទៃក្នុង

លក្ខន្តិកៈរបស់បក្សនឹង គឺថ្នាក់តូច ដែលបុគ្គលគោរពសមូហភាព ថ្នាក់ក្រោមគោរពថ្នាក់លើ បុគ្គលគោរពសមូហភាព ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមត្រូវគោរពថ្នាក់លើ បុគ្គល គោរពសមូហភាព។ ហើយម៉ាសាខាគ្នាសិទ្ធិសម្រេចទេ គ្រាន់មានសិទ្ធិស្មើដូចសាខា ហើយដូច្នេះរាល់ថ្ងៃចឹងបានជាប្អូនសួរខ្ញុំថា ស្វែងរកការពិតវាចឹងមែន ខ្ញុំក៏ចុញថប់ដែររាល់ថ្ងៃនេះ វាចង់ដឹងថាតើអ្នកណាអ្នកសម្លាប់ខ្មែរ បើនៅក្នុងឯកសារពាអនុសាខា បានមានឈ្មោះ ម៉ាសាខា ហើយម៉ាសាខានឹងគ្មានសិទ្ធិសម្រេចទេ។ បាទ! ក្នុងលក្ខន្តិកៈបក្សនិយាយ ហើយបក្សនឹងដល់អនុសាខា ម៉ាអនុសាខាមានបក្សជន៣នាក់ដល់ពេញសិទ្ធិ ហើយពាអនុសាខាវាមាន៩នាក់ ដល់៩គុណនឹង៣ ២៧នាក់បានមានសិទ្ធិសម្រេចចេះចឹងរាល់នេះនឹង ការសម្លាប់មនុស្សវាពិបាកយល់ម៉ង់មិនដឹងវា។ អានឹងខ្ញុំប៉ុននៅក្នុងឯកសារដែលខ្ញុំបានរៀន ហើយខ្ញុំរស់មកដល់ថ្ងៃនេះ បកប្រែខ្លួនឯងត្រង់ឯកសារទង់ក្រហមគឺថាអនុវត្តកុំឆ្វេងកុំស្តាំ ធ្វើម៉េចកុំឲ្យឆ្វេងកុំឲ្យស្តាំ។

ដារ៉ា : ចឹងមានន័យថាពេលអនុវត្តគោលនយោបាយអី កម្មាភិបាលថ្នាក់ក្រោមមើលតាមទស្សនាវដ្តីទង់បដិវត្តនឹង?

ពត : ទង់បដិវត្តនឹង កុំឆ្វេងកុំស្តាំម៉េច ចឹងបានខ្ញុំវាពិបាក ឧទាហរណ៍ថាកំណត់ដីកប្រឡាយ អានោះកំណត់ពីលើម៉ោង១ ប៉ុនខ្ញុំម៉ោង២ឲ្យចុះក៏មានដែរ ម៉ោង១កន្លះបានឲ្យចុះសួរថាហេតុអី នេះមិនឆ្វេងបើម៉ោង១ក្តៅចេះឲ្យចុះទៅ កសិករយើងទាំងអស់ក្តៅបែកញើសឡើងមកខ្យល់ អត់ទេ ម៉ោង១កន្លះវាមេឃត្រជាក់ទៅតាធម្មតាជាតិ មិនផ្អែកត្រូវផ្អែកទៅតាមធម្មតាផង ពិតមែនតែមាគ៏ាខាងលើដាក់មកម៉ោងមួយ ប៉ុនអ្នកឯងជំរុញម៉ោងមួយចុះម៉ាប្រឹបឈឺឡើង១០-២០នាក់វាគ្រោះថ្នាក់ដែរ ចឹងវាឈឺទៅតាមនឹង។

ដារ៉ា : ចឹង ខ្ញុំចង់សង្កត់ធ្ងន់ត្រង់ថាគោលនយោតាមទង់បដិវត្ត?

ពត : បាទៗ ។

ដានី : ចឹងអ៊ំទទួលបានសៀវភៅបដិវត្តនឹងជាទៀងទាត់ឬក៏យ៉ាងម៉េច?

ពត : អានឹងនៅក្នុងពេលដែលមិនទាន់ចប់សង្គ្រាមអត់បានជាទៀងទាត់ទេ កម្របញ្ចេញណាស់ដល់ពេលចប់សង្គ្រាមហើយបានមានចុងក្រោយនេះ ៧៨ ៧៩ ។

ដារ៉ា : មានជាទៀងទាត់ចឹង?

ពត : បាទ! ជួនកាល៣ខែ គេឲ្យ មិនទៀងទាត់ទេ ៣ខែឲ្យទៅតាមឃុំ ហើយយើង។

ដារ៉ា : ហើយចឹងអ៊ំនៅពេលទទួលបានទង់បដិវត្តគឺ អនុវត្តទៅតាម?

ពត ៖ បាទ! យើងមើល ៗ ។

ដារ៉ា ៖ មើលនៅក្នុងនឹងម៉ង?

ពត ៖ បាទ! មើលហើយហៅកម្មាភិបាលថ្នាក់របស់ខ្លួន មានមេឃុំ មានយុវជនអីនៅក្នុងមូលដ្ឋាន មានពេទ្យមានអីមកហៅ យើងសិក្សាឲ្យគេធ្វើម៉េចចៀសវាងអនុវត្ត ពីព្រោះខ្វាចបំផុតអា ដុតឲ្យខ្លោច រោលឲ្យឆៅ...។

ដានី ៖ ដុតឲ្យខ្លោច រោលឲ្យឆៅ មានគេសរសេរនៅក្នុងទង់បដិវត្ត ឬក៏យ៉ាងម៉េច?

ពត ៖ អត់ទេ គំនិតខ្ញុំយល់ទេ ធ្វើម៉េចកុំដុតឲ្យខ្លោច រោលឲ្យឆៅ កុំរោលឲ្យឆៅ។ បានន័យបើ ឆេះខ្លាំងពេក បើម៉ោង១នឹងវាក្តៅធម្មជាតិក្តៅ យើងចេះតែរុញគ្នាអាងតែយើងមាន អំណាចរុញឲ្យគេទៅដឹកប្រឡាយនេះទៅ វាខ្យល់វាក្តៅវារងារកាលណាគ្រោះថ្នាក់ យើងនេះ ជាអ្នកសម្លាប់មនុស្សវាប៉ះពាល់ជីវិតខ្លួនឯងទៀត អានឹង ។/

ដារ៉ា ៖ អឺ! ចឹងសម្រាប់អឺ នៅពេលនឹងទង់បដិវត្តនឹង គឺជាមាគ៌ាសម្រាប់អឺដើរតាម?

ពត ៖ ដើរតាម វិភាគតាម ។

ដារ៉ា ៖ នៅក្នុងសម័យខ្មែរក្រហមហ្នឹង?

ពត ៖ បាទ! សម័យខ្មែរក្រហម ។ ហើយអាទង់អីទង់បេ្តជ្ញាទង់នេះ អ្នកណាចង់បាន ចង់ទៅ ខ្ញុំ គ្រោះថ្នាក់ដែលអូន ទៅនៅកៀនស្វាយគ្រោះថ្នាក់តើ ។ គេបន្ថយសិទ្ធិវិស ១ នឹងផាប់ដែល តើ អាហ្នឹងចង់និយាយប្រពន្ធខ្ញុំទៅ (សើច) ។

ដារ៉ា ៖ ចឹងនៅក្នុងហ្នឹងមាន ដូចអ៊ំអាទង់ជ័យជំនះទង់អីហ្នឹង នៅក្នុងគ្រាំកក់ហ្នឹងដូចបានទទួល?

ពត ៖ មាន ប៉ុន្តែខ្ញុំចេញទៅស្រុកគេហើយ ចេញទៅស្រុកគេហើយ ខ្ញុំអត់មាននេះទេ ។ ហើយបើ ខ្ញុំទៅនៅនោះកៀនស្វាយ ដែលខ្ញុំអឺ!នៅឃុំកំពង់ស្វាយ បើបានទៅស្រាវជ្រាវប្រវត្តិខ្ញុំ ទៅ សួរស្រុកហ្នឹងដឹងហើយ ។ ខ្ញុំធ្លាក់កូដពីលេខានឹង គេចង់ដំឡើងទៅស្រុកអីណាទៀត ខ្ញុំដឹងខ្លួន ពីព្រោះឃើញមាគ៌ានេះ ប្រជាជនក្រៅបក្ស ប្រជាជនក្នុងបក្ស ប្រជាជនរបស់ បក្ស ប្រជាជនត្រៀមពេញសិទ្ធិ ផ្ញើ ខ្ញុំថាត្រូវដល់ហើយ ។

ដានី ៖ អឺ!

ពត ៖ ឡាកបណ្តោយ ឡាកនេះដល់ខ្លួនខ្ញុំហើយ ខ្ញុំចែកអំណោយឲ្យប្រជាជននៅនឹង ឲ្យក្រមាឲ្យអី ទៅ ។ ដល់កម្មាភិបាលនៅក្រោមថ្នាក់របស់ខ្ញុំ គេអ្នកដឹកនាំជាមួយខ្ញុំ គេចង់បានបុណ្យសក្តិ គេថាឯងយករបបសីហនុចែកក្រមាឲ្យគ្នាទៅការដ្ឋានទៅអីនឹង ។ ខ្ញុំអត់ទេធ្វើអន្តុយមុខផាប់

គេទម្លាក់ឲ្យមកជាសមាជិកសាខា មកនៅឃុំបឹងខ្យាង ។ អានឹងខ្ញុំចង់និយាយប្រវត្តិខ្ញុំណាស់ ។

ដានី : បាទ ។

ពគ : ពីព្រោះខ្ញុំមានឈ្មោះជាធាតុអនុធនដែរ បើខ្ញុំមិនអេះទេ ងាប់តែម៉ង ងាប់ បើខ្ញុំភ្លៀវតែបន្តិចក៏គ្រោះថ្នាក់ដែរ អានឹងជីវាបត្រង់ចឹង ។

ដារ៉ា : ចឹងនៅពេលដែលអ៊ំបានមកធ្វើគណៈ អ៊ី!ប្រធានរណសិរ្សឃុំដាងទង់អីចឹងទៅ អ៊ំកៀរគររហូតដល់ឆ្នាំណា?

ពគ : ដែលកៀរគររហូតហ្នឹងចេះអូន ពេលហ្នឹងៗចេះដឹកនាំរហូតទល់៧៥ ។ ៧៥ចប់សង្គ្រាមគេដកខ្ញុំឲ្យទៅនៅឃុំទៅកៀនស្វាយស្រុកកៀនស្វាយ ខេត្តកណ្ដាលទៅទទួលខុសត្រូវនៅឃុំកំពង់ស្វាយ ។

ដារ៉ា : ចឹងអ៊ី!ម៉ាកំឡុងពេលនៃចលនា បន្ទាប់ពីរដ្ឋប្រហារមករហូតមកដល់ឆ្នាំ១៩៧៥ហ្នឹង ជាចលនាខ្មែរក្រហមចឹងអ៊ំនេះ?

ពគ : ដែលរបៀបជាចលនាខ្មែរក្រហម ។

ដារ៉ា : ចឹងនៅក្នុងចលនាអំឡុងពេលហ្នឹងគឺអ៊ំទទួលការអប់រំ ការបណ្ដុះបណ្ដាលបំពាក់បំប៉នគោលមាគ៌ា នយោបាយស្អីហ្នឹង គឺនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុកទាំងអស់ឬក៏អី?

ពគ : ដែលនៅក្រោមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ និយាយរួមមួយម៉ាត់ចឹងទៅ គឺបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ។

ដារ៉ា : ដែលមានអ្នកគ្រប់គ្រងធំជាងគេគឺតាម៉ុក ចង់និយាយចឹងនៅក្នុងបក្ស?

ពគ : អត់ទេ អូនអត់ទាន់ដឹងទេ តាម៉ុកហ្នឹងមានឈ្មោះ ម៉ុកជង តា១៥ជង ឈ្មោះតាប៉ូចជងអត់ទាន់ដឹងទេ ។ ដឹងតែមួយហ្នឹងចំពោះប៉ុល ពត, ចំពោះអៀង សារី ដល់អីនឹងដល់នេះឮឈ្មោះតានេះទេ ។ បើនិយាយពីលក្ខណៈនេះ គេឲ្យដឹងប៉ុន្មាន ដឹងប៉ុណ្ណឹងទេ អត់អ្នកណាហ៊ានតែសួរថា អូនអើយអ្នកដឹកនាំនេះអត់ទេ គេតាមដានយើងទៀត ។ ដឹងដូចច្នេះពេលនឹងដឹងប៉ុន្មាន ឃើញប៉ុន្មានថាប៉ុណ្ណឹង ចឹងខ្ញុំដឹងថានៅ១៣ហ្នឹងមាន តាសោម, មានតាមុតហើយនឹងតាដែន ពេលបើកវគ្គម្ដងៗហ្នឹង ។ តែតាម៉ុកហ្នឹង ខ្ញុំចាំសម្ដីគាត់ នៅពេលទៅរៀនបីបួនដង ជួបគាត់ម្ដងចឹង គាត់ប្រាប់ ។

ដារ៉ា : គាត់និយាយនៅក្នុងអង្គប្រជុំធំតែម្ដង?

ពត ៖ នៅពេលសន្និបាទហ្នឹងតែម៉ង ចូលមកមួយភ្លេត ឬកន្លះម៉ោងគាត់ប្រាប់ចឹង គាត់ថាប្រយ័ត្ន ណាស់ ហើយគាត់ថាឲ្យតាសោម តាមុតទៀត។ នែក!លោកគ្រូសោម គ្រូមុតនឹងណា៎ ខ្ញុំមកស្រគៀលក្បាល ប្រជាជនប្រាប់ថាកាចណាស់ លោកឯងទៅសុំទោសប្រជាជនទៅ។

ដារ៉ា ៖ ថាចឹងទៀត?

ពត ៖ ថាចឹង ហើយប្រាប់កម្មាភិបាលទាំងអស់កុំរៀនតាម គ្រូសោម គ្រូមុតណាស់។ ដូចច្នេះ វិនិច្ឆ័យជីវិតមនុស្ស គណៈភូមិភាគទៅគណៈមជ្ឈឹម។ ឃុំ ស្រុក ខេត្តគ្មានសិទ្ធិសម្រេចទេ គ្មានសិទ្ធិវ៉ៃគេចោលទេ។ ហើយគាត់ថា ដាច់ខាតអាហារឲ្យគ្នាកូនកសិករក្រ។ ដូច្នេះទៅ រស់នៅជាមួយនេះ គ្មានដូចថាគ្មានជីវភាពហូបគ្រប់គ្រាន់យកស្រែទៅបញ្ចាំ យកលុយទៅសូកធ្វើអាហារនេះ។ ឥឡូវខ្ញុំមករស់នៅជាមួយយើងហើយ កុំដែលសមាសភាពអន្តរាយ ឃើញគ្នាអាហារ ហើយចេះតែតាមពីមុខពីក្រោយ ឲ្យគ្នាគេរស់នៅមិនកើត អានេះសម្តីគាត់ដែលនិយាយណា៎។ ហើយខ្ញុំអនុវត្តតាមសម្តីគាត់ហ្នឹង ហើយដែលខ្ញុំបានរស់មកដល់ថ្ងៃនេះ ដែលគេមិនវិនិច្ឆ័យខ្ញុំ ជំរាបអូនឯងត្រង់ប៉ុណ្ណឹង មិនមែនមោទនអីទេ ប៉ុនសម្តីមិនភ្លេច។

ដារ៉ា ៖ បាទ! ចឹងមុនចប់សង្គ្រាមដែលថាមុនឆ្នាំ៧៥ហ្នឹង?

ពត ៖ បាទ។

ដានី ៖ ចឹងខ្មែរក្រហមមិនទទួលបានជោគជ័យ ថ្ងៃ១៧មេសាឆ្នាំ១៩៧៥អ៊ី?

ពត ៖ បាទ។

ដានី ៖ ចឹងមុនហ្នឹងមួយខែ ឬមួយអាទិត្យអី វាមានព្រឹត្តិការអីទេនៅក្នុងភូមិឃុំអ៊ី?

ពត ៖ អត់ទេអូន។

ដារ៉ា ៖ មានផែនការប្រាប់យ៉ាងម៉េចៗអីទេ?

ពត ៖ អត់ទេ ប៉ុនពេលហ្នឹងខ្ញុំសូមជំរាបចេះសមាភាពការណ៍។

ដានី ៖ បាទ។

ពត ៖ សៃលស្រួចស្រាវបំផុតចំណុចសម្លាប់រស់ រវាងចក្រពត្តិប្រជាជនកម្ពុជា ហើយដែលវាផុស ឈានទៅបើកមុខខ្ញុំ យកជ័យជំនះថ្ងៃ១៧ប្អូន។

ដានី ៖ បាទ។

ពត ៖ ប្អូនយល់ទេ អាបេវ៉ៃ វ៉ៃម៉ាដួរភ្នំ វ៉ៃៗហើយនៅវត្តតាសូវវ៉ៃ។ ចឹងកំហឹងប្រជាជនដែលវាផ្ទុះកញ្ជ្រោលឡើងពេលហ្នឹងគឺដាច់ខាតហើយ មួយវិនាទីស្លាប់មួយវិនាទីរស់ទៅតែម្តង។

ដល់ពេលនេះ អាបេឈប់វៃអាស្លាប់កាត់ស្លាប់អីទុកជារឿងធម្មតា ទុកជារឿងធម្មតាទៅ ចឹងហើយបានទៅ ។

ដានី : បេ៩២?

ពត : បេ៩២វៃខ្លាំងណាស់ វៃប៉ុន្មានថ្ងៃខ្ញុំវាភ្លេចទៅ ។

ដារ៉ា : ទម្លាក់តែម្តង?

ពត : ទម្លាក់គ្ទុង១១ទៅម៉ង ហើយនឹងអាបូម អាបូមនិងធ្លាក់មកមួយគ្រាប់ប៉ុនត្រពាំងនេះ ប៉ុនឡូត៍នោះ ។ ចឹងហើយបានជាខ្ញុំជំរាបថា ដុនដង់ប្រជាជនដែលបានហូបណាស់ ច្រើនជាងដុនដង់ដែលយើងបានឃើញ និងរើសទុក ។

ដារ៉ា : ដុនដង់យ៉ាងម៉េចទៅ ស្អីគេ ខ្ញុំអត់យល់ពាក្យហ្នឹង?

ពត : សុំទោស ។

ដានី : បាទ ។

ពត : ដុនដង់ដែលបានរើសទុក ដែលទួលស្លែង លលាដ ក្រាំងតាចាន់ លលាដរបស់អ្នកស្លាប់ឯដុនដង់ ហើយប្រជាជនបានហូបច្រើនជាងដុនដង់ ដែលបានរើសទុកបានន័យថាអាគ្រាប់ បែកទម្លាក់អាបេ ទម្លាក់អាបូម ទម្លាក់ជ្រៅជាងហ្នឹងទៀតអូន ។ អាលុប អាលាយអស់ ហើយវេទនារបស់ប្រជាជន ការស្លាប់រស់ ដេកយប់ឡើងគឺគ្មាន ។ ចឹងបានបងរកដាក់ កំហុសមួយពេលនេះមិនដឹងយ៉ាងម៉េច មានតែអន្គុយហូរទឹកភ្នែក ។

ដារ៉ា : ចឹងមានន័យថាពេលដែលជិតបែកអាឆ្នាំ៧៥ហ្នឹង ដោយសារការទម្លាក់គ្រាប់បែកខ្លាំងអីចឹងនោះ?

ពត : បាទ១ ។

ដារ៉ា : មានការវាយសម្រុកម៉ាគេហៅ ភាសាខ្មែរយើងថាមួយចំអិនកំពឹស?

ពត : បាទ ។

ដារ៉ា : រយៈពេលខ្លះវាកំហុកខ្លាំងតែម្តង?

ពត : បាទ! កំហុកខ្លាំងម៉ង តែដល់ពេលអស់អាបេហើយ អូន ។

ដានី : បាទ ។

ពត : ពេលហ្នឹងសម្រុកចូលបណ្តោយ ហើយសម្រុកចូលហ្នឹងខ្ញុំសួរ ខ្ញុំមិននេះទេ ខ្ញុំនៅសមរភូមិក្រោយទេ ។

ដានី : បាទ ។

ពត ៖ ប៉ុនសួរកង់ទ័ពពេលហ្នឹង ដែលដាច់ខាតអាបេរីខ្លាំងហ្នឹង បើនៅពីក្រោយអាបេរីចំ ចុះសមរភូមិ ទាហាន កន្លែងទីតាំងរុញចូលឲ្យកៀក ។

ដារ៉ា ៖ ចឹងចូលកៀកទាហានតែម៉ង?

ពត ៖ ចូលកៀកទាហាន បើកបុកឈាមងាប់ក៏ងាប់ទៅ មិនងាប់បើឯងទម្លាក់បេ ងាប់ទាំងឯង.... ក្រងាប់ ។ ដល់ពេលនឹងហើយរត់បុកហើយ ។

ដារ៉ា ៖ នេះ យុត្តិសាស្ត្រមួយដែរ?

ពត ៖ បាទ! យុត្តិសាស្ត្រមួយដែរ ។

ដារ៉ា ៖ អានឹងគេហៅយុត្តិសាស្ត្រទាហាន អ៊ំ?

ពត ៖ បាទ! ទាហាន អានឹងយើងសួរវា សួរយុទ្ធជន ។

ដារ៉ា ៖ ចឹងពេល ចឹងអ្នកស្រុកអ្នកភូមិដូចថាមានអារម្មណ៍ថាជិតបានរំដោះ ជិតបាន?

ពត ៖ បាទ! ពេលនឹងវាចេះ សភាពការណ៍គ្រាន់ហុចឲ្យ ម៉ាពេលនឹងសង្ស៊ឹមពីនេះទៅ តាកែវនៅតែទីរួមខេត្តតាកែវប្អូនណា ។ ពីត្បូងមកទម្លាប់មកទីតាំងយោធាអស់ហើយ នៅរួមតាកែវទេ ទីក្រុងតាកែវណាទេ ។ ពីនឹងទៅត្រាំខ្នារ ទៅកំពង់កន្ទួតអស់កន្លែងទីតាំងយោធា មានតែទីក្រុងភ្នំពេញ ។ ចឹងអាជ័យជំនះនឹងវាឃើញ ប្រជាជនរក ហើយយើងនៅក្រោយនេះជីកប្រឡាយ ទំនប់នេះទៅ ។

ដារ៉ា ៖ ចឹងអី! ចំពោះថ្ងៃ១៧មេសា៧៥ម៉ង ដែលថាបែកភ្នំពេញម៉ង នៅក្នុងភូមិអ៊ំមានសភាពការណ៍យ៉ាងម៉េចដែរ ហើយអារម្មណ៍ប្រជាជនពេលនឹងយ៉ាងម៉េចដែរ?។

ពត ៖ ប្អូនឯងសួរនឹង(សើច) ខ្ញុំសើចតិចចុះប្អូន សូម្បីតែខ្លួនខ្ញុំក៏អត់ដឹងដែរទេ អត់មានវ៉ាដ្យូស្តាប់ទេ ។ អត់ទេ ប្អូនគ្រប់ផ្ទះទាំងអស់គ្នាទេ កម្មាភិបាលដូចខ្ញុំ កាលណាបើឯងមានវ៉ាដ្យូស្តាប់គេថាកម្មសិទ្ធិអត់បានទេ អត់បាន ។ ប៉ុន្តែជាពិសេស គេដាក់កម្មសិទ្ធិម្យ៉ាង ប៉ុនហាមឃាត់មិនឲ្យ បើកាលណាយើងមានវ៉ាដ្យូ យើងអាចបើកស្តាប់អាមេរិចកាំង យើងអាចបើកស្តាប់ ប៉ុស្តិ៍នេះប៉ុស្តិ៍នោះ បើមានអត់ទេ ។ ចំពោះខ្ញុំមួយអត់ម៉ង ដឹងអាកន្លែងនឹង កន្លែងងាប់ខ្ញុំមិន ក្រាបដល់ម៉ោង២ ម៉ោង៣បានប្រកាស មកនឹងបានដឹងចឹងទៅស្តាប់គេ ស្តាប់តាមវិទ្យុ គេមានវិទ្យុ គេប្រាប់ចឹងទៅបានគេប្រាប់ ។

ដារ៉ា ៖ ថ្នាក់ណាមានវិទ្យុ?

ពត ៖ វិទ្យុថ្នាក់ស្រុក ហើយឃុំកន្លែងខ្លះគេមាន ប៉ុនខ្ញុំសម្រាប់ខ្ញុំអត់មានម៉ង ។

ដារ៉ា ៖ ចឹងរហូតដល់ម៉ោង២ ម៉ោង៣បានដឹងថា?

ពត ៖ បានដឹង ។

ដារ៉ា ៖ ដឹងថា?

ពត ៖ ទទួលជ័យជំនះ ។

ដារ៉ា ៖ ទទួលជ័យជំនះ?

ពត ៖ បាទ! ទទួលជ័យជំនះ ។

ដារ៉ា ៖ ហើយពេលនឹងដូចថាមាន អីមានអារម្មណ៍សប្បាយរីករាយ ឬក៏យ៉ាងម៉េចដែរ ពេលនឹង?

ពត ៖ អត់ទេបង ខ្ញុំនិយាយស្មោះត្រង់ មិនប្រឡោត មិនចេះ មិនណាស់ណាដែរឃើញសភាព ព្រោះបងមួយនៅទីក្រុង ខ្ញុំពេលនឹងវល់វក់វិញ ។ ហើយខ្ញុំនៅនេះជាអនុធន គេកំណត់អនុធនច្បាស់លាស់ ។ គេកម្រិតខ្លួនត្រូវតែស្លាប់ បងខ្ញុំមួយនៅជំទុកលេខ៣នៅសង្កាត់លេខ៦ ក្នុងទាហានក្នុងសម័យលន់នល់គេថាឲ្យពាក់សក្តិប៉ុន្មាន ចេញមកគេយកទៅគុក២០៨នេះ ។

ដារ៉ា ៖ គុក២០៨?

ពត ៖ បាទ!

ដារ៉ា ៖ គុកកន្លែងណា?

ពត ៖ ២០៨នៅត្រង់ បច្ចុប្បន្នគេហៅវត្តស្ទឹលិចទេ អត់ទាន់បានជួបមុខបងផង គេយកទៅនឹងបាត់ទៅ ។ ប៉ុនបានខ្ញុំដល់នេះទៅមកម្តាយ ខ្ញុំប្រាប់ខ្ញុំមកពីរៀនវិញៗ គាត់ទៅប្រាប់តាជឹម ហើយទៅប្រាប់តាសោម គាត់ក៏ អឺ!ប្រាប់យាយខុម កូនតាម៉ុកនឹងទៅក៏គេអនុគ្រោះឲ្យខ្ញុំ នឹងនាំប្រពន្ធគាត់ឲ្យទៅនៅជាមួយគាត់២០៨ គុក២០៨ រាល់ថ្ងៃគេហៅវត្តស្ទឹ វត្តព្រៃក្តួច ជិតវត្តព្រៃក្តួច ។

ដារ៉ា ៖ ក្នុងនឹងភូមិអី ឃុំអី?

ពត ៖ ស្រុកឃុំព្រៃក្តួចនឹង នៅអូរសារាយ មិនមែនអូរសារាយទេ ត្រពាំងក្រញ៉ូង ។

ដារ៉ា ៖ ភូមិ?

ពត ៖ មិនដឹងភូមិអីទេ ប្អូន ព្រោះបងអត់ដឹងដែរកាលនឹង ប៉ុនដឹងថាទៅនៅនឹង ជិតវត្តអង្គសង្កែៗ ។

ដានី ៖ ស្រុកត្រាំកក់យើងដែរ?

ពត ៖ ស្រុកត្រាំកក់ៗ ។

ដារ៉ា ៖ អឺ! ចឹងអាគុក២០៨នឹងវានៅក្នុង នៅក្បែរគេហៅវត្តព្រៃក្តួចចឹង?

ពត ៖ បាទ! វត្តព្រៃក្ដួច ។

ដារ៉ា ៖ ហើយនៅក្បែរវត្តអង្គសង្កែ?

ពត ៖ បាទ!

ដារ៉ា ៖ តែអត់ដឹងនៅក្នុងភូមិអីឃុំអីទេ?

ពត ៖ បាទ! អត់ដឹង ។

ដារ៉ា ៖ មិនមែននៅឃុំដាងទងយើងនេះទេ?

ពត ៖ មិនមែនទេ ។

ដារ៉ា ៖ មិនមែននៅក្នុងស្រុកត្រាំកក់ទេ?

ពត ៖ បាទ! ហើយកាលនឹងអត់ទាន់មានឃុំទេ ត្រពាំងក្រញ៉ូងមិនឡូយ ទើបឥឡូវនឹងទេ កាលពីដើមនៅក្នុងឃុំត្រពាំងធំខាងជើង ហើយដីនឹងវានៅឃុំបឹងស្រងែ៎ៗ ។

ដារ៉ា ៖ អូ!

ពត ៖ ឃុំបឹងស្រង៉ែៗ ស្រុកត្រាំកក់ចឹង កាលនឹង ឃុំបឹងស្រង៉ែចឹងហើយ ។

ដានី ៖ ចុះម៉េចទៀតទៅ?

ដារ៉ា ៖ ចុះពីអារម្មណ៍អ្នកស្រុកអ្នកភូមិអីយ៉ាងម៉េច អាពេលដែលបែកភ្លាម?

ពត ៖ បែកភ្លាម ប្អូនត្រូវយល់ ចឹងបានខ្ញុំអីនឹង ប្អូនឯងក៏មានបងនៅភ្នំពេញ ខ្ញុំក៏មានបងនៅភ្នំពេញមិនធម្មតាទេប្អូន អត់ហ៊ានយំចំពោះមុខ ប៉ុនទឹកភ្នែកត្រូវពេលនឹង ។ ចឹងបានជាខ្ញុំខឹងនឹងអ្នកដែលមួយចំនួននេះ គាម៉ុកប្រកាសនៅភ្នំត្រែ ចាប់ពីសក្តិ៥ឡើងទៅអត់ឲ្យប៉ះពាល់ជីវិតទេណា ។ ក្រោយពីបែក ប៉ុនសម្តីនឹង គាត់អត់មកភ្លាមទេ ខែ១៣ ខែ៤ ខែ៥វិលង ម៉ាខែ ប្រកាសទៅ ។ ហើយដល់ហើយគាសោមគណៈតំបន់ប្រកាស ហៅកម្មាភិបាលទាំង អស់ទៅរៀនភ្នំត្រែ ទាំងមេទ័ពទាំងអី ។

ដារ៉ា ៖ ភ្នំអីគេ?

ពត ៖ បាទ! ភ្នំត្រែ តាទី ។

ដារ៉ា ៖ ភ្នំត្រែ នៅស្រុកតាទី?

ពត ៖ តានី ប្រកាសថាចាប់ពីសក្តិ៥ឡើងទៅ គឺដាច់ខាត អត់ប៉ះពាល់ជីវិតគេទេ ។ មាត់កាលពេលនឹង ប៉ុនក្រោយមកគេប្រែក្រឡាសយ៉ាងម៉េចមិនដឹងទេ ប៉ុនពេលនឹងគឺ ។

ដារ៉ា ៖ ហើយអី! ក្រោយមកទៅអ៊ឹ បាទ!ចឹងពេលដែលមានអី!បែកភ្នំពេញអីចឹង អ្នកនៅខាងនេះបែរជាមានអារម្មណ៍ភិតភ័យវិញ ដោយសារវន្ធត់ ដោយសារមានបងប្អូននៅខាងក្នុង?

ពត ៖ ចុះមានបងប្អូនមកចូលចលនា សូម្បីតែខ្ញុំ បងខ្ញុំមកគាត់ចេញទៅៗខាងជើងវិញ ទៅរហូតគាត់ថាកំពុងធំ ទៅកន្លែងណាទេ ដល់ពេលគេរុញគាត់ឲ្យទៅនៅខាង អានេះនិយាយសភាពការណ៍ពេលនឹង ហើយគាត់ក៏២នាក់ប្ដីប្រពន្ធវែក សង្រ្រៃៗនេះមកវាងភ្នំពេញមក ។ មកៗដល់នេះ មកដល់ផ្ទះខ្ញុំ ខ្ញុំនៅភូមិអត់បានឃើញផង ទទួលដឹងថាបងមក គេហៅទៅរៀន ។ ដល់មកវិញ សម្រាប់តែបញ្ជូនទៅនោះទៅ ។ ហើយដល់ខ្ញុំដោះស្រាយបញ្ហានឹងហើយ ក៏អង្គការដកខ្ញុំទៅកៀនស្វាយនឹងទៅ ។ ហ្នឹងមកចឹង ចង់និយាយថា ពេលនឹងអ្នកដែលគេសប្បាយ ចំពោះដែលអ្នកមិនបានជាគិត ចំពោះដូចថាគេមុខមាត់គេ បុណ្យសក្តិគេធ្វើ ។ ប៉ុនចំពោះដូចខ្ញុំមួយរួមជាមួយបងប្អូនយើង ប៉ុនអត់ហ៊ាននិយាយគ្នាទេ ។ ប៉ុនខ្ញុំជឿថាភ័យអាណិតអាសូរបងប្អូន ប៉ុន ។

ដារ៉ា ៖ ចឹងអី! ក្នុងខែណាបានអ៊ីត្រូវបានចាត់តាំងឲ្យទៅកៀនស្វាយ?

ពត ៖ ដែលថ្ងៃនេះទៅអស់ អឺ!មើលចូលឆ្នាំទៅចូលឆ្នាំនៅកៀនស្វាយ មិនយូរ ។

ដារ៉ា ៖ ភ្លាមៗដែរ?

ពត ៖ បាទ! ក្រោយពីនេះ ថ្ងៃ១៧មេសាមក ដល់ហើយខែ៣ ខែ៤ ខែ៥ទៅ មកកៀនស្វាយស្រុកកៀនស្វាយ ។

ដារ៉ា ៖ ទៅនៅទីរួមស្រុក?

ពត ៖ អត់ទេ នៅឃុំ ។

ដារ៉ា ៖ ឃុំអីគេ?

ពត ៖ ឃុំកំពង់ស្វាយ ។

ដារ៉ា ៖ អូ! ឃុំកំពង់ស្វាយ?

ពត ៖ បាទ!

ដារ៉ា ៖ ទៅជាមេឃុំម៉ង អ៊ំ?

ពត ៖ បាទ! មេឃុំ ។

ដារ៉ា ៖ ទៅដល់នឹងអ៊ំឃើញសភាពការណ៍នឹងយ៉ាងម៉េចដែរ គេសប្បាយអី?

ពត ៖ នៅកំពង់ស្វាយនឹង ប៉ុនពេលនឹងវាប្រជាជនច្រើន ទៅដល់សកម្មភាពរបស់ខ្ញុំទៅតាមថ្នាក់លើនឹង ខាងនឹងសម្រេចថាឲ្យប្រជាជននឹងទៅរស់នៅណា បាត់ដីបងអីណា ។ ដូច្នេះគេយកឡានទៅដឹកប្រជាជនទៅ ។ ហើយចំពោះខ្ញុំដឹកនាំប្រជាជនដាំពោត ដាំអីធម្មតា ។

ដារ៉ា ៖ មុនអ៊ំចេញពីភូមិនឹងទៅ ធ្វើដូចថាធ្វើមេឃុំនៅ?

ពត ៖ កំពង់ស្វាយ ។

ដារ៉ា ៖ ភូមិកំពង់ស្វាយ ស្រុកកៀនស្វាយនឹង អ៊ីត្រូវបានបំពាក់បំប៉នយ៉ាងម៉េច ឬក៏ប្រាប់ផែនការយ៉ាងម៉េចដែរទេ មុននឹងទៅដល់?

ពត ៖ ត្រង់នឹង ទៅដល់នឹងតាម៉ុកនៅកន្ទួត គាត់ទៅដល់គាត់ថាខ្ញុំមសាររបស់គាត់ តាម៉ុកនឹងគាត់អត់ចេះនិយាយច្រើនទេ ដើម្បីក្ដាប់ប្រជាជនគាត់ត្រូវមានបាយ ។ ដូច្នេះ ដើម្បីមានបាយត្រូវមានប្រជាជន ដើម្បីមានបាយ អឺ!ដើម្បីមានកងទ័ពត្រូវមានប្រជាជន ដើម្បីក្ដាប់ប្រជាជនបានត្រូវមានបាយ ។ អ៊ីចឹងនាំគ្នាទៅធ្វើ ទៅហើយ តាម៉ុកគាត់និយាយចេះដែរអានឹងនិយាយនៅពេលនឹងម៉ង ប៉ុននិយាយនឹងកាលគាត់បង្រៀននៅតាកែវ ។ គាត់ថា "វើយ!នាំប្រជាជនធ្វើម៉េចបង្កបង្កើតផលឲ្យបាន ឲ្យមានសេដ្ឋកិច្ចច្រើន ឲ្យប្រជាជនហូបធាត់ធំ ហើយអាយួនលេបអត់បានទេ កើតជម្លោះនគរអាណាគាប់ភូមិដ្ឋានត្រូវមិនស្រួលប្រយ័ត្នអាយួនយកកម្ពុជា និយាយចឹង ។

ដារ៉ា ៖ ចឹងតាម៉ុកគាត់មានគំនិតៗអឺ!ដូចថាស្អប់យួនតាំងពីនឹងហើយ?

ពត ៖ ស្អប់ៗណាស់ ស្អប់យួនអានេះ និយាយពីកម្មាភិបាល នៅចំរៀង គាត់ថាអាមិត្តវ៉ាត់កន្ទុយ យើងនាំគ្នាកាត់ក្បាល តស់!ដាច់ខាត ។ អានឹងខ្ញុំអត់បំភ្លេស អត់នេះ ដើម្បីការពិត ។

ដារ៉ា ៖ ការងារនៅកៀនស្វាយ នៅកំពង់ស្វាយតទៅទៀត ពី៧៥ទៅអ៊ីដឹកនាំយ៉ាងម៉េច មានផែនការទទួលផែនការយ៉ាងម៉េចអីតទៀត?

ពត ៖ ដែលពេលនឹងអត់ទេ ជីវភាពកាលនឹងវាចប់សង្គ្រាមហើយ វាខ្វះខាតគ្រប់ហើយ គឺត្រដាបត្រដួសណាស់ អានឹងទទួលស្គាល់ យើងហូបអង្ករអត់បាន២ខាំផងទេ ។ ប៉ុនកំពង់ស្វាយស្រុកកៀនស្វាយនេះ ប្អូនឯងចង់ដឹងប្រវត្តិពិត ដឹងប្រវត្តិខ្ញុំពិតទៅសួរឃុំកំពង់ស្វាយដឹងហើយ ។ ចុះអាណាបានពោត បានដំឡូងអី អង្ករ គាត់ហូបបាន ប៉ុនអ៊ីដែលខ្ញុំនេះ ខ្ញុំមានកំហុស គេថាខ្ញុំខូចនឹងស្រី ។ ចឹងក៏គាត់ហៅសុគខ្ញុំ ឲ្យមកនៅបឹងខ្យារ កណ្ដាលស្ទឹង ខ្ញុំនៅបានម៉ាឆ្នាំទេ ។

ដារ៉ា ៖ ខូចស្រីម៉េច?

ពត ៖ គេថាខុសសីលធម៌ ។

ដារ៉ា ៖ ចុះមែន?

ពត : ខ្ញុំវា ដូចខ្ញុំនិយាយខាងដើមចឹង ខ្ញុំដោះស្រាយស្តាំ ផ្អៀងស្តាំ ព្រោះខ្ញុំឃើញឯកសារទង់ក្រហមនឹង មានប្រជាជនត្រៀម ពេញសិទ្ធិថ្មី។ ដល់ហើយខ្ញុំថា អ្នកថារំលាយវណ្ណៈ ដូច្នេះថាមានការបែងចែកចឹង ព្រោះវានឹកឃើញថាមានប្រពៃណីទំនៀមទម្លាប់ខាងការងារ កាត់ខាន់ស្លា វាមានរាជសក្តិ បុណ្យសក្តិ ភពសក្តិ តារាសក្តិ ព្រោះខ្ញុំមិននឹងធ្វើបដិវត្តិនឹង ខ្ញុំធ្វើមហា ចេះចុះចឹងឯងរំលាយវណ្ណៈហើយ នៅមានបែងចែងត្រៀម ពេញសិទ្ធិ ថ្មីនឹង ខ្ញុំក៏ដោះស្រាយធ្វើម៉េចឲ្យវាមានរឿង បន្ថយសិទ្ធិ ហើយបើកាលណាខ្ញុំនៅ គឺកូតខ្ញុំអាវា អាចត្រូវឡើងទៅទៀត។ ចឹងវាពិបាក ខ្ញុំមានគំនិតចឹង ប៉ុនអត់ប្រាប់ពីណាទេ។ ក៏ដោះស្រាយទំនាស់នឹងចេះ យុវជន យុវនារីប៉ុន្មានរយនាក់នឹង ឲ្យទៅជីកប្រឡាយនៅប្រាសាទតាយោល ហើយខ្ញុំក្រមាតាមសហករណ៍ទាំងអស់ ខ្ញុំយកមកខ្ញុំតំរង់ជួរចែកទៅ ដូច្នេះ ខ្ញុំទៅសីហនុចែកអំណោយ គេថាម៉េចថាទៅ ដោះស្រាយគេនឹងមួយ។ មួយទៀត ខ្ញុំប្រាប់ប្អូនឯងត្រង់ ប្រពន្ធសក្តិ៥មួយ ដល់ហើយមិនដឹងថាគេមានគំនិត គ្នាទៅសម្រាលកូន ប៉ុនប្តីខ្ញុំទៅអត់ទាន់ទេ គេយកគាត់ទៅសម្លាប់ធ្វើបាបហើយ។ ដល់ហើយ ខ្ញុំសុំជម្រាប កន្លែងមន្ទីរពេទ្យនៅកំពុងស្វាយចឹង មន្ទីរពេទ្យធំ ហើយធ្វើនៅក្នុងចំការក្រូចៗចឹង។ ពួកមូលដ្ឋាន មានប្រជាជនចាស់សម្រាលម៉ាគ្រែៗដផ្ទែរគ្នាយើងចឹង ហើយគ្នាអ្នកថ្មីហើយចឹង។ ហើយខ្ញុំចូលទៅឃើញគ្នាសម្រាលហើយវាហត់វាហេវ ខ្ញុំទៅចុះក្រូចនឹងម៉េចមិនបេះ មកឲ្យគាត់ហូបមក គេសម្គាល់ខ្ញុំនឹងដោះស្រាយឯង សន្តិសម្ព័ន្ធជាមួយប្រពន្ធទាហានមុន វាចេះអានឹងករណីដែលខ្ញុំដឹង។ ដល់ហើយបានខ្ញុំថាអូ! បើនិស្ស័យបុណ្យខ្ញុំមានសង្គ្រោះជីវិតមនុស្ស បើខ្ញុំស្លាប់ក៏ជាប់នឹងសាសនាដែរ បានរស់។ អានឹងបានខ្ញុំជម្រាបប្អូនឯងត្រង់ ដែលរស់នៅរាល់ថ្ងៃនេះ គឺមានចឹង ពីព្រោះចំពោះប្រជាជនមូលដ្ឋានគេដោះស្រាយ ខ្ញុំស្តីឲ្យពេទ្យ គេថាឲ្យទាំងអស់គ្នាទៅ យើងថាមិនបែងចែកទេ។ យើងឃោសនាលាតសន្ធឹងថា អត់បែងចែកទេ ដោះស្រាយដូចគ្នា។ ដល់ជាក់ស្តែងនេះ យើងទុកគេចោលនឹងវាសមស្របទេ។ ដូច្នេះពេទ្យៗទាំងអស់នឹង ហើយក៏គេសម្គាល់ថាខ្ញុំនេះសន្តិសម្ព័ន្ធមួយ ឯងមួយទៀត ឯងទៅពីនេះ គេប្រើពាក្យមួយ ក្អែកទឹកគោកមកដេញក្អែកទឹក។ ដូច្នេះវាមាន អាចរិតចឹង។

ដារ៉ា : ចុះអ៊ំយល់ឃើញយ៉ាងម៉េចដែរ អំពីការបញ្ជូនខាងនិរតីទៅគ្រប់គ្រងនៅកៀនស្វាយវិញ?

ពត : អត់បានដឹងយ៉ាងម៉េចទេ ព្រោះប៉ុនវាគ្រាន់ថាកម្មាភិបាលនៅខាងនោះ វាតិច វាខ្វះខាត។

ដារ៉ា : ចឹងវិញ?

ពត ៖ បាទ! ខ្ញុំះខាត ចឹងឲ្យយើងទៅចូលរួមចំណែកទៅជួយដឹកនាំ បើយើងនិយាយពាក្យតែម៉ាត់នឹងក៏វាម្យ៉ាងដែរ ដូចថាលក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជាវាផ្សេងៗយ៉ាងម៉េច ឧបមាថាបើខ្ញុំនេះ ម៉ាឃុំនឹងឲ្យឈ្មោះបើមានម៉ាសាខាមានសិទ្ធិស្មើ ។ ដូច្នេះម៉ាឃុំនឹងគ្មានបក្សជនដល់៣ទេ មានតែ១ ហើយនឹង២ ១ហើយនឹង២គ្មានធ្វើអីបានខ្ញុំពិបាក ។

ដារ៉ា ៖ ពិបាកម៉េចអ៊ំខ្ញុំតាមកន្លែងនឹងអត់ទាន់ អារឿងម៉ាឃុំមានគេហៅម៉ាសាខាចឹង?

ពត ៖ អត់ទេ ម៉ាសាខាដល់៩នាក់បក្សជនពេញសិទ្ធិ គេហៅបក្សជនកុម្មុនីយ ។ ហេតុដូច្នេះម៉ាឃុំជាងទងមានច្រើនជាងគេ ដោយសារគេជំនាន់ចាស់តស៊ូពី៦៨ ៦៩អីមកខ្ញុំអត់ដឹងទេ ស្រាប់ដល់ពេលនេះ ខ្ញុំក្រោយទេ ។ បក្សជនមុនដំបូងចំរើន ហើយកាលណាយើងធ្វើការបានល្អស្មោះត្រង់ទៅ ប៉ុនគេផ្អែកលើវណ្ណៈ ៗក្រ គេបានចូលជាបក្សជន ។ ចូលបក្សជនហើយគេទុកត្រៀមទៀត អត់ទាន់ពេញសិទ្ធិទេប្អូន ។ ខ្ញុំជាកូនសិស្សគេទុក៩ខែ តាមដានពីក្រោយទៀត បើកាលណាយើងមិនស្មោះត្រង់មិនដាច់ខាតគេអត់ឲ្យពេញសិទ្ធិទេ ។ ពេញសិទ្ធិនឹងបានន័យថាហៅទៅបញ្ចូល មានប្អូនឯងជាសាក្សី២នាក់ចឹង ប្រធានមួយទទួលស្គាល់ ហើយខ្ញុំប្តេជ្ញាគោរពទង់បក្ស ដើរតាមបក្សចឹង ។ អានឹងអីចឹងណា៎ ។

ដារ៉ា ៖ បាទ!

ពត ៖ ចឹងប្អូនចង់បញ្ជាក់មិញនេះដែលពិបាក ឧបមាថានៅក្នុងឃុំមួយនឹងនេះ កាលខ្ញុំទៅមានតែ២នាក់ហើយទៅពីនេះ ខាងនោះអត់មានមហាជនចំរើនកាលនោះចឹងប្អូន ។ ចឹងទៅដឹងថាធ្វើការដឹកនាំ ដឹកនាំចឹងទៅ ។ ហើយដូច្នេះបើមានកិច្ចការអី យើងអត់មានសិទ្ធិសម្រេចអីស្នើឡើងរាយការណ៍ប្រាប់ ។ អីចឹងបានខ្ញុំឃើញជីវិតមនុស្សពេលនឹង នៅម៉ាចុងប៉ិចទេម៉ាពព្រេចភ្នែកទេ បើអ្នកណាចង់សម្លាប់ ឬគំនុំមនុស្សណាម្នាក់ គឺគេអាចធ្វើបាប ។ ប៉ុនសម្រាប់ខ្ញុំគឺអត់ទេ គឺយកមាគ៌ាមកចង្អុលបង្ហាញជានិច្ច ជាគោលការណ៍ ។

ដារ៉ា ៖ ចឹងអ៊ំចង់មានប្រសាសន៍ថេះ ទាល់តែមានបក្សជន៩នាក់ម៉ិងបានអាចសម្រេចនៅក្នុងកន្លែងនឹងបាន?

ពត ៖ អត់សម្រេចទេ អានឹងហៅម៉ាសាខា ។

ដារ៉ា ៖ ម៉ាសាខា?

ពត ៖ បាទ! ដល់៣សាខានឹង ៣សាខាបានមានសិទ្ធិសម្រេច បើ៩នាក់នឹងមានសិទ្ធិស្មើឡើង ។

ដារ៉ា ៖ មានសិទ្ធិស្មើទេ?

ពត ៖ បាទ! ស្មើទេ ។

ដានី ៖ ចឹងទោះបីជា៩នាក់ ឬ២នាក់ក៏ដោយជាបក្សជននឹងគ្រាន់មានសិទ្ធិស្មើទេ?

ពត ៖ គ្រាន់មានសិទ្ធិស្មើ មានសិទ្ធិរាយការណ៍ទេ គ្រាន់សិទ្ធិលូកដៃចុងក្រោយអីចុះ ។

ដារ៉ា ៖ សម្រេចអីអត់មានទេ?

ពត ៖ មិនបាច់ទេ បាទ! ចឹងបានខ្ញុំឆ្លល់គេ ថាគ្រាន់ការស្លាប់មនុស្សនៅឃុំមួយៗភូមិមួយៗវាហួស វាមានហាក់ដូចជា ខ្ញុំវាក់អ៊ី ដល់ពេលខ្ញុំវាក់អ៊ី ។ ព្រោះខ្ញុំត្រូវលក្ខន្តិកៈ ទៅរៀននឹងគឺរៀនឯកសារតែ៣ទេ ឯកសារលក្ខន្តិកៈបក្ស ឯកសាររណសិរ្ស ហើយនឹងឯកសារយោធា អាគេវៃអីណា ។

ដារ៉ា ៖ បាទ!

ពត ៖ លក្ខន្តិកៈបក្សដូចខ្ញុំថាចឹង ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ បុគ្គលគោរពសមូហភាព ហើយពាក្យដែល ។

ដារ៉ា ៖ រណសិរ្ស?

ពត ៖ រណសិរ្សរួបរួមជាតិប្រមូលឲ្យបានសាមគ្គីឲ្យបាន ប្រមូលវៃឲ្យចំក្នុងនោះមានវណ្ណៈកសិករ កម្មករ នាយទុន អនុធន ហើយនឹងអ្នកសក្តិភូមិនៅក្នុងឋានៈវណ្ណៈ យើងសត្រូវវណ្ណៈនឹង ។

ដារ៉ា ៖ ហើយបន្ទាប់មកទ័ព?

ពត ៖ បន្ទាប់មកទ័ព បានទ័ពវៃទល់ជ្រូក វៃម៉េច របៀបវៃម៉េចៗខ្ញុំមិនសូវនេះដែរ ផ្នែកកងទ័ពៗគេរាយការណ៍ ។ ម៉ែក្មេកខ្ញុំគាត់ចាស់ទៅវង្វេង ។

ដារ៉ា ៖ ហើយអី! ចឹងអីដល់ឆ្នាំណាដែលគេបានត្រូវដកឲ្យមកធ្លាក់ពីឃុំអីនឹង ដែលអ៊ំនិយាយថាធ្លាក់កូតនោះ?

ពត ៖ ធ្លាក់កូត ៧៦ ៧៧ចូលមក ដល់ចូល៧៧នឹងគឺមកនៅបឹងខ្យាងៗ ប៉ុនរបៀបគេដកនឹងគេដកស្រួលដែរ គេមិនឲ្យយើងនេះទេ ។ ដកមកៗនៅឃុំបឹងខ្យាង កណ្តាលស៊ីងឲ្យខ្ញុំទទួលជាអនុៗឃុំ អនុបាន៣ខែធ្លាក់កូតមកសមាជិកសាខា អឺ!សមាជិកសាខាហើយ អានឹងសាមញ្ញធម្មតា ។ ដល់ដាកខ្លួនមិនដាប់ហើយពេលនឹង ។

ដារ៉ា ៖ ហើយចឹងតាម៉ុលគេដឹងទេ?

ពត ៖ ដឹង អូ!ដឹង អានឹងសុទ្ធដឹងហើយ ព្រោះវារបាយការណ៍តែភូមិមួយទៅភូមិមួយ ។ ខ្ញុំអត់ដឹង ប៉ុនដល់ទៅគេកម្មាភិបាលគេទៅរៀនដល់មជ្ឈឹម គេថាមិត្តពតឯងមិនមែនដឹងត្រឹមឃុំមិនដឹងត្រឹមស្រុកខេត្តកណ្តាលទេគេខេត្តម៉ាភូមិភាគម៉ាប្រទេសនោះ គេលើកក្នុងសន្និបាត ។

ដារ៉ា ៖ លើកពីឈ្មោះអ៊ំនឹង?

ពត ៖ បាទ! លើក បានន័យថាក្បត់អីណា សីលធម៌ អាកប្បកិរិយា គេលើក ។

ដារ៉ា ៖ ហើយអ៊ំត្រូវបានគេលើកឈ្មោះនៅប្រជុំ?

ពត ៖ អានឹងខុស កាលណាយើងខុសគេលើក ។

ដារ៉ា ៖ លើកនៅក្នុងដល់ថ្នាក់មជ្ឈិមម៉ង ប្រជុំសន្និបាទ?

ពត ៖ បាទ! ប្រជុំសន្និបាទលើកខ្ញុំ បើគេកុហកៗតាមគេ ប៉ុនគេអ្នកទៅរៀនមកវិញគេនិយាយចឹង ។

ដារ៉ា ៖ ឬមួយក៏អ៊ំមានឈ្មោះ ពត ដូចប៉ុល ពត ដែល ឬយ៉ាងម៉េច?

ពត ៖ មិនដឹងយ៉ាងម៉េចទេ ប៉ុនឈ្មោះពតនេះខ្ញុំវានេះដែរនឹង មិនដូចពតនោះ គេលើក្នុងខេត្តក៏មិនដឹងកាលនឹង ព្រោះខ្ញុំធ្លាក់កូតមកចឹង គេអត់ឲ្យនេះ ។ គេតាមមើលរហូត ។

ដារ៉ា ៖ ធ្លាក់មក?

ពត ៖ ធ្លាក់មកសាខា សមាជិកសាខានឹង មុនសមាជិកអចិន្ត្រៃយ៍ ។

ដារ៉ា ៖ បាទ!

ពត ៖ សមាជិកអចិន្ត្រៃយ៍មានលេខា អនុលេខា សមាជិក ៣នឹងជាសមាជិកអចិន្ត្រៃយ៍ ។ ៦យើងជាសមាជិកសាខានឹង ពិតមែនឃុំនឹងមាន៧រូប ប៉ុនយើងគ្មានសិទ្ធិអីទេ គ្រាន់សិទ្ធិរាយការណ៍ប្រាប់គេ នឹងសិទ្ធិអនុវត្តតាមគេចង្អុល ។ ហ្នឹងឲ្យសិទ្ធិចាត់ចែងអីអត់ទេ សិទ្ធិជំទាស់អីលើកឡើងអត់ទេ នាំផាប់ខ្លួនទេ អានឹងវាចឹង ។

ដារ៉ា ៖ ចុះអ៊ំធ្វើម៉េចបានអាចគេចផុតពីការតាមដាន ការអីបាន?

ពត ៖ ដែលខ្ញុំពេលនឹង អនុវត្តរបស់គេនៅការដ្ឋានស្ទូងដកនឹង បេះប្រឡូកចលនាជាមួយពួកទឹកឡើង រាយការណ៍ប្រាប់គេទៅ ទឹកលិចយើងធ្វើនេះចឹង យើងរត់ប្រាប់ ។

ដារ៉ា ៖ នៅក្នុងចង្កោមនៃឃុំនៃអីចឹងដែរ ហើយម៉េច?

ពត ៖ បាទ! ក្នុងឃុំ ប៉ុនដូចខ្ញុំជម្រាបចឹងសមាជិតសាខាមិនមែនអចិន្ត្រៃយ៍ទេណា ។ ឃុំនឹងមាន៧នាក់ចឹង ឃុំនឹងមាន៥នាក់ចឹង យើងធ្លាក់នៅទី៥ ទី៦អីចឹងទៅណាទី៥ ។ ព្រោះគេមានសិទ្ធិសម្រេច មានសិទ្ធិប្រជុំ ។ ការប្រជុំរបស់គេមានបេះ មិនមែនបេះតែប្រជុំទេ ។ ឧបមាថា លេខាទៅទទួលព័ត៌មានទទួលផែនការពីគណៈតំបន់ពីការប្រជុំនៅស្រុកអីចឹង ។ ដល់មកវិញ គេហៅអនុលេខា និងសមាជិក៣នាក់នឹង គេប្រជុំស្ងាត់ឡើងរៀនសូត្រ

ខ្ទឹមសារហើយ បានគេហៅយើងជាសមាជិកសាខាទៅប្រជុំទទួលផែនការ ។ ហើយយើងទៅទទួលបានចុះ ទៅអនុវត្តជាមួយប្រធានកងនៅតាម ។

ដារ៉ា : ចឹងការទទួលផែនការបានតាមរយៈអ្នកទៅប្រជុំនោះទេ?

ពត : បាទ! បានទៅប្រជុំនោះទេ ។

ដារ៉ា : ចុះអ៊ំរស់នៅឆ្ងាយពីនេះដែរ ឆ្ងាយពីផ្លូវជាតិដែរ នៅក្នុងពេលពីអំឡុង៧៥ មកដល់៧៧ ៧៨ នៅក្នុងឃុំកំពង់ស្វាយអីអឹ?

ពត : ឃុំកំពុងស្វាយនឹងទៅពី គេនៅជាប់នឹងថ្នល់ ជាប់នឹងថ្នល់ជាតិ ជាប់នេះបើទៅតាមផ្លូវច្បារអំពៅនឹង ទៅចឹងទៅឃុំឈើទាល ផុតដល់ឃុំឈើទាល ឃុំកំពង់ស្វាយហើយ ។

ដានី : តាមមាត់ទន្លេ?

ពត : បាទ! តាមមាត់ទន្លេ ។

ដារ៉ា : ចឹងអ៊ំពេលទៅដល់កំពុងស្វាយភ្លាមចឹង អ៊ំមានបានសួរនាំព័ត៌មានអីខ្លះ ដែលទាក់ទងនឹងមុនឆ្នាំ៧៥នឹងដែរទេ នៅក្នុងតំបន់អ៊ំដែលទៅរស់នៅនឹង?

ពត : ដែល អត់ដែលសួរគេ សួរចេះដែរថានៅកន្លែងការធ្វើសង្គ្រាម វ៉ៃចក្រពត្តិអាមេរិច មានវ៉ៃធ្វើសកម្មភាពណា ។ សួរគេតែប៉ុននឹង គេថាដើរទៅកាត់ព្រៃកាត់ផ្សែអីចឹង នឹងតាមប្រជាជនគាត់រាយការណ៍ប្រាប់ យើងដឹកប្រឡាយ ។

ដារ៉ាៈ ទៅដល់នឹងអ៊ំមានលេចឮសម្ដី ឬព័ត៌មានអីទាក់ទងនឹងការចាប់ជនស៊ីវិល ពួកស្បែកសស្បែកអី នៅតាមស្រុកនឹងឃុំនឹង?

ពត : ស្បែកសដូចជានេះហើយប្អូន ចេះគេលាក់ការណ៍ ។ ប៉ុនទៅដល់នឹង ខ្ញុំទៅបានប៉ុន្មានខែឮសួរព្រឹត្តិការណ៍នេះមួយ អានេះខ្ញុំចាប់ញាក់សាច់បណ្ដោយ ព្រឹត្តិការណ៍នឹងគេហៅចាប់ចក្រី មេទ័ព ។ មិនដឹងមេទ័ពខាងណាទេ ចក្រី ។

ដានី : ចាន់ ចក្រី?

ពត : បាទ! អានឹងចាន់មិនដឹងស្អី មិនមែនចាន់ រង្សីទេ ចក្រីទ័ពខ្មែរក្រហម ។ គេឡូបគ្នា ខ្ញុំឮព្រឹត្តិការណ៍ អានេះខ្ញុំឃើញបូព៌ា ហើយនឹងនិរតីអាកុងគ្នា បែកបាក់ ។ ដល់ហើយក្រោយមកខ្ញុំនៅកណ្ដាលស្ទឹងហើយទេ បានឮសួរ ។ ប៉ុនចេះប្អូនសួរមិញថាសួរថា?

ដារ៉ាៈ សួរថាពួកស្បែកស ស្បែកអី ដែលថាវមានមុនឆ្នាំ៧៥នឹងមក ដូចថាក្នុង៧២ ៧៣?

ពត : អត់ទេ អត់មានទេ ។

ដារ៉ា : ដូចថាព័ត៌មាន ក្រែងលរអ៊ំទៅដល់ស្រុកភូមិនឹងទៅឮអ្នកស្រុកអ្នកភូមិឮនិយាយ?

ពត ៖ អត់មានទេ ប៉ុន្តែចំពោះអ្នកដែលមកពីបារាំងដូចចុង៧៨ ហើយដើម៧៧ទេ ហើយក៏អត់ឆ្ងាយដល់ឃុំដែរ បើគេបញ្ចេញពីភ្នំពេញចឹងទៅ ខ្ញុំនៅត្រឹមស្រុកទេ។ ហើយខ្ញុំអត់ដឹងទៀតប៉ុនពេលមួយនឹង ខ្ញុំឮសូរៗយាយបូៗធ្វើលេខាចៅហ្វាយស្រុកនៅនឹង។ និយាយថាអ្នកមកពីបារាំង អ្នកមកពីអី។

ដារ៉ា ៖ អ្នកមកពីបារាំង ជនជាតិខ្មែរយើងមកពីបារាំង?

ពត ៖ ខ្មែរៗយើងនឹង ពួកបញ្ញវន្តពួកអី កាលនឹងអៀង សារី ខ្ញុំស្តាប់បានអៀង សារីប្រកាស អៀង សារីនៅក្រសួង។ ប៉ុនគេគ្រាន់ឮសូរប្រកាសតាមវិទ្យុ អញ្ជើញបងប្អូនយើងចូលរួមចំណែក។ ហើយដូច ចៅ សេង ចៅអីមកជិតនាន់នឹងដែរ។ ហើយខ្ញុំប្រាប់ប្អូនឯងត្រង់ ខ្ញុំស្រឡាញ់អ្នកបេះ ស្តាយៗ។ ហើយនៅឃុំដាងទងនេះ អ្នកដែលគេត្រូវបាក់ឌុប អឺ!ត្រឹមឌីប្លូម ខ្ញុំហៅមកឱ្យបប្រាប់ នៅរាល់ថ្ងៃគេនៅធ្វើគ្រូធ្វើអី គេនៅអរខ្ញុំ ព្រោះខ្ញុំស្រឡាញ់អ្នកបេះ ខ្ញុំអត់ធ្វើបានទេ ប្រាប់ប្អូនឯង។ បងក៏ដូចប្អូនឯងដែរ បងកម្រិតវប្បធម៌តិចដាងប្អូនឯងផង ដូច្នេះប្អូនឯងត្រូវប្រយ័ត្ន កុំធ្វើបេះ កុំធ្វើដឹងគេ។ ខ្ញុំថាពេលនឹងឫស្សីអត់ខ្នាំងអាគាំងមិនឮហើយ ប្អូនកុំធ្វើបេះ រនោចអត់ភ្លឺពេញបរងងឹតឲ្យគេទៅ។ នេះជម្រាបប្អូនឯងត្រង់ហើយមិននេះទេ កម្ពុជាមិនដឹងម៉េច កម្មអីក៏កម្មមាំម៉េច។ ខ្ញុំរាល់ថ្ងៃពេលខ្លះគិតហូរទឹកភ្នែកម្នាក់ឯង ទៅធ្វើដូចនេះ នឹកឃើញ បើនិយាយពីកាត់ទោសខ្មែរក្រហមឥឡូវខ្ញុំ កំណត់មិននិយាយប្រាប់គេផង ថាមិនដឹងទេ ប៉ុន្មាននាក់នឹង ខ្ញុំឲ្យឈ្មោះថាគេឲ្យគាត់មក អង្គុយលេងបាយឡុកបាយឡជាមួយគ្នាគាត់នឹង អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, នួន ជា ហើយតាឌុច។ អីខ្លះដោយសារឯង បើអង្គការជាអ្នកឲ្យលុយមកៗប៉ុនអង្គុយ តើឃើញទេ មកអង្គុយលេងបាយឡុកបាយឡជាមួយគ្នានឹង៧ថ្ងៃម៉ាអាទិត្យគេឲ្យទៅជួបគ្នា២ដង។ ដូច្នេះយើងអាចក៏កំបាំងម៉េច គាត់ចង់រុញដាក់នរណាម្នាក់រុញទៅ យើងទៅធ្វើអីកើត។ ហើយលក្ខន្តិកៈដូចខ្ញុំថាមិញ គណកម្មាធិការមជ្ឈឹមវាមានប៉ុន្មាន ដូចត្រឹមគណៈកម្មការនៅឃុំម៉ាសាខា ២សាខា វាមានមេ ដល់ទៅខាងនឹងយើងដឹងណាមួយអ្នកទទួលខុស ត្រូវពិតប្រាកដបើលេងចឹងហើយ ថាដូចពិបាក មិនចង់ឃើញ។

ដារ៉ា ៖ ចឹងអឺ! ចុះអ៊ំមានការគាំទ្រដែរ ចំពោះការកាត់ទោស?

ពត ៖ បងនិយាយឲ្យស្មោះត្រង់ណា៎ ចង់ឲ្យកាត់ ចង់កាត់ប្អូន ដើម្បីយុត្តិធម៌ចង់ឲ្យកាត់។ ប៉ុនកាត់នឹង ហើយបើមិនកាត់ក៏ល្អ ឲ្យប្រជាជនឯកភាពគ្នាថា ឥឡូវពៀររំងាប់ដោយការមិនចងពៀរ ឲ្យចប់ត្រឹមនឹងម៉ង ឲ្យសន្តិភាពកើតមាន ខ្ញុំធ្វើ។ ដល់មែនទែនខ្ញុំសិក្សា ខ្ញុំហួរ

ទឹកភ្នែករឿងអី លោកនិយាយមកចេះ ប្រាប់មកចឹង ។ ខ្ញុំកំណត់ខ្លួនខ្ញុំឥឡូវនឹង ខ្ញុំប្រាប់កូនប្រាប់ជំនះមិន ឈ្នះទំនាយ រឿងកម្ពុជាជំនះមិនឈ្នះជំនាយខ្ញុំប្រាប់ ។ ដល់ហើយមានអាខ្លះគេសួរថាមើល និយាយតិចមើល ។ និយាយខ្ញុំអាចនិយាយបាន ជំនះមិនឈ្នះទំនាយ ម្ទិលឥតសាសនា មកដឹកនាំប្រទេស ម្ទិលឥតសាសនា ។ ប៉ុល ពត យកតែសាសនាទេ បំបាត់សាសនាទេ ប៉ុនត្រង់ថាឲ្យឈ្មោះថាក្បត់ជាតិនៅមិនទាន់លើកឡើងថាយ៉ាងម៉េចទេ ព្រោះការរកមិនទាន់ឃើញ ។ ហើយប៉ុល ពត មានយុត្តិធម៌ទី១តំលាភាពអ្វីដែលខ្ញុំនិយាយនេះដណ្តងដែរគាត់ ប្រមូលទុកនេះ ក៏ក្នុងរបបប៉ុលពតនឹងហើយ ។ បានន័យថា ហើយគណនេយ្យភាព គាត់នៅឈរអត់សម្លាប់ខ្លួនទេ ខុសពីប៉ុលពតនៅមានតាម៉ុក, មាននួន ជា, មានខៀវ សំផន នៅអង្គុយចាំឲ្យគេកាត់ទោស អត់ចង់កសម្លាប់ អត់រត់ចោលស្រុក បានន័យថាចឹងរបបនឹង វាបង្ហាញដែរយើងតំលាភាព ។ ដណ្តងប្រមូលទុកទាំងអស់ នៅស្រុកត្រាំកក់មាន ក្រាំងតាចាន់ ។ ទីក្រុងភ្នំពេញ កណ្តាលបេះដូងប្រទេសទុកឲ្យភ្នកញាតិ និងភ្នែកជាតិឃើញទាំងអស់ ស្លាប់លលាន៍ ដណ្តងដែលត្រូវទុក ។

ដារ៉ា : តែរហូតមកដល់សព្វថ្ងៃនេះ ដូចមេដឹកនាំខ្មែរក្រហម ដែលជាប់ឃុំឃាំងនៅសាលាក្តីខ្មែរក្រហម តើហេតុអីគាត់អត់មាន អត់និយាយការពិតទាំងទាល់តែសោះ?

ពត : ព្រោះចឹងបានខ្ញុំចាំមើលចំលើយ ដែលតុលាការហៅគាត់មកសួរម្នាក់ម្តងៗ ចំមើលគាត់ឆ្លើយ បើឌុចឆ្លើយហើយ ។ ចុងក្រោយខ្ញុំថាលេងតិចទៅ បើកមុខតិច គាត់ថាបើមិនអនុវត្តគឺខ្លួនគាត់ស្លាប់ដែរ ហើយពេលនឹងចឹងមែន ។ ដូច្នេះបក្សកុម្មុយនីសកម្ពុជានឹង អនុវត្តដោយផងឹតផងុលមានទៅតាមចិន ។ បើឌុចបង្ហើបប៉ុននេះគាត់ឃើញមួយ ឃើញថាអានឹងវាមិនដឹងអ្នកណានៅពីក្រោយ ។ ប៉ុនខ្ញុំឃើញថា រាល់ថ្ងៃនេះ ខ្ញុំប្រាប់កូនខ្ញុំ កូនអើយតាំងដូចថាកូនឯងឪខ្ញុំផ្តាំគាត់ថា កូនឯងកុំខ្លាំង ខ្ញុំអត់លាក់ទេ ឆ្នាំ៧០ចូល៧៥ ដែលគេដេររបបចក្រពត្តិ គាត់ថាតាអ៊ុងដេរតាឯក តាឯកដេរតាអ៊ុង តាអ៊ុងក្បាលទំពែក តាឯកក្បាលត្រងោល កូនឯងគិតតែប៉ុននឹងបានហើយកុំខ្លាំង ពុកខ្ញុំគាត់ប្រាប់ចឹង កាលនឹងខ្ញុំអាយុជាង២០ គាត់អាយុ៥០ ។ ដល់ហើយមកថ្ងៃនេះ បានខ្ញុំនឹកឃើញថា ប្អូនដេរខ្ញុំអាខ្ញុំចិន ខ្ញុំដេរប្អូនឯងថាខ្ញុំអាមេរិចកាំង ។ ដូច្នេះខ្ញុំឆ្លើយថាខ្ញុំខ្មែរ ខ្ញុំបម្រើឲ្យខ្មែរ ខ្ញុំមិនមែន បម្រើឲ្យចិនទេ ។ ប្អូនក៏ឆ្លើយថាខ្ញុំខ្មែរ ខ្ញុំបម្រើឲ្យខ្មែរ មិនមែនបម្រើឲ្យអាមេរិចកាំងទេ ។ ក៏ប៉ុន្តែនេះអត្តនោម័តឆ្លើយប៉ុននឹងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ។

យើងដាក់សំនួរខ្លួនខ្ញុំ ហើយឆ្លើយខ្លួនខ្ញុំទៅតាមសំនួរសម្តីដែលពុកខ្ញុំគាត់ប្រាប់ ។ ដូច្នេះមិនបដិសេធទេ គឺថាខ្ញុំ ឆ្លើយប៉ុននឹងមិនទាន់គ្រប់គ្រាន់ទេ ចឹងពេលនោះចិនមកឬក៏មិនមក ។ ចិនមកជាសម្ភារៈ មកជាទីប្រឹក្សា ។ អាមេរិចកាំងមកជាហិរញ្ញវត្ថុ មកទាំងយោធាបេ៥២ ជាទីប្រឹក្សា ។ ចឹង ក្បាលតាអ៊ុង ហើយក្បាលតាឯក គឺក្បាលទំពែក ត្រងោលដូចៗគ្នា អត់មានអ្នកណាមួយញែកបាន ។ ចឹងបានថ្ងៃនេះ ខ្ញុំវិភាគទៅទៀតសម្រាប់ខ្លួនខ្ញុំ ។ ឯងដែរ ប្អូនមិនមែនមិនឯងទេ ឯងត្រង់អីគេដេរខ្មែរក្រហម គេកម្មាភិបាលខ្មែរក្រហមសម្លាប់ប្រជាជន ដោយឡែកខ្ញុំ វិភាគទៀត ថាសាច់នៅជាមួយឈាមៗនៅជាមួយសាច់ឆ្អឹងមិនមែននៅជាមួយឆ្អឹង ក៏ប៉ុន្តែពេលនេះគឺម៉ៅទាំងអស់វាអត់ត្រូវទេ ព្រោះសាច់នៅជាមួយឆ្អឹងខ្ចីដែរ ។ សាច់នៅជា ជាប់ឆ្អឹងជំនីរជ្រូកអាខ្ចីៗ ។ ដូច្នេះគេអាចទំពារទាំងឆ្អឹងខ្ចីទាំងសាច់លេបចូលបាន ។ ចឹងមានប៉ុលពត កម្មាភិបាលប៉ុលពតមួយចំនួន ក៏ឈឺចាប់នឹងអាបរទេសលេបទឹកដីដែរ ហើយពេលនឹងក៏រួមចំណែកប្រឆាំងដែរ ។ ចឹងបានខ្ញុំឥឡូវអាយុ ៧០ ប្លាយវាចេះវល់វក់ភ្លេចមុខ ភ្លេចក្រោយ ប៉ុនអាការជំហរនឹង ។

ដារ៉ា : នៅជាប់ចឹង?

ពត : បាទ! ជាប់ចឹង ។ ព្រោះវេទនាណាស់ប្អូន ខ្ញុំហូរទឹកភ្នែកដល់ប្រជាជន ពេលនឹងប្អូនឯងនៅតូចទេនេះៗវ៉ៃនេះ វ៉ៃនៅអន្លុងតាសោម តាកែវ ។ ប្អូនឯងវិភាគរបួសចាប់សែងពីតាកែវមកតាថ្នល់នេះ ហើយនារី យុវនារី ក្នុងសង្គ្រាមទៅហើយឈរនៅនឹង មានទៅជួរបម្រើសង្គ្រាម បម្រើម៉េចសែងពីត្រឹមផ្ទះថ្មនោះ ផ្ទះក្បឿងនោះមកទល់ត្រង់នេះម៉ាជំណាក់ ។ អ្នកភូមិនឹងម៉ាជំណាក់សែងទៅដល់មន្ទីរពេទ្យម៉ាជំណាក់ទៅរហូត ពេទ្យកណ្តាលព្រៃនោះ ។ ឯវ៉ៃនៅភ្នំពេញ ពេទ្យ២២នេះ ពីកំពង់ទួលសែងពីនឹងមកដេក ពេទ្យ២២ តាជួនជឿននឹង ម៉ាពេលនឹង ។ ដល់លទ្ធផល ថ្ងៃនេះវាទៅជាចឹងទៅវិញ បានតឹកឃើញថាខ្មែរមិនដឹងថាថ្ងៃណាចប់ទៀត ។

ដារ៉ា : តែអ៊ុំមានប្រសាសន៍ជាការម្យ៉ាងដែលថាយើងមានគេការនិយាយថា កម្មាភិបាលខ្មែរក្រហមសម្លាប់មនុស្សសម្លាប់អីចឹង ហើយដោយសារអ៊ុំនៅក្នុងជួរនឹងដែរ ។ ប៉ុន្តែចឹងហើយបានជាការកាត់ទោសគេមិនមានធ្វើការកាត់ទោសទៅដល់ថ្នាក់ក្រោមអីចឹង ប៉ុន្តែអ្វីដែលយើងចង់បាន ចង់ឲ្យមានការផ្សះផ្សា គឺការនិយាយរឿងរ៉ាវពិតដែលចេញមកទម្លាយឲ្យ ប្រជាជនយើងអ្នកដែលមិនធ្លាប់ឆ្លងកាត់បានដឹងទាំងអស់គ្នា?

ពត : បាទ! បានដឹងទាំងអស់គ្នា ។

ដារ៉ា ៖ អានឹងជាការសំខាន់ ដូចខ្ញុំបានជួបអ៊ំក្នុងថ្ងៃនឹងចឹង អ៊ំបាននិយាយរឿងរ៉ាវទាំងអស់ ដែលមានចំនុចខ្វះ ដែលពួកខ្ញុំមិនបានសិក្សាដល់ដែរ ហើយក៏អត់បានដឹងរឿងនឹងដែរ ជាប្រយោជន៍សម្រាប់ពួកខ្ញុំស្រាវជ្រាវដែរ ។ ហើយបើសិនជាកម្មាភិបាលផ្សេងៗ មានគំនិតដូចអ៊ំដែរ ហើយទម្លាយការពិតចេញមកក្រៅចឹងដែរ ខ្ញុំយល់ថាប្រហែលជាវាមានប្រយោជន៍ដ៏សំខាន់ក្នុងការផ្សះផ្សា ក្នុងការទប់ស្កាត់អីចឹង ហើយចំពោះអ៊ំៗយល់ថាការដែលនិយាយថា កម្មាភិបាលខ្មែរក្រហមសម្លាប់មនុស្សសម្លាប់អីចឹង អ៊ំនៅមានអារម្មណ៍ថាខឹងសម្បារចឹងដែរ ។

ពត ៖ មិនខឹងទេ ប៉ុនចង់និយាយថា ។

ដារ៉ា ៖ ចង់និយាយថា ចាត់ទុកដូចថាខឹងដែរ ។

ពត ៖ បាទ!

ដារ៉ា ៖ ដូចថាអ៊ំមិនបាន អ៊ំស្ថិតនៅជាចន្លោមជាកម្មាភិបាលចឹង ប៉ុនមិនបានប្រព្រឹត្តចឹង?

ពត ៖ បាទ! អត់បានប្រព្រឹត្ត ។

ដារ៉ា ៖ ដល់បានព្ញត៍ត៏មានព្ញអីចឹងទៅ វាធ្វើឲ្យប៉ះពាល់ដល់សតិអារម្មណ៍អ៊ំដែរ?

ពត ៖ បាទ! សតិអារម្មណ៍ ។

ដារ៉ា ៖ មិនចឹង?

ពត ៖ បាទ! ហើយចឹងចង់ឲ្យកាត់ ចង់ឲ្យវែក ចង់ឲ្យមើលឃើញយ៉ាងម៉េច ពីព្រោះពេលនឹងពេល៧០ ពេល៧១ដែលខ្ញុំបានចូលធ្វើការហើយទៅរៀន ឬកម្មាភិបាលមកពីហាណូយម៉ាចំនួន ខ្មែរយើងប៉ុនមិនដឹងទៅយកពីពេលណារៀន ។ ពេលណារៀនតាំងពីមេទ័ពមេអីរៀន ប៉ុនខ្មែរទេណា ប៉ុនដល់យូរៗទៅបាត់ ។

ដានី ៖ អ៊ំខ្ញុំចង់សួរ អ៊ំបកតិច ខ្ញុំអត់ទាន់ច្បាស់កន្លែងអ៊ំ ពេលដែលអ៊ំធ្វើគេចាត់តាំងឲ្យអ៊ំធ្វើជាប្រធានរណសិរ្សស្រុក អឺ!ឃុំដាំងទង កាលនឹងអឺ!មានគ្នាប៉ុន្មាននាក់ទៅអ៊ំកាលនឹង?

ពត ៖ កាលនឹងខ្ញុំៗ មានខ្ញុំប្រធាន បន្ទាប់មកមិត្តហួនៗអនុប្រធានៗ ហើយសមាជិកតាវ៉ាំងៗប៉ុនស្លាប់ហើយ ។

ដានី ៖ ហួនៗ?

ពត ៖ ហួនក៏ស្លាប់ដែរ ហួននឹងនៅត្រពាំងធំ នៅប្រគៀត ។ ប៉ុនជំនាន់នឹងឃុំដាំងទង២០ប៉ុន្មានភូមិទេ ២៦ភូមិហើយមិនដឹង មិនទាន់កាត់ភូមិទៅចេះទេ ។

ដានី ៖ កាលជំនាន់នឹងដូចថាអ៊ំទៅប្រជុំ ដូចមានយាយចែម ដូចមានយាយចែម មានតាទិតអី ដូច អ្នកផ្សេងៗច្រើន កាលនឹងគាត់នៅក្នុងឃុំដាំងទងតែមួយ ឬក៏យ៉ាងម៉េច?

ពត ៖ ដែលចេះគេក្នុងក្របខណ្ឌស្រុកគេហៅទៅរៀននៅនោះ ហើយយាមចែមកំណើតគាត់នៅដាំងទង ។ ដាំងទង ប៉ុនគាត់ទៅរៀនពីគណៈកៀរគរនារីឃុំទេ មុនដំបូង ។

ដានី ៖ ឃុំដាំងទង?

ពត ៖ បាទ! ឃុំដាំងទងនឹង ដល់ហើយទៅបានខាងតំបន់នឹងហៅគាត់ទៅ ដល់ក្រោយមកចាត់តាំងគាត់ទៅខាងស្រុកណា ស្រុក១០៦មិនដឹងទេ អានឹងប្រវត្តិយាយចែមនឹង ។ ប៉ុន ប្តីគាត់ ឈ្មោះតាញ៉ែមនឹងជាអ្នកតស៊ូក្នុងព្រៃជំនាន់៦០ឆ្នាយនោះ ។ ហើយយាយចែម នៅនេះ ហើយខ្ញុំអត់ដែរស្គាល់ទេ ព្រោះខ្ញុំគេម្តុំក្បាលអូរនឹង គេជំនាន់នឹងដែរ អឺ!ជា កម្មាភិបាលមួយលេចមុខ លាក់ក្បាលអូរនោះ សាច់ឈាមបងអឿកនឹង ។ ហើយតាទិត នេះ គឺខ្ញុំបានដឹង អឺ!មុនដំបូងគាត់មិនមែនជាមេភូមិ ឬមេឃុំអីទេ ប៉ុននៅក្នុងក្របខណ្ឌ គាត់នឹងប្អូនថ្លៃ តាម៉ុក ដល់ហើយគេឲ្យធ្វើជាចៅហ្វាយស្រុក ។ ប៉ុនមិនមែនជាចៅហ្វាយ ស្រុកទេ គ្រាន់ទៅរួមការងារជាមួយគេ ប៉ុនមិនដឹងស្រុកណាទេ ដល់ក្រោយទៅបានទៅ នៅគិរីវង់ តាទិតនឹង ។ ហើយឡើងទៅរៀននឹងគឺ កម្មាភិបាលឃុំត្រឹមលេខាឃុំ ប្រធានឃុំ នឹងម៉ាស្រុកត្រាំកក់នឹង ខេត្តតាកែវ មកទាំងអស់គ្រប់ស្រុក ហើយកងទ័ពគ្រប់កងវរៈ គ្រប់ស្រុកកាលនឹង មានស្រុកកោះអណ្តែត ស្រុក១០៦ ខាងតានីអី នឹងហើយនឹង ត្រាំកក់ ។

ដានី ៖ ចុះមួយទៀត ដូចថាពេលនឹងមានយន្តហោះ មានប៉េ៥២ទម្លាក់អីចឹង?

ពត ៖ បាទៗ ។

ដានី ៖ មានទាហាន មានអីវ៉ៃជាមួយខាងកងទ័ពខ្មែរក្រហមមិនចឹង?

ពត ៖ បាទ!

ដានី ៖ បាទ! កាលនឹងអ៊ំមានដែលឮព័ត៌មានដូចថាខាងទាហាន ថាពួកអាមេរិចកាំងអីវ៉ៃថាធ្វើរដើង អីមានចាប់បានចាប់អីទាហាន ឬពួកអ្នកកាសែតអាមេរិចកាំងអី?

ពត ៖ អត់ទេៗ ។

ដានី ៖ អត់ដែលឮទេ?

ពត ៖ អត់ទេ នៅក្នុងនេះ អត់ទេ ។

ដារ៉ា ៖ អឺ! ម្សិលមិញខ្ញុំជួបអ៊ំអឿក?

ពត ៖ អឺ អឿក!

ដារ៉ា ៖ បាទ! គាត់ថា គាត់នៅក្នុងភូមិនមោនឹង គាត់ដូចថាធ្លាប់មានពួលេចពាក្យដូចថាព័ត៌មានខ្លះទាក់ទងនឹងការចាប់បានជនស៊ីវិល ពួកស្បែកសស្បែកអីនឹង ហើយអ៊ំបានឮចឹងដែរ នៅក្នុងភូមិអ៊ំ?

ពត ៖ អត់ទេ គ្មានទេ ។

ដារ៉ា ៖ កាលនៅក្នុងឆ្នាំ៧២ ៧៣ដែលអ៊ំនៅក្នុងភូមិ?

ពត ៖ អត់ទេប្អូន អត់ទេ ៧២ ៧៣ខ្ញុំធ្វើការនៅឃុំជាងទង បើចាប់បានដឹងហើយ អត់ទេក្នុងឃុំប៉ុន្តែក្រែងនៅឯណាក្រៅពីឃុំជាងទង ប៉ុន្តជាងទងអត់ទេ ។ អត់ទេកូនប្រទ្បំទេ ក្រែង៧១ ៧២ ៧៥ នៅក្នុងសង្គ្រាម គ្មានបរទេសណាអត់ទេ ។

ដារ៉ា ៖ ដែលមានដូចថាចាប់នឹង ដូចថាចាប់នៅតាមអាដ្ឋវជាតិលេខ៣យើង ពីអន្លុតាសោមភ្នំពេញណា?

ពត ៖ បាទៗ ។

ដារ៉ា ៖ ដែល តែមិនច្បាស់លាស់?

ពត ៖ អូ! អត់ទេ មិនចឹង ។ បើនៅក្នុងក្របខណ្ឌ ដែលដីយើងគ្រប់គ្រងជាងទងគ្មានទេ ប៉ុន្តែក្រែង មាននៅខាងគូស ញ៉ៅញ៉ូង ខាងអីត្រពាំងធំអីអត់ដឹងទេ ។

ដានី ៖ ចុះអ៊ំមួយទៀតដូចរបៀបគេចាត់តាំងកម្មាភិបាល ដូចថាយើងគេចាត់តាំងគេរើសតាមខ្សែតាមអីដែរ ឬយ៉ាងម៉េច?

ពត ៖ គេរើសតាមខ្សែដែរ ។

ដានី ៖ ខ្សែយ៉ាងម៉េចអ៊ំ?

ពត ៖ ខ្សែទៅតាមវណ្ណៈ ធាតុវណ្ណៈ ។

ដានី ៖ ធាតុវណ្ណៈ?

ពត ៖ បាទ! ធាតុវណ្ណៈ ហើយខ្ញុំនេះ បើសិនណាគេដឹងរឿងពិត គេមិនត្រូវយកប្រើទេ ពីព្រោះឪពុកខ្ញុំស្មៀនឃុំជំនាន់បារាំង ។ ចឹងគេចាត់ទុកខ្ញុំជាអ្នក ព្រោះគាត់ចេះលេខចិន ពីដើមគេហៅក្បាច់ចិន ហើយគាត់ជាមនុស្សមួយធ្វើអាចារ្យ ហើយជាមនុស្សត្រឹមត្រូវ ប៉ុន្តខ្ញុំនេះរៀនសូត្រតាម ចង់និយាយថាមានកម្រិតវប្បធម៌ប៉ុននឹង គេចាត់ទុកជាអនុធនហើយណាគេអត់ត្រូវការទេ ។ ប៉ុន្តដោយធាតុវណ្ណៈនេះវាក្រ ពុកខ្ញុំក្រគាត់អ្នកកាន់សីល ហើយកូនគាត់ច្រើន ។ ចឹងក៏គេចាត់តាំង ដល់ចាត់តាំងហើយបានគេដឹងក្រោយៗចឹងទៅ ខ្ញុំក៏ដឹងខ្លួន

ឯងដែរ ដល់សិក្សាពីវណ្ណៈរៀនសូត្រពីមាគ៌នឹងក៏យើងសម្រាបខ្លួនតាមនឹងទៅណាប្អូន អានឹងចឹង ។ តែដល់ប្អូនឯងសួរថាទៅតាមខ្សែថាខ្ញុំអត់លាក់ទេ ។ គឺខ្សែទៅតាមខ្សែមែន ឧបមាថាប្អូនឯងជាប់និន្នាការជាខ្មែរក្រហមតស៊ូសំងាត់ក្នុងព្រៃចឹងទៅណា ហើយដល់ហើយចឹងទៅ គេយកក្មួយយកកូន យកតាមខ្សែនឹង ។ ឯសំខាន់បំផុតទៅទៀតនឹងក្នុងភូមិនឹងដែរ ។ បើអ្នកណាវណ្ណៈក្រីក្រអានេះ គឺខ្សែមាគ៌បក្សកុម្មុយនីសកម្ពុជាត្រូវអនុវត្តចឹងម៉ង ។ ទោះបីមនុស្សនឹងអត់ចេះអក្សរ ម៉ាតួក៏គេយកអានឹងដូចវណ្ណៈដាច់ខាតគេយក ។

ដានី : ចុះកាលនឹងនៅកន្លែងដូចថាយើងនៅក្នុងតំបន់រំដោះតាំងពីឆ្នាំ៧០មក ដូចថាកាលនឹងគេរៀបចំប្រជាជននឹងរបៀបដូចថា ជាសហករណ៍ ជារស់នៅផ្តុំគ្នាអីយ៉ាងម៉េច?

ពត : អត់ទេ គឺពេលនឹងគេបង្កើតជាក្រុមសាមគ្គីប្រវ៉ាស់ដៃៗនឹង ឧបមាប្អូនម៉ាគ្រួស (គ្រួសារ) ខ្ញុំ ម៉ាគ្រួសៗ ៥គ្រួសារ ឬ៦គ្រួសារជាម៉ាក្រុម ហើយថ្ងៃនឹងប្អូនឯងជីកឡូត៍ប្អូនឯង បងលាងបង្គឹរវែកឡូត៍ ស្អែកឡើងខ្ញុំទៅប្អូននោះ ទៅខាងស្អែកទៅប្អូននោះជាប់រៀងចឹងមក ។ ដល់ពេលស្ទូងក៏ចឹងដែរ ប្អូនឯងមានគោ ប្អូននោះមានគោ ខ្ញុំមានគោ ខ្ញុំអត់គោចឹងទៅ ក៏រួមប្រវ៉ាស់ដៃជាមួយគ្នានឹងធ្វើតាមនឹង ។

ដានី : ប្រវ៉ាស់ជួយគ្នាទៅវិញទៅមក ប៉ុន្តែផលស្រូវនឹងបានរៀងខ្លួនទេ?

ពត : បានរៀងខ្លួន ពេលនោះអត់ទាន់ប្រមូលទេ ។

ដានី : បាទ! ហៅសាមគ្គីប្រវ៉ាស់ដៃ?

ពត : បាទ! ក្រុមប្រវ៉ាស់ដៃ ។

ដានី : ដល់ឆ្នាំណាយើងទៅជាបង្កើតជាសហករណ៍ជារួម?

ពត : សហករណ៍កម្រិតទាប ឆ្នាំ៧៣ធ្វើម្តង ធ្វើម្តងខ្ញុំវឹសងាប់ ឯងបើកមិនចេះគិត បើកបាយរួមម៉ង បញ្ចូលគ្នាហើយហូបរួម ខ្ញុំដាក់ចំថ្ងៃលន់ នល់ធ្វើរដ្ឋប្រហារ ថ្ងៃ១៨ ។

ដានី : ៧៣?

ពត : ៧៣អី លន់ នល់ធ្វើរដ្ឋប្រហារឆ្នាំ៧០ហ៎ ថ្ងៃ១៨ ដល់ហើយធ្វើបាន២ថ្ងៃ ស្រាប់រំលាយ វិញនឹងម៉ង វាមិនចំណាទៅយកដាក់ថ្ងៃជ័យជំនះរបស់លន់ នល់ ហើយភៀសខ្លួនមក វាយការណ៍ងាប់បណ្តោយ ។ ហើយអត់បានជាគិត ធ្វើបានប៉ុន្មានភូមិ ក៏រំលាយព្រោះគេ ខាងភូមិគេដើរធ្វើមុន ភូមិមុន ខ្ញុំថាទុកឲ្យជុំវិញធ្វើឲ្យហើយចាំធ្វើជាងទងក្រោយគេទេ ប៉ុនឃើញ....ហ៊ឺព័ទ្ធទៅម៉ាប្រិបទៅ ។ ដល់ចប់សង្គ្រាម សហករណ៍រួម ៣ង

បែកវែកបាក់ ដាក់សហករណ៍ភាវូបនីយកម្ម ចប់សង្គ្រាម៧៥នឹងគឺបានបាយរួមៗហើយ ធ្វើរួមនេះ ហើយ រួមទាំងអស់ ។ល

ដានី: ដល់ពេល៧៣?

ពត: ៧៥ ។

ដានី: ចុះបងរបស់អ៊ំដែលថាជាប់នៅអី?

ពត: ២០៤ ។

ដានី: ២០៤ហ្នឹង យ៉ាងម៉េចដែរគាត់?

ពត: គាត់នៅរស់ដោយសារ អាហ្នឹងចង់និយាយថាកម្មាភិបាលខាងលើ គេយល់ឃើញថា បើកាលគេសម្លាប់បងខ្ញុំមួយទៅវាពាក់ព័ន្ធដល់ខ្ញុំ ដែលបម្រើចលនាហ្នឹងណា៎ ហើយប្អូនស្រីខ្ញុំ ២ បម្រើក្នុងចលនាបដិវត្តន៍នៅតំបន់រំដោះណា៎ ហើយនឹងប្អូនប្រុសខ្ញុំ១ ។ ចឹងគេទុកមួយហ្នឹង បើកាលណា៎គេដកមួយហ្នឹងវាប៉ះពាល់ដល់ទិន្នការ ។

ដានី: ច្រើន?

ពត: ច្រើន អញ្ចឹងគេអនុគ្រោះទៅ ។

ដានី: គាត់នៅរស់ដល់ឥលូវហ្នឹង?

ពត: នៅរស់ដល់ឥលូវ ។

ដានី: ដល់ពេលអ៊ំផ្លាស់ទៅកំពង់ស្ពាយ កាលហ្នឹងអ្នកណាដែលជាអ្នកមកចាត់តាំងផ្លាស់ឲ្យអ៊ំទៅ?

ពត: ខាងហ្នឹងឯកភាពតាំងពីភូមិភាគមក អាហ្នឹងខ្ញុំមិនដឹងទេតែខ្សែហ្នឹងអនុវត្តតាមភូមិភាគ គណៈតំបន់គ្មានសិទ្ធិទេ គណៈស្រុកគ្មានសិទ្ធ អញ្ចឹងគឺមជ្ឈឹមមកតែម្តងត្រូវដកកម្មាភិបាល ។ ជាងទងនេះទៅខ្ញុំ ទៅមិត្តញ៉ែននេះ ២នាក់ ហើយនឹងប៉ុន្មាននាក់ទេ ដែលទៅហើយយកពីស្រុក១០៦ យកពីត្រពាំងធំជើង ត្រពាំងធំត្បូងទៅហ្នឹងចឹងទេ ។ ដូច្នេះ ចង់និយាយថាគេរកឱកាសគេ គេរកតម្លៃបុគ្គលណា ប៉ុនបើតាមរយៈហ្នឹង គឺស្រុកនឹងហើយមកប្រាប់ហើយណា៎ ថាអ្នកឯងត្រូវទៅ ។

ដានី: ស្រុកកាលជំនាន់ហ្នឹងកូនតាម៉ុកដែរ ឈ្មោះ ខុម ហ្នឹង?

ពត: ខុម ហ្នឹងកូនតា ម៉ុក លេខា កាលហ្នឹងមាន តាជឹម, តាគៀវ ។

ដានី: អញ្ចឹងនៅជាងទង គ្នា៣នាក់ហ្នឹង ទៅផ្លាស់ទៅកំពង់ស្ពាយទាំងអស់ឬក៏តែអ៊ំទេ?

ពត: ផ្លាស់ទៅតែខ្ញុំទេ ដល់ក្រោយមកគេទទួលការងារក្រោយមានពីណាគេទេ បន្ទាប់ខ្ញុំ មាន យាយ បឿន ។

ដានី: យាយ បឿន ហ្នឹងឈ្មោះរ៉ាំង ឈ្មោះអីរ៉ាំង ឈ្មោះ ហួនអីនឹង?

ពត: មិនដឹងទេ មិនដឹងគេផ្លាស់ឈ្មោះម៉េចទេ ប៉ុន្តែកាលហ្នឹងនៅឃុំគេហៅយាយ បឿន ។

ដានី: យាយ បឿន?

ពត: បាទ! ប្រពន្ធតា ជន ។

ដានី: ប៉ុន្តែកាលជិនាន់អ៊ំមានគ្នា៣នាក់ មានអ៊ំហើយមានឈ្មោះអីទៀត?

ពត: កាលជំនាន់ខ្ញុំជម្រាបត្រង់ ដែលខ្ញុំទទួលប្រធានរណសិរ្សឃុំដាំងទង់ហ្នឹងគឺខ្ញុំហើយមិត្ត ហួន ទៅរ៉ាំង ប៉ុន្តែដល់ពេលហើយទៅខ្ញុំទទួលឆ្នាំ៧១ហ្នឹង ដល់ពេលឆ្នាំ៧២ចុងហ្នឹង ក៏គាត់ឃុំដាំងទង់នេះត្រឹមថ្នល់ហ្នឹង ខាងលិចនេះទៅត្រពាំងធំខាងជើង អញ្ចឹងមិត្តហួន ក៏ដកទៅនោះខ្ញុំនៅដាំងទង់ក្នុងនោះមានមិត្តរ៉ាំងមួយមក ។

ដានី: រ៉ាំង គាត់នៅ?

ពត: គាត់ស្លាប់ហើយ ។

ដានី: ប៉ុន្តែគាត់បានផ្លាស់ទៅកំពង់ស្វាយដែរ?

ពត: អត់ទេ ។

ដានី: អត់ទេ?

ពត: ទៅតែខ្ញុំទេ ហើយមិត្តរ៉ាំង នឹងនៅនេះ ប៉ុនមុនខ្ញុំទៅកៀនស្វាយ រ៉ាំង ហ្នឹងគេដកទៅណាឃុំគោកព្រេចគីរីវង់នោះ ដកទីណាត់ណែងហើយ ។

ដានី: បាទ! ដល់ចឹង ពេលអ៊ំដកទៅកំពង់ស្វាយ យាយបឿន គាត់?

ពត: គ្រប់គ្រងនៅនោះ ។

ដានី: គ្រប់គ្រងនៅហ្នឹង?

ពត: បាទ!

ដានី: មួយទៀត ខ្ញុំឃើញតាមខ្ញុំជួបមកតាមដឹងដូចថា នៅស្រុកកៀនស្វាយហ្នឹង ពីខាងឃុំដាំងទង់យើងទៅច្រើនមែនទែន?

ពត: ទៅក្នុងប្រជាជនទៅច្រើនដែរ ហើយកម្មាភិបាលនីមួយៗក៏ទៅពីដាំងទង់ទៅដែរ ។

ដានី: ហើយដូចជាយាយបូរ ក៏គាត់ជាអ្នកនៅដាំងទង់ដែរ?

ពត: បាទ!

ដានី: ហើយដូចតា អឿក?

ពត: តា អឿក នៅដាំងទង់ដែរ ។

ដានី៖ ចុះមូលហេតុអីបានជាអ្នកជាឥទងទៅស្រុកកៀនស្វាយច្រើនម្លេះ?

ពត៖ អាហ្នឹងវាពិបាកយល់ដែរអូន ព្រោះខាងលើគេតម្រូវហើយ..... ប៉ុន្តែទៅជំនាន់ខ្ញុំទៅតែខ្ញុំទេ ជាឥទង ហើយមានតាញ៉ែននេះមួយនឹងកម្មាភិបាល ជាបក្សជនណា៎ ហើយទៅទទួលឃុំនៅ គេទទួលជាសមាជិកឃុំនៅព្រែកថ្មីអីក៏មិនដឹងទេ ញ៉ែនហ្នឹង ប៉ុនឥលូវស្លាប់ហើយ ។ អាហ្នឹង សុទ្ធតែជាអ្នកដាច់ខាតដែរហ្នឹងណា៎ ហើយជាឥទងមានតែខ្ញុំទេ ។ អ៎ហើយ ប៉ាក់មួយដែរ ប៉ាក់ ហ្នឹងក៏ស្លាប់ដែរ ស្រឡាញ់ស្រុកហើយ ។ ប៉ាក់ហ្នឹងប្អូន អៀក នឹងហើយទៅពីកៀនស្វាយទៅ ។

ដានី៖ អញ្ចឹងពេលដែលអ៊ំទៅដល់កំពង់ស្វាយ អញ្ចឹងពេលហ្នឹងអ៊ំធ្វើជាលេខាឃុំបានរយៈពេលប៉ុន្មានបានជាអ៊ំថាធ្លាក់?

ពត៖ ១ឆ្នាំគត់ ។

ដានី៖ ១ឆ្នាំគត់ហ្នង?

ពត៖ បាទ!

ដានី៖ ចុះអ៊ំពេលអ៊ំដូចថាពេលដែលគេមានបញ្ហា គេចោទថាអ៊ំខុសសីលធម៌ជាមួយប្រពន្ធទាហានសក្តិ៥ហ្នឹង កាលហ្នឹងគេមានប្រុងចាប់អ៊ំចាប់អីដែរអត់?

ពត៖ ប្រុងដែរ ប៉ុនក្នុងករណីមួយគឺវានៅក្នុងរូបភាពខាងស្រីៗវាអត់មានអ្នកណាប្រតិកម្ម ហើយប្រជាជនហ្នឹងគេនេះខ្ញុំ គេស្តាយខ្ញុំ គេនេះខ្ញុំគេអត់មានឃើញការពិត ដល់ពេលអត់មានឃើញការពិត ។ អត់ឃើញការពិតអញ្ចឹងគេទុកតាមដាន ។ ដូច្នេះគេឲ្យខ្ញុំមកនៅបឹងខ្សាងកៀនស្វាយ នៅកណ្តាលស៊ឹងនេះ ។

ដានី៖ តែកាលហ្នឹងដូចថាមានអ្នកណាជួយអ៊ំ ឬដូចថាខាងក្នុងជួរស្រុកជួរអី គេមានមកដូចថាជួយអ៊ំ ដូចអនុគ្រោះ អ៊ំដែលអ៊ំមកពីស្រុកជាមួយគ្នាដែរអត់?

ពត៖ អត់មានទេៗ ។

ដានី៖ អត់ទេ?

ពត៖ គេមានតែសង្កត់ថែម ព្រោះយាយបូរនឹងចៅហ្វាយស្រុកណា៎ ខ្ញុំជាមនោសញ្ចេតនា ខ្ញុំយល់អញ្ចឹងជារឿងពិត ។ អញ្ចឹងនៅក្នុងឃុំជាឥទង អឺ!នៅក្នុងលេខាឃុំកំពង់ស្វាយហ្នឹងណា៎ ខ្ញុំវិភាគ បើខ្ញុំមិនវិភាគគឺខ្ញុំត្រូវស្លាប់ហើយ ។ ពេលនឹងមានអនុលេខាគឺ តាអែលៗហ្នឹងកាលហ្នឹងនៅឃុំនៅស្រុក១០៦ ហើយយាយបូរ មុនទៅកៀនស្វាយហ្នឹង ទៅធ្វើចៅហ្វាយស្រុកនៅ១០៦ណា៎ ។ អញ្ចឹងក៏ខ្ញុំ តាអែលហ្នឹងគាត់ចង់មានទស្សនៈមុខមាត់ៗ

ក៏លេងខ្ញុំ ហើយខ្ញុំដឹងថាកូនខ្ញុំចៅហ្វាយស្រុកនៅហ្នឹងតាមួយនោះ ប៉ុនគេថ្ងៃក្រោយមកគេយកគាត់ទៅធ្វើបាប ទៅដូចស្លាប់តានឹងឈ្មោះ តាហាក់ ។ គាត់ខ្សឹបប្រាប់ខ្ញុំថា "មិត្តពតឯងគេតម្រូវហើយ ទៅចុះឡើងពីសមាជិកស្រុក" ប៉ុនមិនដឹងស្រុកណាទេ ប៉ុន្តែដាច់ខាតត្រូវតែទៅហើយ ។ ហើយខ្ញុំថាស្រុកមិនស្រុកអីលោកអើយ ។ ដល់ហើយចឹងខ្ញុំឃើញខ្ញុំនិយាយឲ្យត្រង់ ខ្ញុំលាក់អត់លាក់ទេ ខ្ញុំឃើញឯកសារត្រៀម ពេញសិទ្ធិ ធ្វើចំពោះប្រជាជនបែងចែកនេះ ។

ដាវ៉ា: ក្នុងឆ្នាំណាអ៊ំ?

ពត: ឆ្នាំ៧៦ចូល៧៧ ដូចថាក្នុងពេលហ្នឹងគេសម្រិតសម្រាំងណាស់ អ្នកថ្មីអ្នកចាស់ វាខុសពីគោលការណ៍ ខ្ញុំឃើញថាវេទនាណាស់ ដល់ចឹងខ្ញុំត្រូវតែមិនអាចរុលទៅមុខបានទេ ព្រោះឪពុកម្ដាយខ្ញុំ បងខ្ញុំ ឃើញក៏មិនមែនថាតម្រូវចិត្តពេលនេះដែលនេះ ខ្ញុំមានមោទនៈអីគេសប្បាយចិត្ត ។ ខ្ញុំថាធ្វើម៉េចឲ្យតែមានបាយស៊ីខ្ញុំទទួល អត់មានចង់បានមុខមាត់បុណ្យសក្តិអីទេ ។ ចឹងក៏ពេលនឹងគេស្នាមម៉ាតិចនឹង ក៏គេរុញថែមមក ហើយចឹងបានមករស់នៅ ។

ដានី: ចុះអ៊ំកាលនឹងអ៊ំធ្លាប់ជួបតា អឿក អត់?

ពត: តាអឿក ហ្នឹងនៅជាមួយគ្នា ប៉ុន្តែមិនមែននៅជាមួយខ្ញុំទេ គាត់នៅខាងកៀនស្វាយ ត្រូវតាអឿក ហើយយាយបូរ ហ្នឹងជីដូនមួយ ។ គេឲ្យតាអឿក ហ្នឹងនៅខាងពាណិជ្ជកម្មសម្រាប់ចែករបស់របរអីហ្នឹង ។ ហើយ តាអឿក ហ្នឹងមិនមែនជាបក្សជនទេ ជាជនចម្រើនទេ ។

ដានី: ជាជនចម្រើន?

ពត: ជាជនចម្រើន ជាសមាគមន៍កសិករកម្ពុជាប្រជាធិបតេយ្យ វាមានអញ្ចឹង ។ ហើយបើនារីវិញ គេហៅសមាគមន៍នារីកសិករកម្ពុជាប្រជាធិបតេយ្យ ។ បើយុវជន យុវកកនឹងដូចថាយុវជនកម្មុយនីស្ត កម្ពុជាប្រជាធិបតេយ្យ អាហ្នឹងវាមានថ្នាក់កម្រិតវាអញ្ចឹង ។

ដានី: ចុះពេលអ៊ំទៅធ្វើការនៅកំពង់ស្វាយហ្នឹងខស្សប្រាហ៍ជួប ខស្សប្រាហ៍និយាយអីជាមួយតាអឿកដែរ?

ពត: អត់ទេ បានជួបដោយសារអញ្ចេះទេ ឆ្ងាយដែរ ព្រោះតាអឿក នៅគគីរនោះហ្នឹង ហើយពីកំពង់ស្វាយនឹង បើឆ្លងកាត់មកគគីរហ្នឹង គឺត្រូវទៅតាមស្រែអំពិលចឹង ទៅតាមផ្លូវហ្នឹងបត់ទៅខាងកើត១នេះ ទៅអញ្ចឹងទៅឡើងទៅថ្នល់ជាតិលេខមួយហ្នឹង ខាងកើតឃុំដីឥដ្ឋ ហើយបានបកមកខាងលិចវិញ ហើយដល់ទៅចូលប្រជុំ១ហើយជួបគ្នាមួយភ្លែត ដូចថាគេ

ត្រូវចែកអី ដូចជាសំបកកង់ឬក៏ចែកស្ពឺបានទៅយកគាអឿក ហ្នឹងឲ្យជួបពីកន្លែងគាអឿក គេអ្នកបញ្ចេញឲ្យប៉ុណ្ណឹងទេ សុំទោស ។

ដានី: ចុះអ៊ំពេលដែលអ៊ំមានរឿងខាងខុសសីលធម៌ មានដែលជួបគាត់ទៀតទេ?

ពត: អត់ទេ ។

ដានី: អត់ទេ?

ពត: ពេលឃើង អូនឯងចាំហើយពិតរឿង អូនឯងក៏ដោយបងក៏ដោយ តែកាលណាបងមានរឿងអញ្ចឹងអូនឯងសុខចិត្តទឹកភ្នែក ឬបែរមុខចេញអត់ហ៊ានសួរទេ ពាក់ព័ន្ធៗ ខ្លាចពាក់ព័ន្ធ ។

ដានី: ខ្លាចពាក់ព័ន្ធ?

ពត: បើមិនអញ្ចឹងទេ គេយកខ្ញុំទៅគេតាមដានអូនឯងទៀត ដូចគេថាក្បាលអ្នកណាសក់អ្នកហ្នឹង អានេះខ្ញុំប្រាប់ត្រង់ ។

ដានី: ចុះអ៊ំមួយទៀត ម៉េចបានដូចថាកាលហ្នឹងអ៊ំទៅកៀនស្វាយ ដល់ពេលអ៊ំមានខុសសីលធម៌ ទៅគេផ្លាស់អ៊ំមកបឹងខ្យាង មកស្រុកកណ្តាលស្ទឹងវិញ?

ពត: បាទ!

ដានី: ម៉េចបានជាគេផ្លាស់ចេញពីស្រុកកៀនស្វាយ?

ពត: គេផ្លាស់ហ្នឹងវាអញ្ចេះ កាលណានៅនោះបើរឿងហ្នឹងពិតខ្ញុំអស់ឥទ្ធិពលធ្វើការនៅកន្លែងនឹង ដូច្នេះគេត្រូវដកៗមក គេតាមដានពីក្រោយ ។ បើរឿងហ្នឹងវាពិតគេតាមដាននៅនោះផង នៅនេះផង ។ បើរឿងហ្នឹងវាពិតគឺគេរុញ ប៉ុន្តែពេលនោះខ្ញុំដឹងថាខ្ញុំវាអត់មានវា ចឹងខ្ញុំអត់មានបានទៅប្រឡាក់ប្រឡូក ចឹងអ៊ីដែលគេលុតដំគឺត្រូវធ្វើម៉េចឲ្យតែមានបាយហូប ស្មោះត្រង់ទៅគឺនេះទៅដើម្បីរស់ណា យើងអត់ប្រតិកម្មពីរឿងបុណ្យសក្តិ មុខមាត់ ។

ដានី: បើតាមអ៊ំយល់គិតខ្លួនឯង ដូចថាខាងដូចថាកម្មាភិបាលខ្មែរក្រហមថ្នាក់លើ មានមនោសញ្ចេតនា ដូចថានេះ ពេលដែលអ៊ំខុសសីលធម៌ គេចោទថាអ៊ំខុសសីលធម៌ហ្នឹង គេត្រូវយកអ៊ំទៅសម្លាប់ឬក៏គេមានមនោសញ្ចេតនាជាមួយអ៊ំ បានគេផ្លាស់យកទៅអ៊ំទៅខាងបឹងខ្យាង?

ពត: មុនដំបូងគេត្រូវពិនិត្យសិនដែរ ។

ដានី: ត្រូវពិនិត្យសិន?

ពត៖ បាទ! គេពិនិត្យ ហើយគេតាមដានណ៎ ពីព្រោះកម្រិតពីព្រោះវាសីលធម៌ហ្នឹងគេត្រូវពិនិត្យចឹងទៅ បើកាលណាយើងឃើញខ្សែស្រឡាយរបស់យើង ចង់និយាយថាអញ្ចេះណាយើងចាត់តាំងកម្មាភិបាលក្រោមថ្នាក់របស់យើងនេះបានល្អ ។ ដូច្នេះបើគេដកខ្ញុំម្នាក់ទៅសម្លាប់ កម្មាភិបាលថ្នាក់ក្រោមដែលខ្ញុំបានចាត់តាំងនេះ វាត្រូវស្លាប់ម្ដែរ អានឹងត្រូវដកសិទ្ធណ៎ ។ ហើយអញ្ចឹងកម្មាភិបាលដែលយើងមាគ៌ាចាត់តាំងនេះ កម្មាភិបាលជាបក្សជនគេសមាគមន៍-កសិករកម្ពុជានេះ យើងអប់រំគេហើយ អប់រំគេនឹង គេឃើញកម្លាំងខ្ញុំនេះវាល្អដែរ ...........(ខ្យល់) អញ្ចឹងគេទុកតាមដានកសាងយើង ។

ដានី៖ ចុះអ៊ីកាលហ្នឹងគណៈស្រុកកណ្ដាលស្ទឹងពីណាគេ?

ពត៖ គណៈស្រុកកណ្ដាលស្ទឹងមិនមានរឿងអីដែរ............(ខ្យល់) ខ្ញុំមកដល់មានតាគ្រុយ ពេលខ្ញុំទៅរៀនស្មាយខ្ញុំជួប តាគ្រុយ បានពីរខែដែរ ជួបបាន២ខែ ៣ខែ គេដកគាត់មកនៅកណ្ដាលស្ទឹង ។ ដល់ដកគាត់មកនៅកណ្ដាលស្ទឹង ខ្ញុំនៅជាមួយគាត់បានប៉ុន្មានខែក៏បាត់តាគ្រុយហ្នឹងទៀតទៅ ។ ហើយជំនាន់ហ្នឹងមានអ្នកណាទេ ដូច្នេះអស់ពីតាគ្រុយទៅ តាយ៉ាន់ទៅពីស្រែក្នុងដែរ ទៅធ្វើជាចៅហ្វាយស្រុកនៅនឹងយ៉ាន់ ។

ដានី៖ កាលហ្នឹងដែលឮឈ្មោះ តាអាន ទេ គណៈស្រុក?

ពត៖ តាអាន ហ្នឹងខ្ញុំមកជួបនៅ ជួបហើយជួបប៉ុនអត់ដឹងទេ គេដកគាត់ទៅណាស្រុកបូព៌ា តាអានហ្នឹង គ្រាន់តែឃើញទេ ។ ប៉ុនតាអាននឹង មុនខ្ញុំនៅឮថានៅកណ្ដាលស្ទឹងហ្នឹងមិនដឹងតា អាននឹង នៅម្ដុំដើមបុសនៅម្ដុំអីនឹង ខ្ញុំវាមិនបានដឹងដែរ ។

ដានី៖ ដល់ពេលអ៊ីទៅគេគាត់មកសិន?

ពត៖ បាទ! ដកបាត់ហើយ ។

ដានី៖ ដកមកខាងណាវិញ?

ពត៖ មិនដឹងទៅណាទេ តាអាន ហ្នឹង ។

ដានី៖ តែឮឈ្មោះគាត់ដែរ?

ពត៖ ឮតែឈ្មោះ មុនតាគ្រុយ ហ្នឹងមកដល់ដូចតាអាន ដូច្នេះហើយបាត់ទៅនេះ អត់នេះតាអាន ។

ដានី៖ ដែលស្គាល់មុខគាត់ទេ ឃើញមុខ?

ពត៖ ទេ! ដូចជាអត់ទេប្អូន តាអានហ្នឹងដូចជាខ្មៅ អត់ហ៊ានសួរកាលណាបានមួយៗពីរនេះ បើជួបអូនឯងអញ្ចឹង អត់ហ៊ានសួរឈ្មោះទេ ។ វរៗគេថាចង់ដឹងឈ្មោះសម្រាប់ខ្ចាថាធ្វើ

ឃាតធ្វើអីហ្នឹងណា៎ ។ តួនាទីរបស់ម្នាក់ហ្នឹង ជាចៅហ្វាយស្រុកចៅហ្វាយអី មិនហ៊ានសួរទេ …(ខ្យល់) ដល់គាត់ចូលប្រជុំបើកខទ្វេសនាមឯកសារហ្នឹងបាន យើងដឹងថាអ៎ានឹងចៅហ្វាយស្រុក បើពីក្រៅគ្រាន់តែឈរនឹង អត់ហ៊ានសួរទេ ។

ដានី: ដឹងថាគាត់អ្នកមកពីស្រុកខាងណាដែរ?

ពត: តា អាន ហ្នឹង?

ដានី: បាទ!

ពត: មិនដឹងទេអូន អត់ដឹងទេ ពីព្រោះខ្ញុំនេះ ហើយខ្ញុំចរិតមួយវាអញ្ចេះផងអូន មនុស្សខ្ញុំមិនសូវហ៊ានទំនាក់ទំនងគេទេ ព្រោះចាញ់រូបគេទេ ចូលរួមក្នុងអង្គប្រជុំ មិនសូវបង្ហួបបង្ហើទេ ខ្ញុំគេថារៀបការ ខ្ញុំឯកសារធ្វើម៉េច រស់ម៉េច គេអ្នកបង្ហូរបង្ហើរឡេះឡោះអីជាមួយគេជាមួយឯងខ្ញុំអត់សូវដែរ ។

ដានី: ចុះតាប៉ូច ស្គាល់តាប៉ូច ទេ?

ពត: តាណា?

ដានី : តាប៉ូច?

ពត : ប៉ូច អត់ទេ ។

ដានី: គាត់ធ្វើឃុំដែរកាលហ្នឹង កាលមុនបែក៧៥?

ពត: ធ្វើនៅណា?

ដានី: ធ្វើនៅខាងកណ្ដាលស្ទឹងដែរ ខាងម្ដុំដើមឫស?

ពត: អត់ទេ កណ្ដាលស្ទឹងនៅខាង អឺ!តាប៉ូចនឹង ។

ដានី: គាត់ឈ្មោះទេព ប៉ូច ។

ពត: ទេព ប៉ូច កណ្ដាលស្ទឹង គេរាប់ពីនេះប្អូន កាលបងទៅ រាប់ដើមឫសអានឹងគេចាត់ទៅតំបន់ ខាងស្ដីនេះហើយ មានតែបាគូ, គង់ណយ, ឃុំបាគូ, គង់ណយ, វៀនថ្ម, តាខ្មៅ, អឺ! តាខ្មៅនឹង ហើយឃុំវៀនថ្ម, ហើយគង់ណយ ហើយនឹងបឹងខ្យាង, ព្រែកស្វែង ហើយនឹង ព្រែករកាថ្មី, ទ្រា អានឹងចឹង ហើយខាងលិចថ្នល់ជាតិលេខ៣នេះ ចាត់នៅណា ដើមឫស ដើមអីនេះ អត់ទេអត់ចូលទៅនឹងទេ ។

ដានី: បាទ! តាប៉ូច ដល់ពេលបែក៧៥ហើយ គេចាត់តាំងឲ្យគាត់មកធ្វើជាអនុលេខាស្រុកស្អាង ខាងស្អាង ខាងស្រុក១០?

ពត: តា ប៉ូច អត់ដឹងទេ ។

ដានី:	ចុះតាអានអី ដល់ពេលក្រោយៗមក មានដែលបានជួបគាត់?

ពត:	អត់ដែលទេ ។

ដានី:	អត់ដែលដឹងគាត់?

ពត:	អត់! តាអានៗ តាប៉ូច ហ្នឹងខ្មៅក៏ស?

ដានី:	គាត់សម្បុរប្រហែលអីដែរ ហើយមាឌគាត់រាងធំ?

ពត:	អត់អូន កាលហ្នឹងចេះបងមកពី កណ្ដាលស្ទឹង មកពីកៀនស្វាយមក កម្មាភិបាលហ្នឹងគេជួបគ្នាមួយភ្លែត អ្នកក្រៅអត់ទាន់ស្គាល់ឈ្មោះទេ ហើយដល់ហើយបែកគ្នាទៅ បែកនៅស្គាល់តែ កាលហ្នឹងទៅពីកៀនស្វាយទៅមកពីកៀនស្វាយ មនុស្សដែលនៅឃុំហ្នឹងនៅនឹងស្គាល់តែបីងខ្សាងនេះ ស្គាល់អាហៀង មួយហៀងនឹង ប៉ុនហៀងនឹង ស្លាប់ហើយ ។ ហើយដែលមកពីកៀនស្វាយមកតែ២នាក់ទេ ស៊ើន១ ហើយខ្ញុំមួយ ហើយនឹងនៅខាងកណ្ដាលស្ទឹង អំពៅព្រៃនឹង គឺកម្មាភិបាលដែលធ្វើការមុននឹងឈ្មោះ ចន មួយតែមិនដឹងគាត់ស្លាប់ឬរស់ទេ ។

ដារ៉ា :	ចន?

ពត :	ចនមួយ ហើយតាអីមួយ ហើយតាកេនឹងមួយ តាកេហ្នឹងប្រហែលស្លាប់ហើយៗ ព្រោះសុទ្ធជិនាន់នឹងអាណោចអាធោមណាស់ប្អូនអើយ ឃើញតាកេ ហ្នឹងក្រោយពីព្រឹត្តិការណ៍ហ្នឹង ដឹងថាបូញ៉ានោះចេះចុះ សុទ្ធតែមនុស្សម្នាក់ៗសុទ្ធគេមិនដឹងអ្នកណាម៉េចៗទេ ។ ហើយ តាកេ ហ្នឹងសដូចចិនអញ្ចឹង ។

ដានី:	ចុះអ៊ំមានស្គាល់ដូចថាកម្មាភិបាលណាដែលគាត់ទៅក្តាប់នៅខាងកណ្ដាលស្ទឹងមុនឆ្នាំ៧៥ទេ?

ពត:	អត់ដឹងទេអូន ។

ដានី:	ចេញពីខាងស្រុកយើងទៅ?

ពត:	អត់ ៧៥ មុន៧៥គ្មានទេ បើកងទ័ពខ្ញុំសួរទៅមានតានេះ ប៉ុនគាត់វៃត្រង់នឹង អីណាត តា ណាតហ្នឹងកងទ័ព ។

ដានី :	តាណាត?

ពត :	បាទ! តាណាតនឹងកងទ័ពនឹង សួរគេ ។

ដានី:	បាទៗ ចុះអ៊ំអី!មួយទៀតដូចថាកាលហ្នឹងអ៊ំគិតថាស្មើភាពទេ កាលសម័យបែកភ្នំពេញឆ្នាំ៧៥មក យើងមិនថាយើងស្មើភាព បាយរួមបាយអីអញ្ចឹង ដូចថារវាងកម្មាភិបាលហើយនឹងប្រជាជនយើងស្មើភាពគ្នាដែរឬអត់?

ពត: អត់មានស្មើភាពទេអូនអើយ អត់ស្មើភាពទេ បើនិយាយពីស្មើភាពអត់ទេ តាំងពីការហូបចុក ខ្វះនឹងកម្មាភិបាលគេឆ្អៀត ហើយគ្នាអ្នកនេះថ្មីចាស់បែងចែកគ្នាហូប ប៉ុនហូបៗបាយរួមហើយអានឹងគឺស្មើភាព។ ពាក្យបាយរួមនឹងវាពិបាកៗណាស់ បបរៗគ្នា។ ប៉ុនអាគេទិន្នាការរបស់ គេមូលដ្ឋានគេ អាចឆ្អៀតខ្សឹបខ្សៀវនេះគេនាយអាយវាអាចបានជាស្អុរបានជាអី ត្រង់ថាឲ្យស្មើភាពម៉ងអត់ទេ អានេះខ្ញុំអាចទទួលស្គាល់ចឹង។ ប៉ុនឃុំណា ដែលខ្ញុំទទួលខុសត្រូវខ្ញុំជឿថា ខ្ញុំអនុវត្តនៅនេះវាត្រូវវាអត់ ប្រពន្ធខ្ញុំវ៉ាន់ក៏ប្រហែលគេប្រហែលឯងដែរ អាហ្នឹងខ្ញុំចង់និយាយប្រាប់ចឹង។ ប្រជាជនឲ្យពិន្ទុខ្ញុំ ៧៩ចូលមក ឃុំនេះក៏គេអត់វិនិច្ឆ័យ ខ្ញុំខាងបឹងខ្យាងក៏អត់វិនិច្ឆ័យខ្ញុំ។ រហូតដល់រាល់ថ្ងៃគេតែមកសួរសុខទុក្ខខ្ញុំ គេថាចង់មកលេង អាមួយនៅបងប្អូនអាសែស គេធ្វើការនៅខាងបុស្តិ៍បាយ័នអីហ្នឹង គេមកតាមសួរខ្ញុំដែរ។

ដារ៉ា : ជាអនុស្សាវរីយ៍?

ពត : បាទ! អនុស្សាវរីយ៍ ដួយគ្នា។

ដារ៉ា : ធ្លាប់នៅអីចឹង កំសត់កំរ?

ពត : បាទ! កំសត់ កំរ។

ដានី: ចុះអ៊ីមួយទៀត ខ្ញុំចាប់អារម្មណ៍ត្រង់អ៊ីមានប្រសាសន៍មិញថា ត្រង់យើងមានសិទ្ធិ ដូចថាទាល់តែពអនុសាខាវាស្មើនឹងបក្សជន៩នាក់ បានយើងមានសិទ្ធិស្មើទៅខាងលើ?

ពត: ស្មើឡើង បាទ! ស្មើថ្នាក់លើ។

ដានី: ប៉ុន្តែតាមការអនុវត្តជាក់ស្តែងដែលអ៊ីធ្លាប់ចុះទៅអនុវត្តនៅតាមឃុំតាមអីហ្នឹង គេអនុវត្តទៅតាមហ្នឹងដែរ ឬក៏គេសម្រេចដូចថា ការចាប់ ការសម្លាប់អីនឹង គេសម្រេចនៅតាមឃុំតាមអីហ្នឹងខ្លួនឯង ឬក៏គេស្មើទៅខាងលើ?

ពត: ដែលចេះ ប្អូនត្រង់ហ្នឹង បានថាជីវិតមនុស្សប្រហែលជាអនុវត្តទៅតាមមួយព្រព្រិចភ្នែកម៉ាចុងបិច។ ប្អូនសួរហ្នឹងបងក៏ពិបាកឆ្លើយ ឬបើថាបងឆ្លើយទៅអូនថាខ្ញុំលាក់។ ប៉ុនចំពោះខ្ញុំមួយគឺគ្មានម៉ង ចំពោះឧបមាថាបើគ្នាខុសតិចតួចខុសឆ្គងអីនាយអាយណា ធ្វើមិនបានដូចគោលបំណងណា ខ្វះណាគេរាយការណ៍គេចង់បានមុខមាត់ គេថាអាហ្នឹងខ្មាំងអាហ្នឹងអីណា ចំពោះខ្ញុំអត់មានទេ អត់ទេ អត់ដែលមានរាយការណ៍ឡើងទេ អត់ទេ។ បើរាយការណ៍ គ្រាន់តែរាយការណ៍អញ្ចេះមែន បើថារដូវភ្លៀងផ្គរអញ្ចឹង ឬក៏អត់ពូជដាំភ្លៀងអត់មាន នៅឃុំនេះឃុំនោះ រាយការណ៍ប្រាប់គេចេះមែន។ តែចំពោះដូចអូនឯងជា

អនុធនសិស្ស ជាសិស្សអីខុសឆ្គងពាក្យសំដី ។ បើយើងតែកាលណាឃើញគេធ្វើខុសមួយភាគហើយណា៎ គេវិភាគ មេភូមិរាយការណ៍មក ហើយរាយការណ៍មកខ្ញុំថ្ងៃថ្ងៃៗថាម្នាក់ហ្នឹងមិនអត់ បេះអក្សរទេ ដូច្នេះអាការនិយាយខុសត្រូវអីតិចតួចយើងប្រដៅប្រដាំងហើយ ។ ដូច្នេះ ប្រតិកម្មអ្នកដែលគ្នាអ្នកបេះ គ្នាអាចមានមតិស្នើឡើង ឬជាយោបល់កែសម្រួលហើយ ។ ដូច្នេះយើងយកមតិហ្នឹង វិភាគថាគ្នាប្រឆាំងវាអត់កើត ។ ដូច្នេះបើក្នុងកម្មាភិបាលនេះ សម្រេចមនុស្សហ្នឹងនេះដកឡើង អាហ្នឹងហើយដែលយើងនេះ ។ ដូច្នេះខ្ញុំមានអំណាត់ ត្រង់ហ្នឹង វិភាគត្រង់ហ្នឹងដែរបាន ។

ដានី : ប៉ុន្តែនៅក្នុងឃុំអ៊ំ?

ពត : ប៉ុន្តែបេះសម្រេចដែលនេះ ខ្ញុំអត់បាននេះទេ ព្រោះគេចង់ហើយស្រេចហើយអូន ចង់គ្រាន់មានជាមាត៌ាឯកសារមក មានមតិស្នើឡើងប៉ុនគេចង់ហើយ ថ្នាក់ទាបថ្នាក់ក្រោមគោរពថ្នាក់លើ មតិភាគតិចគោរពភាគច្រើន បុគ្គលគោរពសមូហភាព ។ ហើយបើមានស្នើឡើង៣សាខា ម៉ាអនុមួយសាខាមាន ម៉ាសាខាមានសិទ្ធិស្នើឡើងមួយឃុំ អត់ដែលមាន ២៧នាក់បក្សជនទេអូន ។ វាមានរឿងអី គ្រាន់តែចង់មកមានឯកសារប៉ុន្តែឯកភាព ។

ដានីៈ ប៉ុន្តែ ការអនុវត្តអត់បាន?

ពតៈ បានស្អី បើមានបក្សជនណា២៧នាក់ ៩បីដង២៧នាក់ ហើយពេញសិទ្ធិទៀត រស់នៅក្នុងឃុំមួយហ្នឹង ។ ដូច្នេះ វាអត់ទេ ប៉ុនមានមុខធ្វើការ ឧទាហរណ៍ថាម៉ាឃុំហ្នឹងមាន៧នាក់ ឬ៥នាក់ណា៎ អ្នកនឹងមានប៉ុន្មានអត់បាន២អនុសាខាផង ។ តែចំពោះបើបក្សជនពេញសិទ្ធិនៅតាមភូមិៗ បើយើងមានកិច្ចការអីចង់ថាឲ្យបានមួយសាខាហ្នឹង ២៧នាក់នឹងហៅមកប្រជុំគ្នាចឹង យើងចង់ស្នើអីឡើងមួយអានឹងស្នើទៅ ។ ហើយពេលនឹង វាអត់មានរឿងអីៗស្នើផង មានតែដល់ពេលគេដាក់មកផែនការណ៍ម៉ាហិចតាតោន តែពូជស្រូវ៧ទឹក ។ អានឹងវា ។

ដារ៉ាៈ ចុះតាមភូមិមានបក្សជនទេដែរ?

ពតៈ មាន ។

ដារ៉ាៈ តាមភូមិតាមសហករណ៍ មានបក្សជនទៀត?

ពតៈ បាទ! មានៗបក្សជនទៀត បក្សជនជួនកាលមួយភូមិម៉ាសហករណ៍មានមួយ ម៉ាសហករណ៍នឹងមាន ។ ប៉ុនអាការស្ងាប់ហ្នឹង ខ្ញុំពិនិត្យមើលទៅវាបេះដែរ មិនមែនតែប្រជាជនទេ

បក្សជនក៏នាប់ដែរ ព្រោះអានាប់ហ្នឹងមកពីឆ្វេង ជួនកាលវាឆ្វេង វាអនុវត្តឆ្វេងធ្វើឲ្យគេខ្លាចធ្វើឲ្យប្រជាជនបះបោល អាហ្នឹងក៏។

ដារ៉ា : គ្រោះថ្នាក់ដែរ?

ពត : គ្រោះថ្នាក់ដែរ បក្សជនគ្រោះថ្នាក់ហើយអនុវត្ត។

ដានី: ចុះអ៊ីក្នុងឃុំអ៊ី ដូចមានមិនមែនតែអ៊ីម្នាក់ណា មានក្នុងនឹងមានសមាជិក៧នាក់?

ពត: ៧នាក់។

ដានី: ដូចជាអ៊ីម្នាក់ អ៊ីអត់សម្រេចប៉ុន្តែគេ៧នាក់គេសម្រេច ឧបមាថាគេចង់ ដូចថាគេមានរឿងរ៉ាវអីត្រូវសម្រេចថា ចាប់ពីណាឬក៏អីជូនអីយ៉ាងម៉េច ដូចថាអ៊ីអត់សម្រេចតែគេ៧នាក់អឺ!៦នាក់ទៀតគេសម្រេចអីចឹង យើងតាមគេឬ ក៏យ៉ាងម៉េច?

ពត: យើងដាក់ជូនកាល ប៉ុនយើងមិនបដិសេធទេណា៎ អាហ្នឹងយើងធ្វើរបាយការណ៍ឡើងទៅលើ ក៏ប៉ុន្តែយើងគ្រាន់ថាមតិយើងម្នាក់នេះ ក្នុងនាមជាលេខា គឺខ្ញុំសុំទុកអប់រំមួយរយៈដាក់ប៉ុណ្ណឹង។ បើខាងលើគេតាមក៏តាម បើមិនតាមប៉ុនសុំឲ្យខាងលើជួយជាយោបល់ តែជាគំនិតខ្ញុំជាជំហររបស់ខ្ញុំ សុំកសាង ទុកកសាង ទុកតាមដានក្រោយ។

ដានី: ក្នុងឃុំអ៊ីមានករណីហ្នឹងដែរអត់?

ពត: មាន អឺ!ករណីហ្នឹងមិនដែលមានទេ ប៉ុនមានករណីមិនមែនជាលាយលាក់អក្សរទេ ពេលដែលប្រជុំរាយមេភូមិណា៎ គេរាយការណ៍មកអញ្ចឹងមក អត់អីទេម្នាក់នេះ ខ្ញុំសុំទុកកសាងសិន ថាពុកអញ្ចឹងហ្នងរហូត ដល់គេនៅចាំដល់រាល់ថ្ងៃហ្នឹង។ ម្នាក់ហ្នឹងអត់អីទេ ខ្ញុំសុំកសាងសិន កុំអាលរាយការណ៍អី កុំអាលធ្វើអីខ្ញុំនិយាយចឹង។ អញ្ចឹងកម្មាភិបាលក្នុងថ្នាក់របស់ខ្លួនពិនិត្យខ្ញុំហើយ គេថាឯងទិន្នាការខ្សែសឹកទៅចេះចុះ វាថាម៉េចថាទៅរឿងពិតយើង។ ប៉ុនខាងលើចេះដែរអូន មិនមែនសប្បាយចិត្តនឹងសម្លាប់មនុស្សទេ កម្មាភិបាលថ្នាក់ស្រុកថ្នាក់ខេត្តក៏ដោយគេខ្លាចបំផុតដាច់កម្លាំង ឧទាហរណ៍ថាបើអស់បុគ្គលម្នាក់នឹងមួយ គេដូរមួយម្នាក់នឹងបង្កើតបងប្អូនម្នាក់នឹង វាត្រូវដាច់កម្លាំងដែរ បើថាឲ្យអង្គរមួយកំប៉ុងមក ថ្ងៃក្រោយមកត្រឹមកន្លះកំប៉ុង ហើយបើគេឲ្យពិបាកហើយ។ ចឹងគេនេះ មិនមែនសុទ្ធតែនេះសង្គមណាក៏ដូចសង្គមណាដែរអូន ប៉ុនតែមូលហេតុនេះ មិនដឹងគេមានអីនៅពីក្រោយក្នុងការសម្លាប់ហ្នឹងទេ អាហ្នឹងខ្ញុំមិនហ៊ានថាទេ សម្រាប់ខ្ញុំមួយ។

ដារ៉ា : ចឹងដោយសារតែអ៊ីដូចថា ប្រឡូកនៅក្នុងហ្នឹង អ៊ីយល់មាគ៌ាហ្នឹង អ៊ីអនុវត្តដូចថារៀងជាបែកចេញពីមាគ៌ាហ្នឹងតិច ដើម្បីការពារជីវិតអ៊ំ ក៏ដូចជាប្រជាពលរដ្ឋអីចឹង អ៊ំ?

ពត ៖ បាទៗ ។

ដារ៉ា ៖ ហើយដល់ពេលថ្មីងថ្ងៃងមក អាភាពដាក់ស្តែងឃើញគំនរឆ្អឹងឃើញអីច្រើនអញ្ចឹង អ៊ីមានការយល់ឃើញផ្សេងពីហ្នឹង ឬក៏មិនច្បាស់លាស់ពីបញ្ហានៃការសម្លាប់មនុស្ស អញ្ចឹងអ៊ី?

ពត៖ ពីព្រោះចេះ ខ្ញុំឃើញ ត្រង់នឹងដែលខ្ញុំចង់រកឲ្យឃើញ ពីព្រោះឯកសារវាខុសពីហ្នឹង ហើយសំដីតាម៉ុក និយាយខុសពីហ្នឹង។ ហើយចប់សង្រ្គាមហើយនៅភ្នំត្រែល បើមានកម្មាភិបាល ដូចកាលជំនាន់នេះ ខ្ញុំប្រកាសម៉ងតា១៥ អឺ!មិនមែនតាម៉ុកទៅ។ ពេលនឹងមានតាសោម គណៈតំបន់ ប៉ុនដល់ទីបំផុតចាប់ ទីបំផុតគេដកសិទ្ធិពីគាត់ដែរ ព្រោះគាត់បញ្ជាវ៉ែន តាសោម ថាចាប់ពីសក្តិ៥ឡើងទៅដាច់ខាតកម្មាភិបាលឃុំទាំងអស់ អត់មានធ្វើអីគេទេ កុំឲ្យសោះណា កុំតាមដានកុំធ្វើឲ្យគេភិតភ័យ និយាយប្រាប់កម្មាភិបាលទាំងអស់។ ខ្ញុំសប្បាយចិត្ត ខ្ញុំថា អូ!បានហើយប៉ុណ្ណឹង ខ្ញុំមានន័យអនុវត្ត។ ហើយមេឃុំ តាម៉ុកហើយនឹងសម្តីតាម៉ុកនៅ ពេលសន្និបាទ ដាច់ខាតមេឃុំមិនមែនប្រតិកិរិយាទេ មេឃុំអត់ប្រតិកិរិយាទេ កុំទាំងអស់គ្នា កុំឃើញថាគេមេឃុំៗចេះតែធ្វើបាបគេណា ដូចឃុំដាងទងតាសុខន គាត់ស្អីគាត់ប្រពៃណី ទំនៀមទំលាប់ ឯងទៅចុះអ៊ីតាស៊ីវិលចុះអី យកតែនំម៉ាចាក់ម៉ាដ្ដិលទៅ ហើយម្ហូមួយដៃស្វា ប្លួនដប់យកឲ្យផ្ញើប្រពន្ធគាត់ទៅគាត់ចុះឲ្យ ហើយមានអីប្រតិកិរិយា ហើយម្នាក់មួយដែល ធ្វើមេឃុំបឹងស្រង៉ែទីបំផុតកម្មាភិបាលហ្នឹង តាម៉ុកចាប់យកទៅ។ អានឹងបានខ្ញុំនឹកឃើញ សំដីខាងលើ ហើយតាសោមថាអញ្ចឹង ដល់ហើយមកឃើញគំនរឆ្អឹងអញ្ចឹងបានខ្ញុំថា ចុះកម្មាភិបាលជំនាន់នឹង ដែលទៅរៀនដែរនឹងគេអនុវត្តិយ៉ាងម៉េច ខ្ញុំចង់ឃើញចឹង។

ដារ៉ា៖ នេះអ៊ីអាចយល់បានតែត្រឹមក្នុងមូលដ្ឋានរបស់អ៊ី?

ពត៖ បាទ!

ដារ៉ា៖ នៅកន្លែងផ្សេងទៀតវាយ៉ាងម៉េចអីយើងមិនអាចដឹង?

ពត ៖ យើងមិនអាចដឹងទេ ពីព្រោះកាលណាយើងរំលោភនូវសិទ្ធិរបស់គេ ដូចថាយើងវាយឆ្កឹតរដ្ឋ នៅក្នុងរដ្ឋ។ យល់ន័យហ្នឹងទៀត ឧបមាថាសិទ្ធិរបស់ត្រពាំងធំខាងជើង បើឃើញប្រជាជនខុស ឬក៏ទៅអួសអប់រំនឹង អាកម្មាភិបាលឃុំត្រពាំងធំខាងជើង គេថាយើងទៅធ្វើចលនា អាសំដីយើងនិយាយល្អ គេថាយើងងាប់រស់ ចឹងយើងគ្រាន់តែដឹងជាជំហរសម្រាប់អនុវត្ត។

ដានី: ចុះអ៊ំៗមិញ លើកករណីថាអ្នកណាមួយណាដែលថាគេលើកមក ថាត្រូវយកទៅសម្លាប់អីចឹង ហើយអ៊ំថាទុកអប់រំសិន?

ពត: អត់មានទេ ។

ដានី: អត់មានទេ?

ពត: អឺ!ដែលខ្ញុំនិយាយហ្នឹង គឺកម្មាភិបាលនែក!បងហ្នឹង ប៉ុនឥឡូវបងខ្ញុំចាស់ជាង ។ ប៉ុនសម្តីនឹងក៏គាត់ប្រាប់គេ ដល់ពេល៧៩យួនចូលមកណ៎ា ចំពោះខ្ញុំក៏គាត់ការពារដែរ ថាអត់ទេ ដូចខ្ញុំអីគាត់និយាយនៅចំពោះមុខទេ ហើយប្រជុំនៅមឿងចារ ខ្ញុំថាអត់អីទេ បងនឹងឈ្មោះ បងហឿន ។

ដានី : បងហឿន?

ពត : អឺ! ឈ្មោះបងហឿននឹង ។ ហើយខ្ញុំអឺ! ខ្ញុំសុំទុកអប់រំគាត់សិន ការខុះខាតសំដីសំដៅ គាត់និយាយអីប៉ុណ្ណឹងវាមិនមែនជារឿងទេ គាត់និយាយ បកស្រាយពីរឿងសហករណ៍ពីរឿងស្អីៗទេ កាលហ្នឹង ព្រោះមេភូមិគេរាយការណ៍កាលហ្នឹង ។ កាលហ្នឹងបង្កើតជាសមាគមន៍អឺ!បង្កើតជាសហករណ៍កម្រិតទាប ផលហើយនឹង ។ ដល់ហើយខ្ញុំថាខ្ញុំអត់ទេ ទុកឲ្យខ្ញុំចាំខ្ញុំអប់រំគាត់ និយាយជាមួយគាត់ ។ ដល់ថ្ងៃក្រោយខ្ញុំខ្សឹបប្រាប់គាត់ ខ្ញុំជួបថា «បងឯងឥលូវខ្ញុំជម្រាបត្រង់បង យើងអ្នកចេះ យើងនិយាយខុសតែមួយចំហៀងម៉ាត់គេតាមណ៎ាបង ។ បើអ្នកល្ងង់ហើយអ្នកអត់ចេះអី អានឹងគេនិយាយ១០ម៉ាត់គេទុកជារឿងធម្មតាទេ បងតែចំពោះយើងសមត្ថភាពដូចបងឯងនិយាយតែមួយចំហៀងម៉ាត់ខុស គេតាមបងកុំឲ្យសោះ កុំធ្វើចេះ កុំធ្វើដឹង» អាហ្នឹងខ្ញុំជម្រាបគាត់អញ្ចឹង ។

ដានី: ហឿន ហ្នឹងគាត់អ្នកនៅស្រុក?

ពត: នៅភូមិអឺ!(ខ្យល់) ប៉ុនស្គាល់គ្នា គាត់ប្រជាជនសាមញ្ញ ។

ដានី: គាត់លើកហេតុផលហ្នឹង តាំងពីឆ្នាំណា?

ពត: តាំងពីជិតនាំ៧៣ ៧០អីនោះនុ៎ះ តាំងពីកើតសហករណ៍ដំបូងនោះណា មិនបាច់ចុះក្នុងហ្នឹងទេ កូនគាត់មួយធ្វើការឃុំនៅនេះដែរ ប៉ុនអាពេលហ្នឹងខ្ញុំនិយាយអញ្ចឹងណ៎ា ។ ហើយដល់ហើយសំដីនឹងឮដល់គាត់ ហើយដូច្នេះខ្ញុំ អត់បានចាប់អារម្មណ៍ ប៉ុនគាត់ក៏ប្រាប់គេប្រាប់ឯងថា «បានប្អូនពតហ្នឹងគាត់ជួយ»(សើច) អាហ្នឹងវាអញ្ចឹងណ៎ា ។/

ដានី: បាទ!

ពត ៖ ប៉ុនខ្ញុំវិភាគទៅបានខ្ញុំដឹងថា អូ!ជីវិតមនុស្ស បើគេចង់សំអប់គាត់ គឺស្ទីណា គេនឹងគេត្រូវស្លាប់ បានខ្ញុំឃើញអាគំនរដែលនេះនឹង អូ!នេះវាអាចចូលក្នុង ហើយខ្ញុំថ្មីងថ្លៃងខ្លួនខ្ញុំៗអាចដឹងថាអូ! ព្រោះពេលនឹងអ្នកដែលអត់ចេះអក្សរគេដឹកនាំ ជាមេភូមិជាបក្សជនជាអី ដូចជាកម្មាភិបាល ។ ហើយដូច្នេះ បើទៅអន្តប្រជុំណាមួយមានអ្នកនៅនឹងវាទើស ។

ដារ៉ា ៖ អឺ!

ពត ៖ ម្លោះហើយគេរកលេស អាចយល់ជាចឹង ការយល់របស់ខ្ញុំបានជាគ្នាស្លាប់ ។

ដានី ៖ ចុះអ៊ីមួយទៀត ដូចអ៊ីមានប្រសាសន៍មិញថា កាលហ្នឹងសំបូរអ្នកអត់ចេះអក្សរ ជាអ្នកដឹកនាំ ។ ចុះអ៊ីថាត្រឹមត្រូវដែរអត់ ដែលដូចថាខាងបក្សគេចាត់តាំង គេចាត់ចែងឲ្យអ្នកអត់ចេះអក្សរទៅដឹកនាំអីអញ្ចឹង?

ពតៈ មិនត្រឹមត្រូវទេអូនអើយ វាពិបាកដែលហ្នឹង ព្រោះអ្នកអត់ចេះអក្សររីង ។ ខ្ញុំពេលដែលធ្លាក់កូតម៉ោ ម៉ោជាអនុ ម៉ោជាសមាជិក និយាយប្រាប់គេសឹកម៉ាតិចហ្នឹង ភ័យខ្លួនទៀតហ្នឹង អត់ចេះអក្សរគឺជាច់ខាត គេថាត្រង់ណាត្រូវតែតាមគេហ្នឹងម៉ង បើអត់ទេ គេរាយការណ៍ឲ្យយើងងាប់វាអញ្ចឹង ។ ប៉ុនខ្ញុំវាមិនបានទៅប្រឆាំងមិនបានទៅអីទេ ពាក្យហ្នឹងម៉ាម៉ាត់ ពាក្យអីមិនដឹងទេ និយាយគេរាយការណ៍ គេថាឈ្មោះ អ៊ើ!ឈ្មោះតានេះ ឈ្មោះតាមុត ។ ប៉ុនដល់ហើយ ចលនាគេវិនិច្ឆ័យពេលហ្នឹង ចេញពីខ្ញុំបឹងខ្យាងទៅ គេឲ្យទៅធ្វើថៅហ្វាយស្រុកនៅលើកដែក ថ្ងៃ៧មករានេះ ក្រោយ៧មករា ២ថ្ងៃ ខ្ញុំអត់បានឃើញនឹងភ្នែកទេ ប៉ុនក្មេងនាយសែ ពួកនេះវីងវា បើកឡាំម៉ូណា ម៉ោតាមបាញ់ចោលនៅៗអាភ្នំស្អី ក្អែកទប់ ។ ហ្នឹងហើយ ដែលអត់ចេះអក្សរគត់ហើយ ។ ហើយកងទ័ព ដកពីកងទ័ពឲ្យធ្វើមេឃុំ ហើយដល់ហើយឡើងទៅថៅហ្វាយស្រុកគេអ្នកដាច់ខាតហ្នឹង មិនវិភាគហើយដល់ខ្ញុំសួរតាមដានរឿងអី បានពួកហ្នឹងវីងម៉ាម៉េះ វីងត្រង់ឲ្យគ្នាដឹកអង្ករពឡានដឹកអង្ករយកទៅៗឲ្យអាដែងយុវជនយុវនារី នៅប្រាសាទតាយោលដែលធ្វើអីនៅហ្នឹងណាំខ្ញុំតាមដាន គេរាយការណ៍ប្រាប់ ។ ខ្ញុំនៅកណ្តាលស្ទឹងទេ គេនៅលើកដែក ប៉ុនពេលនឹងទទួលអាឡាននេះវាផុង ដឹកអង្ករទៅវាផុងលិច ស្រាប់តែមុតហ្នឹងគេម៉ោ គេដកអាកាពេល "អាឯងធ្វើម៉េចមិនទៅដល់នឹងបាញ់ឯងហែង អត់ឲ្យឯងស៊ីបាយទេ" ។ ប្រឹងធ្វើអស់ប៉ុន្មានម៉ាយប់ ម៉ាថ្ងៃ អត់សុខចិត្តស៊ីបាយទេ ស្តារម៉ក់ ហើយដល់ហើយវាក្តៅវា អាហ្នឹងបានន័យថា អាហ្នឹងតិចច្រើនវាដល់កករ ។

ដានី: ចុះអ៊ីមួយទៀតទាក់ទងរឿងផែនការណ៍ កាលហ្នឹងយើងបង្កបង្កើនផលអីសស្រោក់ សស្រាំណាស់ណាំ?

ពត: បាទៗ ។

ដានី: អញ្ចឹងទាក់ទងហ្នឹង ដូចថាផែនការណ៍ពីថ្នាក់លើម៉ោ ដូចថាពីថ្នាក់តំបន់ ថ្នាក់ស្រុកម៉ោ គេដាក់ផែនការណ៍ឲ្យយើងបង្កបង្កើនផលអីយ៉ាងម៉េច ម៉ោដល់ត្រឹមថ្នាក់ឃុំ ថ្នាក់ភូមិយើងឲ្យយើងបង្កបង្កើនយ៉ាងម៉េចទៅអាហ្នឹង?

ពត: ម៉ាហិចតា៣តោនជាគោលការណ៍ ហើយធ្វើដីធម្មជាតិ ហើយយកលាមកមនុស្សអីហ្នឹង អាហ្នឹងអញ្ចឹង ។ ប៉ុនអារឿងហ្នឹងបេះ ត្រង់ហ្នឹងបាននេះ ខ្ញុំឃើញថាអ៊ូ!អញ្ចឹងបានប្រជាជនអត់បាយត្រង់ហ្នឹងចឹង ហើយខ្ញុំបកឲ្យអស់ ។ ហើយខ្ញុំឲ្យប្អូនឯងទៅសួរនោះ នៅកំពង់ស្វាយ និងបឹងខ្យាង ។ ខ្ញុំមកវ៉ាក់អើ! ខ្ញុំម៉ោលេងផ្ទះខ្ញុំ១ដង ម៉ែខ្ញុំគាត់ហូបបបរ ហើយឃុំដាងទង ហើយឃុំស្រែខ្វាវគាត់អត់ក៏សូវហូបបបរ ។ ចំពោះបឹងខ្យាង ម៉ាហិចតា៣តោនៗ ខ្ញុំថាអត់បាន៣តោនទេ ប៉ុនខ្ញុំមិននិយាយប្រឆាំងនឹងគេទេ ៣តោនជីមិនបានគេទៅវាស់ម៉ាការហ្នឹង ម៉ាការហ្នឹងថ្លឹងមកបាន៦គីឡូ ឬ៣គីឡូទាំងសើម គេថាគេធ្វើបានម៉ាហិចតា៣តោនជាង ឬ៤តោនជាងនោះ ។

ដានី: អឺ!

ពត: ដល់ជាក់ស្តែងមនុស្សអត់បាយប្រមាយអូន ដេកវិភាគអញ្ចឹងហើយអាកម្មាភិបាលជិនាន់ហ្នឹង វាខឹងរហូតដល់កម្មាភិបាលត្រង់ហ្នឹងដែលខ្ញុំបែងចែកថា មានកម្មាភិបាល ប៉ុល ពត មួយៗស្នេហា អាកម្មាភិបាលមួយចំនួនវាមានគំនិតធ្វើបាបប្រជាជនដែរ ។ ឧទាហរណ៍ឃុំដាងទង មានប្រជាជន ឧបមាថា១ម៉ឺននាក់ត្រូវហូបស្រូវអស់ប៉ុន្មាន១២តោន ខាងលើគេសុំឃុំដាងទង៦តោន ពី៧តោន ណែក!ខ្ញុំនៅបឹងខ្យាងនេះសុំមែន ហើយរហូតដល់ប្រឆាំងនឹងគេទៀត ប្រឆាំងនៅពេលដែលគេម៉ោយក ឧបមាបើលើសប្រជាជនឃុំហ្នឹងត្រូវហូប១២តោន ។ ប៉ុនបើធ្វើបាន១៨តោនយើងមានសិទ្ធិឲ្យ ៦តោនទៅ ដឹកយកទៅ តំបន់យកទៅ ។ ហើយដូច្នេះអា១២តោននេះ ទុកឲ្យប្រជាជនហូប បើកាលណាហូបមិនគ្រាន់សល់យកទៅ អត់យកទៅណាទេ ។ ប៉ុនកម្មាភិបាលមួយចំនួន ឃុំមួយចំនួនសំអាងថាឥឡូវ១២តោន អញចង់បានទង់ក្រហមមុខមាត់ ឃុំហ្នឹងត្រូវហូបអស់១២តោនមិនទេ សុខចិត្ត៦តោនយកទៅទៀត ទុក៦តោន ទៅចាំ៦តោននេះធ្វើស្រូវប្រាំងយកម៉ោ ។ ដល់ស្រូវប្រាំងកណ្តុរកាត់ អត់ទឹកងាប់ បបរហូប ហ្នឹងប្រជាជនអានាលនេះហ្នឹង ។ ដល់ហើយខ្ញុំថា

អ៊ូ!ពួកអាអស់នេះ ដុតឲ្យខ្មោច រោលឲ្យឆៅ រឿងហ្នឹងរឿងទង់ក្រហម រឿងនេះខ្ញុំអត់ទេ ទុកចឹង ប៉ុនរឿងពិតអញ្ចឹងម៉ង អាហ្នឹងខ្ញុំ។ អាហ្នឹងតាមុគហ្នឹង មុគហ្នឹងដែលធ្វើមេឃុំ ថាដែលខ្ញុំថា «បងអើយឈប់ទុកសិន យើងមើលភូមិសាស្ត្រ កណ្តុរកាត់ចុយម្រាយហើយ នៅអាប្រាសាទ៥ហ្នឹង កុំចាំដល់ស្រូវប្រាំងម៉ោក្រែងស្រូវ ប្រាំងមិនទាន់ប្រជាជនអត់បាយ ខាងលើគេថាយើងអត់ចេះធ្វើការ ងាប់ទៀតអាហ្នឹងយើង» ក្រឡាងាប់នៅតែងាប់ ។

ដានី: ប៉ុន្តែមួយទៀត ឧបមាថាផែនការអញ្ចឹងដល់គេតម្រូវមានគេ មានខាងលើអីឧបមាថា គេអត់បានផ្តល់ផល ផ្តល់ស្រូវអីឲ្យខាងលើអត់គ្រប់ទេ គេរករឿងយើងគេចាប់យើង?

ពត: អត់ទេ គេមុននឹងចាប់យើង គេសួរហេតុផលដែរ ហើយយើងបង្ហាញជាក់ស្តែងទីតាំងលក្ខណៈជីវភាពរបស់ប្រជាជន លក្ខណៈនេះយើង គេមិនមែនចេះតែងាកចាប់ៗទេ ខាងលើគេវិភាគដែរ ព្រោះយើងធ្វើបានដើម្បីប្រជាជន គេខ្លាចបំផុតប្រជាជនបាតុកម្ម។ ប៉ុនខ្ញុំជាមួយតាម៉ុក អត់ៗសួរនេះទេ អត់សួរខ្លាចទេ តាម៉ុក ព្រោះតាម៉ុក និយាយទៅយើងនិយាយទៅស្តាប់វិភាគជាក់ស្តែងនេះ បើគាត់ខ្លាំងទៅត្រឹមថា «បងបើកណ្តុរស៊ីអស់ហើយ បើមិនយកទៅខ្ញុំបានអី ហើយមិនមែនដូចបងឯងណា បងឯងបើអត់ខេត្តនេះ អត់ស្រុកនេះ ក៏យកស្រុកនោះ ប៉ុនខ្ញុំមិនដែលបាននិយាយអញ្ចឹងទេ ប៉ុនឧទាហរណ៍ដែលឆ្លើយឆ្លងអាហ្នឹង គឺធ្វើម៉េចប្រាប់ការពិត ។

ដានី: អ៊ំហ៊ាន?

ពត: បាទ!ហ៊ាន យើងអាចហ៊ានប្រាប់អញ្ចឹង ។

ដានី: តែជាក់ស្តែង មិនដែលបាន?

ពត: មិនដែលបាននិយាយសាកសួរទេ ប៉ុនរឿងខ្ញុំកុំបានគាត់ដែលហ្នឹង ពិនិត្យតាមដានពិនិត្យជាក់ស្តែង ពិនិត្យៗមិនចេះតែនេះទេ បើខុសនោះនេះហើយ ប៉ុនលក្ខណៈដែលមនុស្សអត់បាយប៉ុនហ្នឹង ។

ដារ៉ា: ខ្ញុំយកៗមើលនៅក្នុងឯកសារផែនការ៤ឆ្នាំរបស់ខ្មែរក្រហមអ៊ំ?

ពត: បាទៗ ។

ដារ៉ា : បាននិយាយពីរឿងម៉ាហិចតា៣តោន ម៉ាហិតា៦តោនអីអញ្ចឹង?

ពត : បាទ!

ដារ៉ា ៖ ប៉ុន្តែមិនដែល យើងមិនដែលដឹងព័ត៌មានដាក់ស្ដែងចេញពីតាមមូលដ្ឋាន ថាតើការអនុវត្តផែនការ៣តោន ៦តោនហ្នឹង វាធ្វើយ៉ាងម៉េច ហើយការបញ្ជូនអី! ផលិតផលស្រូវអីទៅថ្នាក់លើថ្នាក់អីហ្នឹងយ៉ាងម៉េច?

ពត: វាមិនដែលបាន៣តោនទេ ប្អូនអើយ ៣តោន បើធ្វើតែមួយហិចតាក៏បាន២តោនដាន់ដែរ ខ្ញុំដាក់ស្ដែង ហើយយកខ្ញុំថាឲ្យអាមួយកម្មាភិបាលឃុំដែរ ខ្ញុំថាគាត់ធ្វើម៉េចបាន៦តោន អញដូចមិនទាន់បានទេ៦តោន មានតែ១តោនដាង ហើយនឹង២តោនហ្នឹង ប្រឹងណាស់ដីមមោកយ៉ាងម៉េចក៏ដោយ ហើយមមោកហ្នឹងទៀត គេថា «បងឯងវាស់ម៉ាការប្អូន ខ្ញុំធ្វើបានធ្វើម៉ាការប្អូនជ្រុងហើយថ្ងឹង» ថា «អ្ហ៊ូ!យកអាហ្នឹងទៅធ្វើ ៦តោនៗឬអីហើយ ខ្ញុំអត់ទេ អត់ទាន់បានទេ ឃើញអន្តុយធ្វើ ធ្វើអាស្បែកអន់ហ្នឹងគេថាម៉េចថាទៅអត់» ខ្ញុំអត់ៗ ដែលត្រូវទេ។

ដានី: អញ្ចឹងបើតាមអ៊ំវិភាគមើល ប្រជាជនអត់បាយអីហ្នឹង ដោយសារកម្មាភិបាល?

ពត: បាទ!កម្មាភិបាលមួយចំនួនអួន កម្មាភិបាលមួយៗអាចង់បានទង់ក្រហមមុខមាត់ហ្នឹង លើកកញ្ចើ លើចង្អេរតាមគេហ្នឹង ងាប់ប្រជាជនហ្នឹង «កំប្រុកស៊ីផ្លែល្វា ប្រទាក់កទា ផ្សាគូថ្លុះ» ខ្ញុំយកទស្សនៈហ្នឹងមកវិភាគបានខ្ញុំរស់។

ដានី: តែអ៊ំបើតាមអ៊ំដឹងថាកម្មាភិបាលថ្នាក់លើដូចជា តាម៉ុក ដូចជាខាង ប៉ុល ពត, នួន ជា, អៀង សារី អីគាត់ដឹងថាប្រជាជនអត់បាយអត់អីដែរ ឬអត់?

ពត: បើតាមមើលកន្លែងខ្លះដឹង កន្លែងខ្លះដូចពិបាកព្រោះខាងក្រោមគេធ្វើ បេះតែបានបេះតែល្អ ហើយពួកនោះអត់ដាប់ដើងៗ។ ហើយដូចខ្ញុំថាអញ្ចឹងក្រែងមានអាអ៊ីនៅពីក្រោយធ្វើម៉េចឲ្យតែខ្លោច ធ្វើម៉េចឲ្យតែរួញហ្នឹង។ ហើយដាក់ស្ដែងសំដីខ្ញុំមួយមាត់មិញ ដែលខ្ញុំថ្លឹង ហើយពេលនោះបងខ្ញុំមានដែលទៅរៀនសាលាកម្មាភិបាលដឹកនាំ បានន័យថាខ្លួនពុះពារ ប៉ុនពេលនោះគេ បណ្ដប់ឲ្យខ្ញុំធ្វើមេឃុំហ៎!។ កំប្រុកស៊ីផ្លែល្វា ដូច្នេះប្រទាក់កទា កំប្រុកគេថ្នាក់លើមាត់មកឲ្យមាត់ល្អ ហើយដល់ផ្សាគូថធ្លុះនោះ អូនអើយបងប្រាប់អូនឯងត្រង់ណា។ អាស្នាលទោស ចប់សង្គ្រាមមក ហូតបបរនឹង យុវជនយុវនារីចុះដឹកប្រឡាយញើសតាំងពីឆ្អឹងខ្នងរហូតដល់កំប៉េះគូថ។ ហើយខ្ញុំវ៉ៃយុវជនផងអូនអើយ! ខ្ញុំវេទនាប៉ុន្មាន ហើយដល់យើងឃើញអញ្ចឹងហើយ បើយើងឃើញចឹងហើយ យើងមិនវិភាគខ្លួនយើង ហើយខ្ញុំបន់ឲ្យតែកម្មាភិបាលម៉ោពេលថ្ងៃក្ដៅ។

ដានី: តែៗអ៊ំដែលឃើញតាម៉ុក គាត់ធ្លាប់ចុះមូលដ្ឋានដែរ?

ពត: ចុះម៉ោៗឃើញដូចថាមិញចឹង ចុះម៉ោពេលម្ដងអាបេរ៉ៃៗ អឺ!អាបេរ៉ៃអីទំលាក់គ្រាប់បែក នៅខ្ពកវែងចុះមក ស្លាប់យុវនារី២នាក់កាលនឹង។ ហើយខ្ញុំមិនដឹងធ្វើម៉េចទេឥឡូវ អាហ្នឹង នៅសមរភូមិឯាប់ទេណា៎ វាស្ងាត់ជ្រាប។

ដានី: ប៉ុន្តែជំនាន់យើង ជំនាន់ក្រោយឆ្នាំ៧៥ ពី៧៥ដល់៧៩ មើលទៅអ៊ំដឹងថាគាត់ដូចថាគាត់ ធ្លាប់ចុះទៅមូលដ្ឋានឃើញប្រជាជនដាក់ស្ដែងធ្វើស្រែធ្វើចំការ ហូបចុកអីគាត់ធ្លាប់ចុះម៉ោ អញ្ចឹងដែរ មើលទៅ?

ពត: គាត់គាត់ គាត់ជិះឡានជិះអីគាត់អញ្ចឹង មើលទៅ ត្រង់គាត់ចុះណាៗយើងអត់ដឹងទេណា៎ អត់ដឹងទេ។ ក៏ប៉ុន្តែករណីសម្រាប់ខ្ញុំវិញក្រោយ៧៥ នឹងដើម៧៥នេះ កន្លែងធ្វើការខ្ញុំមិន ប្រឡោតអត់ប្រឡោតទេ ដូចខ្ញុំថាអញ្ចឹងខ្ញុំវិភាគមើល។ អត់ប្រឡោតម៉េច កន្លែងខ្លះខបមា ថា ឥឡូវចុះទៅប្រាសាទ៥ទៅធ្វើការប្រឡាយទំនប់អញ្ចឹង កម្មាភិបាលគេម៉ាចំនួនគេរុញ ទៅ រ៉ូទៅចឹងម៉ោ ឲ្យប្រជាជនធ្វើ ហើយអារូមកឯអត់ទាន់មាន គេយកមុខយកមាត់ ណាស់។ ខ្ញុំអត់ទេ ៣ថ្ងៃវ៉ាន់ ទៅដល់ខ្ញុំដាក់អញ្ចឹងឲ្យធ្វើរោងៗហើយ ណានេះធ្វើបន្ទីរ អាគេទៅដល់ ជំរុញបឹបទាំងថ្ងៃក្ដៅឡើងមកដល់ដេកអត់មាននេះ ហាលទឹកសន្សើមមិន ឈឺ។ ហើយយើងធ្វើអានឹងឲ្យហើយ ប្រដាប់ឈ្នះឲ្យហើយគិតច្រើនអីទាន់មានធ្វើ ដាក់ សម្រេច។ អាហ្នឹងអញ្ចឹងបានវាការងារហ្នឹង វាទៅតាមដំណើរហ្នឹងដែរហ្នឹង មិនចេះតែ។

ដានី: បាទ!មិញខ្ញុំភ្លេចសួរ អ៊ំឪពុកអ៊ំឈ្មោះអីដែរ?

ពត: សៅ មី។

ដានី: ឈ្មោះ សៅ មី?

ពត: បាទ! មី។

ដានី: គាត់ស្លាប់អស់ហើយឥឡូវ?

ពត: ស្លាប់ហើយ មី មិនមែនម៉ីទេ។

ដានី: ចុះម្ដាយ?

ពត: សុខ ពេន។

ដានី: សុខ ពេន?

ពត: បាទ! សុខ ពេន។

ដានី: គាត់ស្លាប់ដែរ?

ពត: ស្លាប់ដែរ។

ដានី៖ ចុះអ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ទៅ?

ពត៖ បងប្អូនបង្កើតច្រើនខ្ញុំ ១០នាក់ ប៉ុនឥឡូវនៅ៨ទេ មើលឈប់រាប់សិន។

ដានី៖ ទាំងអស់១០នាក់ ឥឡូវនៅសល់៨ទេ?

ពត៖ អឺ! មុត អ៊ំជ្រុន ខ្ញុំ មើល អាវក អាវ៉ាន់ អាសុង នៅ៨។

ដានី៖ សល់៨?

ពត ៖ បាទ! សល់៨។

ដានី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ពត៖ ប្រុសនៅ៣ ប្រុសតែ៣ទេ ។

ដានី៖ ប្រុស៣ ស្រី?

ពត៖ ស្រី៥ ។

ដានី៖ ស្លាប់អស់២អញ្ចឹង?

ពត៖ ស្លាប់អស់២ ។

ដានី៖ ស្លាប់ស្រីឬប្រុស ស្លាប់?

ពត៖ ស្លាប់ស្រី ។

ដានី៖ ស្រីទាំង២នាក់?

ពត៖ (ខ្យល់) ប៉ុនស្លាប់តាំងពីខ្ញុំនៅតូចៗ អត់ដឹងអីនេះ ។

ដានី៖ អ៊ូ!បាទៗ អញ្ចឹងកាលពីសម័យពី៧៥ដល់៧៩ហ្នឹង បងប្អូនអ៊ំមាននៅទាំងអស់អត់មានស្លាប់ទេ?

ពត៖ នោះបានបងដែលមួយនឹង ដែលខ្ញុំថាជាប់នៅ២០៨ហ្នឹង ប៉ុនគាត់រស់វិញ ។

ដានី៖ គាត់ឈ្មោះអី?

ពត៖ សៅ ជ្រុន ។

ដានី៖ សៅ ជ្រុន?

ពត៖ បាទ! សៅ ជ្រុន ។

ដានី៖ បាទ! ចុះបងប្អូនអ៊ំមានអ្នកណាខ្លះដែលធ្វើកម្មាភិបាលដូចអ៊ំដែរ?

ពត៖ កាលហ្នឹងគឺ មានតែខ្ញុំមួយទេ ហើយប្អូនស្រីខ្ញុំមួយឈ្មោះ សៅ វ៉ាន់ ឥឡូវនៅភ្នំព្រឹកនោះគេខាងកម្មាភិបាលអឺ!នៅស្រែអំបិល បាទ!សៅ វ៉ាន់។

ដាវ៉ា៖ ចុះអឺ! ប្អូនរបស់អ៊ំឈ្មោះ សៅ ជ្រុននេះ គាត់នៅណា?

ពត:	បង១ សៅ ជ្រុននេះ ដែលគាត់ឈ្មោះ សៅ ស៊ុម គាត់ធ្វើការពីសង្គមលន់ នល់ នៅ ភ្នំពេញ ជំទុកលេខ៣ សង្កាត់លេខ៦ ។

ដានី:	សព្វថ្ងៃគាត់នៅណាឥឡូវ?

ពត:	ដល់៧៩នោះ គាត់ធ្វើខាងដែនការនៅតាកែវ ហើយនៅខាងភ្នំពេញ តែឥឡូវគាត់រ៉ៃត្រែត នៅខាងលិចវត្តអមរា នៅឃុំរកាក្នុង រកាកោងមិនដឹង រកាក្រៅ ។

ដានី:	នៅខាងលិចវត្ត?

ពត:	ខាងលិចវត្តអមរា ។

ដានី:	ម៉ារ៉ា?

ពត :	អមរាចេះ ។

ដានី :	វត្តអមរា នៅរកា?

ពត:	នៅរកាក្រៅ រកាក្នុង អាផ្លូវទៅក្បាលពោធិ៍ (ខ្យល់)ផ្លូវទៅក្រុងតាកែវទៅប្រហែលកន្លះ គីឡូ នៅជិតហ្នឹង ។

ដានី:	អូ!នៅក្នុងស្រុកដូនកែវ?

ពត:	បាទ! ស្រុកដូនកែវ ។

ដារ៉ា:	គេហៅវត្តអីគេអំ?

ពត:	វត្តអមរា ។

ដារ៉ា :	វត្តអមរា ។

ដានី:	ប្រពន្ធគាត់ឈ្មោះអីដែរ?

ពត:	ប្រពន្ធអី! ឈ្មោះគាត់ ប្រពន្ធគាត់ឈ្មោះ មុំ ហ៉ៅ ត្រូវនេះដែរ ត្រូវជាជីដូនមួយខ្ញុំដែល ហ្នឹង ។

ដានី:	គាត់នៅទាំង២នាក់ប្ដីប្រពន្ធ?

ពត:	នៅទាំង២នាក់ ។

ដានី:	គាត់អាយុអី! ស្របាលណាហើយ?

ពត:	ប្រុសអំរបស់បងខ្ញុំ អាយុ៧៣-៧៤ហើយ ខ្ញុំ៧១ហើយ ។

ដានី:	បាទ!

ពត:	ហើយប្អូនមួយឈ្មោះ សៅ ចំរើន រាល់ថ្ងៃនៅក្រុមប្រឹក្សាឃុំខាងទឹកថ្លា ខាងសមរង្សី ដែលហ្នឹង អាហ្នឹងប្អូនប្រុស ។

ដានី:	ខ្ញុំដូចជាអស់សំនួរអីសួរនាំអ៊ំទៀតហើយ អញ្ចឹងអ៊ំមានអីចង់បន្ថែម?

ពត:	អត់ទេ!អត់មានអីចង់បន្ថែមទេអូន គ្រាន់តែត្រេកអរបានម៉ោសាកសួរអញ្ចឹងហាក់ដូចជាធូរអារម្មណ៍ដែរណា ខ្ញុំវាមានលក្ខណៈមួយចង់បញ្ជាក់ការពិតអញ្ចឹងដែរ ប៉ុនអាអ៊ីដែលខ្ញុំនិយាយនេះជារឿងពិតរបស់ខ្ញុំ ។

ដានី:	បាទៗ!រឿងរបស់អ៊ំ?

ពត:	បាទ!រឿងរបស់ខ្ញុំ ហើយបើនិយាយទៅវាខ្ញុំនេះ អឺ!៧០មកទល់៧៥ហ្នឹង គឺធ្វើកម្មាភិបាលហ្នឹង ធ្វើការរបបហ្នឹង ប៉ុល ពតហ្នឹង ៧៩ម៉ោហ្នឹងមកទល់២០០២នឹង ក្នុងស្រុកក្នុងភូមិប្រជាជន គាត់ពឹងខ្ញុំឲ្យធ្វើមហា ធ្វើអាចារ្យពាលាវៀបចំមង្គលការឲ្យគេហ្នឹងណាំ ។

ដានី:	អ្ហូ!

ពត:	ហើយដល់ហើយ ខ្ញុំនិយាយប្រាប់អូនឯងហើយកុំយកពាក្យហ្នឹងទៅណាទៀតណាស់ ។

ដានី:	បាទ!

ពត:	ខ្ញុំអន់ចិត្តត្រង់គេថា កម្មាភិបាល ប៉ុល ពត ចេះប្រតិកិរិយាយ៉ាងយោរយៅ ដល់មានខាងនយោបាយឈប់ហើយ ដល់ហើយសមរង្ស៊ីគាត់ផ្តើមឡើងអញ្ចឹង បាននឹកឃើញថាអញសាកលរមើល អញធ្វើការនៅឃុំដាងទងពី៧០ទល់៧៥ បើអញប៉ុល ពត ប្រតិកិរិយាចាំមើល មានគេបោះឆ្នោតឲ្យអត់ ។

ដារ៉ា :	ចង់សាកចឹងទេ?

ពត :	អឺ! ចង់សាកចឹងទេ ដល់ទៅក៏ដាក់មួយកៅអីទៅ បាន៦០០សំលេងគត់ ៦០០ប្អូន៦០០គត់បានអាណត្តិទី១ហ្នឹងឈ្មោះ ពត ជំទុកទី២ អាហ្នឹងអញ្ចឹង ។ ហើយដល់ហើយទៅខ្ញុំវាចាស់ហើយ គ្មានគំនិតអីចង់ឲ្យវាមុខមាត់អីណាទៀតទេ ប៉ុនចង់រួមចំនែកឈឺចាប់ដែរ អ៊ីដែលយើង ទឹកដីរបស់យើង អញ្ចឹងក៏ឲ្យអាមួយនោះវានៅបាក់ឌុបឲ្យវារៀនបរិញ្ញាហ្នឹង ប្អូនឯងបើមានដំនោរអញ្ចឹងហើយ ចូលឈរលំដាប់ទី១ទៅ ហើយខ្ញុំក្នុងប៉ុន្មាន១៩-១៨នាក់ហ្នឹង ពេញសិទ្ធិ៩៧ត្រៀមហ្នឹងណាក្នុងសមាជិកក្រុមប្រឹក្សាហ្នឹង ឯដាក់ត្រង់ណា វុញដាក់ត្រង់ណាដាក់ទៅ ហើយដល់ហើយគេព្រមគេរុញមកបញ្ចប់ត្រឹមលេខ២លេខ១ នឹងលេខ២ អញ្ចឹង ក៏បាន២កៅអីហ្នឹងបានមានឈ្មោះមករាល់ថ្ងៃនឹងទៀត ។

ដានី:	បាទ!ចុះអ៊ំកាលពីបែក៧៩ពេលដែលយួនចូលម៉ោនេះ អ៊ំអត់អីទេនៅប្រជាជន គេអត់មានចាប់អីអ៊ំ?

ពត:	អត់ទេអូន ប៉ុនម៉ោពីខ្ញុំដែរ ខ្ញុំនិយាយស្មោះត្រង់ប្រជាជនអត់មានវិនិច្ឆ័យទោសខ្ញុំទេ គេបញ្ជូន ថ្ងៃហ្នឹងគេហៅខ្ញុំ ហើយឯងនេះដែរ ចង់សុំទៅជាមួយគេ ដល់ហើយបានអាមួយគេគិ្គច "ឆ្កួត គេហៅទៅរៀនអាជ្ញាប័ណ្ណបើកខ្សែភ្លើងខាងនៅកោះអណ្តែតនោះណា" ។ ឯងថាសុំទៅជាមួយគេឲ្យហើយម៉ង ដល់ហើយបានគេគិ្គចពីឆ្អឹងខ្នង អញ្ចឹងឲ្យបានមកនៅផ្ទះវិញ ។ ប៉ុននៅបាន២ឆ្នាំខ្ញុំអាលាក់ អាលើខាងអង្គការចំនុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ខ្ញុំជាប់គុក២ដងទៅទល់នឹងនយោបាយ ១៨-ខរបស់ខ្មែរក្រហម ឡើងទៅភ្នំហ្នឹងទៀតនោះ ។

ដារ៉ា:	អឺ! ទៅទៀត?

ពត:	ទៅទៀត(សើច) អាហ្នឹងខ្ញុំនិយាយទៅទៀត ទៅអញ្ចឹងហើយម៉ោវិញ អត់ដឹងចាញ់បោកក្មេង ដូចថារលកធាក់រលក យើងអត់ដឹងណាំ ទៅយកម៉ោៗបាន២ថ្ងៃគេហៅ ទៅហ្នឹងជាប់បាន៣ខែ ។

ដានី:	ជាប់នៅណា?

ពត:	នៅតាកែវ ជាប់គុកហ្នឹង ។

ដានី:	នៅតាកែវ?

ពត:	បាទ! ប្រឆាំងនឹងយួន ឆ្នាំ៨០ប្លាយហើយ ។

ដានី:	២ដង ហើយឆ្នាំ៨០ប៉ុន្មាន?

ពត:	៨៣-៨៤ ៨១មិនដឹង ដល់ហើយអូនឯងក្រោយមួយទៀត ដែលមានបង្កើតអង្គការចំនុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យនោះ វាមាន៤ត្រីភាគីនោះណា ។

ដារ៉ា:	បាទ!

ពត:	សឺន សាន, ខ្មែរក្រហម, ហើយនឹងខៀវ សំផនហ្នឹង អង្គការចំនុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យសឺន សាន ហើយនឹង ហ៊ុនស៊ិនប៉ិច ។ ហើយនឹងខ្ញុំកាលហ្នឹង តាខៀវ សំផន គាត់គណបក្សមួយ ។

ដានី:	បាទ!

ពត:	ខ្ញុំតំណាងបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យហ្នឹង ។

ដារ៉ា :	បាទ! បក្សកម្ពុជាប្រជាធិបតេយ្យ ។

ពត :	បាទ! ប្រជាធិបតេយ្យនឹង ប៉ុនរំលាយកប្បរហើយ ។ ដល់ហើយយករូប ខៀវ សំផនហ្នឹងកាន់ខាងខ្មែរក្រហមខាងកម្ពុជាប្រជាធិបតេយ្យហ្នឹង យកម៉ោយកមកចែកគេ ចែកលាក់ស្ងាត់ទេ ។

ដារ៉ា: បាទ!

ពត: ដល់ហើយគេដឹងរឿង ក៏ចូលនឹកឃើញនៅកៀរចុះកៀរសារជិត៥០នាក់ គ្នាច្រើនដែរណា៎ ខ្ញុំចេញមក បើកាលណាឯងរឹងមុខជាផាប់ (ខ្សឹល) ហើយពួកអានោះជាប់គុកទាំងអស់គ្នា ។ ហើយអញ្ចឹងក៏ទៅសារភាពបង្ហាញគេ ព្រោះយកមកលាក់ទុក ហើយចែកខ្លះហើយលាក់ទុក ។ ដល់ហើយក៏ទៅលើកក្រោយនេះ ទទួលខ្ញុំទៅសារភាពអញ្ចឹង ទៅក៏ពេលនោះខ្ញុំអត់លាក់ខ្លួនឯងទេ ល្បិចទល់ល្បិចដែរខ្ញុំ ព្រោះគេថាឲ្យទៅសារភាពគេឲ្យរួចខ្លួន ។

ដានី: បាទ!

ពត: អញ្ចឹងក៏សារភាព សារភាពហើយក៏គេឲ្យមកផ្ទះវិញ បានមកផ្ទះវិញបានប៉ុន្មាន៤-៥ថ្ងៃគេហៅទៅអង្គការសោមកន្ទះខែ ។ ខ្ញុំផ្ញើម៉េចបើខ្ញុំភ័ន្តច្រលំ ប៉ុនភ័យដែរ ព្រោះក្រោយអាលើកទី១ម៉ោ យើងរួចហើយគេឲ្យរួចហើយណា ។ ហើយលើកទី២ ក្រោយពេលហ្នឹងគឺដុតរូប ខៀវ សំផន, ដុតរូប សីហនុ ដុតរូបនេះឯងទៅចចេះទៀតភ័យដែរ ។ ដល់ហើយក៏បានកន្ទះខែឲ្យម៉ោវិញ ម៉ោប្អូនអើយពេលនេះ ខ្ញុំដល់ហើយក៏ទៅចឹងអង្គការអនុគ្រោះមកដែរ ដូចថា អង្គការអីគេចាំឆ្លើយសមស្របនឹងគេអនុគ្រោះឲ្យមកវិញម៉ោ ។ ហើយថាឈប់ហើយរឿង នយោបាយហ្នឹង ឈប់ហើយចាស់ចំណាស់នេះហើយ កុំឲ្យគេដៀលដូចថាចេះចុះមនុស្ស ភ័ន្តច្រឡំ ។ ប៉ុនដូចខ្ញុំថាមិញ គេថាដេរៗគេថា អីណាប្រតិកិរិយាឃោរឃៅ អញ្ចឹងសាកលរមើលអញរស់នៅក្នុងឃុំហ្នឹងដែរ វាឃោរឃៅ ហើយប្អូអត់អាហ្នឹងប៉ុនហ្នឹងទេ ។ មិនមែនចង់ប្រឆាំងប្រាស់អីទេ គំនុំគុំគួនអីអត់ទេអូន ។ ហើយដល់ហើយក៏សិក្សាទំនាយៗគេថា "ស្រីសល្អដូចហង្ស គេមិនចង់សុខចិត្តនៅប្រុស" (ខ្សឹល) នៅខាងសមរង្សីជាច់ខាតៗអត់ហ៊ានថាទេ អត់ឈ្នះទេអូនៗ អត់ឈ្នះទេ បានជាគេថា "ស្រីសល្អដូចហង្ស" គេមិនចង់ទុកចិត្តនគរ" មើលរដ្ឋធម្មនុញ្ញ២ភាគ៣ បោះឆ្នោត២អាណត្តិម៉ោ គ្មានអ្នកណាបាន៨០ភាគរយបង្កើតរាជរដ្ឋាភិបាលតែម្នាក់ឯងបាន ។ អញ្ចឹងបានន័យថាកម្ពុជាអាមេរិចកាំង យកតែម្នាក់ឯងក៏អត់បានដែរ កម្ពុជាអាកុម្មុយនីស្តយកតែម្នាក់ឯងក៏អត់បានដែរ ឆ្ងងពីអាហ្នឹងម៉ោ ជិនះឲ្យឈ្នះនិយាយហើយអូនចាំទុក ប៉ុននិយាយអញ្ចឹងកុំៗ ។

ដានី: បាទ!

ពត: គេថា "ស្មាពីរលើក្អាងបី ជនប្រុសស្រីលៃម៉េចលីឲ្យហើយអស់ឲ្យរួច" ។

ដានី: ស្មាពីរលើក្អាងបីម៉េច?

ពត៖ ស្នាពីរលើក្នាងបី ។

ដារ៉ា៖ ក្នាងហ្នឹងអីគេអុំ?

ពត៖ ក្នាង នន្ទ័ល នេះ ។

ដារ៉ា៖ អ៊ូ! ក្នាង នន្ទ័ល ។

ពត៖ “ស្នាពីរលើក្នាងបី ជនប្រុសស្រីលែយ៉ាងម៉េចលីឲ្យអស់ ហើយឲ្យរួច” ។

ដានី៖ លីម៉េចរួចទៅ?

ពត៖ បានន័យថាកម្ពុជាយើងរាល់ថ្ងៃ អូនឯងឃើញមានតែរបបពីរទេ មានតែគណៈបក្សពីរទេ អត់ទេប្រជាជននៅតែវេទនាអញ្ចឹង ប៉ុនខ្ញុំអត់មាត់ទេកាលណាមាត់គេថា “ឯងសត្វ.....ធ្វើស្អីចេះចុះ” បានន័យថាមានតែបក្សកាន់អំណាចនឹងបក្សប្រឆាំង ។

ដារ៉ា៖ បាទ!

ពត៖ អញ្ចឹង ជាតិ សាសនា ព្រះមហាក្សត្រ បាត់ត្រង់សាសនាហើយ អញ្ចឹងដល់មានរបបកណ្តាលមួយ ដល់មានអូន ចាំមើល ស្នាពីរបានន័យថាដល់អព្យាក្រឹត្យ លោកអព្យាក្រឹត្យនេះសង្កត់អ្នកទាំង២ កណ្តាលអូន ។ ហើយអូនឯងមើល គេថាវិមានៗមុខ៣ផុសលើទឹកដីកម្ពុជា ពេលនោះប្រទេសជាតិនឹងប្រែប្រួល អូនឯងមើលសាលាឃុំ មួយប្រទេសគេឲ្យលុយមកអភិវឌ្ឍន៍ធ្វើ ហេតុអីក៏មិនធ្វើដោយឯករាជ្យម្ចាស់ការឃុំមួយៗ ឃើញមុខ៣ទេ ។ នេះហើយខ្ញុំនៅឈរ ធ្វើមេឃុំ ជំទុកទី១ អាណត្តិទី១ ដំបូងអូនឯងមិនមើល ឃុំណាដូចឃុំណាដែរ មុខ៣ឃើញទេ ហើយមានមួយសង្កត់ អានេះសង្កត់មកនេះបន្តិច សង្កត់មកមុខបន្តិច ឃើញទេ បានអីអព្យាក្រឹត្យរហូត ។ ហើយមុនពីហ្នឹងមក ពុទ្ធោអារហំ ពុទ្ធំធម្មោខ្ញុំនឹកគុណព្រះគោ ព្រះកែវ ជួយផង ខ្ញុំដាំពោធិ៍មួយមិនទាន់បានឆ្លង ព្រះគោ ព្រះកែវជួយផងសុំឆ្លងវាល៣ វាល១បែកផ្សែង, វាលវែងក្រក្រៃ, សុំឆ្លងវាល៣ដល់ព្រះនិពាន្ទ ។ ហ្នឹងខ្ញុំចេញពីគុកលើកទី១ តាមួយប្រាប់ ដល់ប្រាប់គ្រាន់តែគាត់និយាយចប់ ខ្ញុំថា “ត្រូវហើយតា ត្រូវហើយពូឯងយូរណាស់មិនប្រាប់ខ្ញុំ” ។

ដានី៖ ចុះអុំៗដែលគេហៅទៅកន្ទះខែលើកទី២នេះ ឆ្នាំណា?

ពត៖ ឆ្នាំហ៊ើ ក្រោយពីមានអាដែលអង្គការចំរុះ ត្រីភាគីកម្ពុជាប្រជាធិបតេយ្យ ខ្ទង់៨៣-៨៤ អីនឹង ខ្ទង់នឹង ។

ដារ៉ា ៖ បាទ! ខ្ទង់នឹង ។

ដានី៖ លើកទី១ ឆ្នាំ៨១ លើកទី២ ៨៣-៨៤?

ពត៖ បាទ! ខ្ទង់៨៣-៨៤ ក្រោយពីដុតរូបសីហនុហើយ ដល់ដុតទៅរូបសីហនុ ហើយគេថា "ផ្តេកស្អុយអូសយកពងមាន់ នៅក្នុងរាវរេ ម្តេចហើរចឹកឲ្យក្អែក, ផ្តេកស្អុយអូសយកទៅចោលម្តេចឡើយ បែកបែរខាំដូចគ្នាតវិញ" អូនឯងឃើញទំនាយ ឥលូវសិក្សាខ្ញុំចង្អុលថា "ពងមាន់នៅក្នុងរាវ បានន័យថាខ្មែរក្រហមសំបុកតែមួយទេ ហើរចឹកឲ្យក្អែកវិញ ដល់ផ្តេកស្អុយអូសយកទៅចោល ម្តេចឡើយបោចបែរខាំឲ្យគ្នាតវិញ សីហនុដុតចោលហើយ (ខ្យល់) ខៀវ សំផន, នួន ជា អីណា ដល់ហើយបានប្រមូលទៅចចារឃើញទេ ដេញឲ្យគ្នាតវិញ យួនទៅ ទ័ពយួនទៅ ។

ដានី៖ បាទ! ខ្ញុំអរគុណអ៊ំច្រើន ។

ពត៖ (សើច) សុំទោសណាខុសត្រូវ ។

«ចប់»